# ពន្លឺធម៌ព្រះពុទ្ធ

## ១_សិរីជាទ្រព្យដ៏ប្រសើរ

សិរីក្នុងទីនេះ គឺជាសេចក្តីល្អ ឬជាបុណ្យកុសល ដែលមនុស្សយើងបានធ្វើទុកមក តាមលំដាប់លំដោយ រហូតបានជាបុញ្ញនិធិ ជាគំនរបុណ្យ ឬជាបុណ្យបារមីដែល ជាប់តាមបុគ្គលអ្នកធ្វើនោះរហូតមកហ្នឹងឯង ។

សិរី គឺជាទីមកហើយស្ថិតនៅនៃភោគៈទាំងឡាយ ដោយសេចក្តីថា ភោគសម្បត្តិទាំងឡាយ ហាក់ដូចជា ចូលចិត្តតែមនុស្សណាដែលមានសិរីនៅក្នុងខ្លួនអ៊ីចឹង រីឯ មនុស្សណាមិនមានសិរីនៅក្នុងខ្លួន ឬអស់សិរី សម្បត្តិមិន ប្រាថ្នានៅជាមួយឡើយ ។

មនុស្សយើង ស្វម្បីបានភោគសម្បត្តិមកអំពីគំនរ មរតកក្តី បានមកអំពីអំពើអ្វីៗផ្សេងៗក្តី តែកាលណាខ្វះសិរី



ហើយ ភោគសម្បត្តិទាំងអស់នោះ រមែងសន្សឹមៗ អស់ទៅៗ ពេលខ្លះសម្បត្តិថ្មីដែលបានមកនោះ ត្រឡប់ទៅ ជាមកនាំយកសម្បត្តិចាស់ឱ្យវិនាសទៅជាមួយក៏មាន ថែម ទាំងគ្រោះថ្នាក់ដល់ខ្លួនជាម្ចាស់ទៀតផង ។

បុណ្យដែលចាត់ថាជាសិរីនោះ បានដល់បុណ្យគឺ ការប្រព្រឹត្តធម៌ដែលជាសេចក្តីល្អផ្សេងៗ ដូចជាការមាន មេត្តាករុណា ការអើពើទំនុកបម្រុង ការមានអាជីព សុចរិត ការនិយាយពីរោះ ការគោរពឱនលំទោនជាដើម ដែលធ្វើឱ្យអ្នកដទៃពេញចិត្ត ជិតដិតស្និទ្ធស្នាល និងជា ឧបការៈជួយឱ្យខ្លួនឯងមានសេចក្តីចម្រើន ឈានឡើង ដោយលំដាប់ រួមទាំងការវៀរចាកនូវអំពើអាក្រក់ទុច្ចរិត គ្រប់បែប វៀរចាកអបាយមុខគ្រប់ប្រការ ហើយមាន ព្យាយាម មិនខ្ជិលច្រអូសក្នុងការងារផ្សេងៗផង ទាំងអស់ នេះឯងគឺជាសិរីរបស់មនុស្ស ។

មនុស្សដែលប្រព្រឹត្តធម៌ដូចពោលមកនេះ ចាត់ថា ជាមនុស្សមានសិរី និងសមគួរជាមនុស្សប្រភេទ « ជាទី

មកហើយស្ថិតនៅនៃភោគៈទាំងឡាយ » ។ ចំណែកបុគ្គលមិនប្រព្រឹត្តធម៌ វៀរចាកទុច្ចរិតមិនបាន ញៀនក្នុងអបាយមុខសព្វគ្រប់ ដូចនេះ ទោះជាបានទ្រព្យសម្បត្តិពីណាមកក៏ដោយ ក៏នៅមិនយូរឡើយ ត្រឹមតែមួយថ្ងៃពីរថ្ងៃ ក៏នឹងមានហេតុឱ្យទ្រព្យចេញចាក ទៅនៅជាមួយមនុស្សមានសិរីវិញដោយពិត ។

សិរីនេះនៅជាមួយអ្នកណា គឺជារបស់អ្នកនោះ មិនអាចខ្ចីគ្នា ឬសូម ឬលួចបានឡើយ មិនមែនដូចជាទ្រព្យខាងក្រៅដែលអាចខ្ចីគ្នាជាដើមបាននោះទេ ។

ម្យ៉ាងទៀត សិរីបានដល់ភាពជាធំ មានឋានៈខ្ពង់ខ្ពស់ មានស័ក្តិមានយស ដោយបុណ្យបារមីចាស់ ឬបុណ្យថ្មីក៏ដោយ ដោយការចេះដឹងព្រមដោយសមត្ថភាពពិតប្រាកដក៏ដោយ អ្នកនោះ រមែងបានទទួលនូវទ្រព្យសម្បត្តិទាំងឡាយដែលមកអំពីគ្រប់ទិសទាំងពួង ព្រោះមានភាពជាធំនោះឯង ។

ដោយហេតុនោះ បើត្រូវការឱ្យមានសិរីសួស្តីក្នុង



ខ្លួន ឬនៅជាមួយខ្លួន ត្រូវសាងសិរីសួស្តីនោះ ដោយការប្រព្រឹត្តខ្លួនឱ្យជាមនុស្សល្អ ជាមនុស្សយល់ហេតុយល់ផល និងមានគុណធម៌ មានទឹកចិត្ត មិនឃើញតែខ្លួនឯង មានព្យាយាមមាំមួន ចេះប្រយ័ត្ន មានកតញ្ញូតាធម៌ គ្រប់គ្រងអាជីពដោយសីល ធ្វើតែការងារប្រាសចាកទោស វៀរចាកអបាយមុខដោយដាច់ខាត ។ល។ ពោលគឺចេះរៀបចំជីវិតឱ្យជាទីកើតឡើង និង ជាទីអាស្រ័យនៅនៃសិរីសួស្តីហ្នឹងឯង ។

មនុស្សមានសិរី នៅក្នុងទីណា រមែងធ្វើឱ្យទីនោះចម្រើន នៅក្នុងគ្រួសារណា គ្រួសារនោះក៏មានការរស់នៅជាសុខ មានលាភមានយស មានទ្រព្យសម្បត្តិស្តុកស្តម្ភគង់វង្ស និងមានភាពត្រជាក់ត្រជុំក្នុងក្រុមគ្រួសារនោះៗ ។

សិរីទើបជាទ្រព្យដ៏ប្រសើរ និងជាទីស្ថិតនៅនៃភោគៈទាំងឡាយដ៏ពិតប្រាកដ ។

## ២.ចំណុចខ្វះខាតនៃជីវិត

ពេលខ្លះ យើងអាចកើតសេចក្តីសង្ស័យឡើងថា បុគ្គលនោះគេល្អគ្រប់យ៉ាង ការចេះដឹង និងសមត្ថភាពផ្សេងៗទៀតក៏ល្អ ការប្រព្រឹត្តជាទូទៅក៏ល្អ ឯមុខនាទីការងារក៏ខ្ពង់ខ្ពស់ សេចក្តីព្យាយាម ព្រមទាំងអធ្យាស្រ័យមេត្រីភាព ក៏គួរឱ្យគោរពរាប់អាន ប៉ុន្តែ ហេតុដូចម្តេចទើបគេនោះមិនចម្រើនរុងរឿងឱ្យសមនឹងការងារ មានតែរឿងរ៉ាវមិនចេះចប់ទៅវិញ ពុំនោះសោតទេ គឺមិនមានអ្នកណាឃើញដល់សេចក្តីល្អរបស់គេទាំងនោះ ម្តេចក៏សេចក្តីល្អដែលគេធ្វើនោះមិនជួយគេផងហ្ន៎ ។

យើងអាចសង្ស័យយ៉ាងនេះក្នុងអ្នកដទៃ ពេលខ្លះក៏សង្ស័យចំពោះខ្លួនឯង ។ កាលគិតរកចម្លើយត្រឹមត្រូវមិនឃើញ ក៏ត្រឡប់ជាគិតយល់ថា « ធ្វើល្អមិនបានល្អ » ទៅវិញ ។



តាមពិតមនុស្សយើងជាទូទៅ រមែងមានល្អ ហើយក៏មានមិនល្អផងដែរ ប៉ុន្តែកាលដែលមានល្អច្រើនទៅនៅក្នុងផ្នែកផ្សេងៗ យើងក៏រមែងមើលរំលងនូវអ្វីដែលមិនល្អទាំងអ្វីដែលមិនល្អនោះមាននៅក្នុងខ្លួនផងដែរ ។ ដូចក្នុងករណីខាងដើមអីចឹង មនុស្សដែលយើងមើលថាល្អនោះ យើងសាកសង្កេតរកចំណុចខ្វះខាត ដែលធ្វើឱ្យគេមិនបានចម្រើនរុងរឿងក្នុងជីវិតទៅមើល យើងនឹងអាចឃើញបាន ទាំងដែលចំណុចខ្វះខាតដែលយើងបានរកឃើញនោះ អាចជាចំណុចខ្វះខាតដ៏សំខាន់ខ្លាំងរបស់គេក៏មានដែរ គឺគេអាចល្អខាងក្រៅដែលយើងមើលឃើញគ្រប់យ៉ាង តែគេអាចខ្វះសេចក្តីល្អខាងក្នុង ពុំនោះសោតទេ គឺគេខ្វះសេចក្តីល្អពីជាតិមុនមក ។

ការខ្វះខាតសេចក្តីល្អខាងក្នុង ដែលជាចំណុចខ្វះខាតដ៏សំខាន់ខ្លាំងនោះ គឺខ្វះខាតការនឹករលឹកដល់សេចក្តីល្អរបស់អ្នកដទៃ ព្រមទាំងទទួលយកថាជាសេចក្តីល្អពិតហើយចារឹកទុកក្នុងបេះដូងរបស់ខ្លួន នឹងរកឱកាស

តបស្នងរហូតទៅ ។

កតញ្ញូតាធម៌ ចាត់ជាគុណធម៌ដ៏សំខាន់ ជាភូមិឋាននៃជីវិត បុគ្គលណាមាននូវកតញ្ញូតាធម៌ បុគ្គលនោះគឺជាអ្នកមានគ្រឹះនៃជីវិតមាំទាំ ជីវិតរបស់គេ រមែងរុងរឿងខ្ពង់ខ្ពស់តទៅ ។ បុគ្គលណាខ្វះខាតនូវកតញ្ញូតាធម៌ ឈ្មោះថា ខ្វះខាតនូវគ្រឹះដ៏មាំទាំក្នុងជីវិត សូម្បីបុគ្គលនោះមានសេចក្តីល្អផ្សេងៗជាខាងក្រៅមួយរយមុខក៏ដោយ បើខ្វះខាតនូវកតញ្ញូតាធម៌ហើយ គឺមិនអាចរុងរឿងទៅបានយូរប៉ុន្មានឡើយ ។ ដូចអគារធំៗ ដែលគ្រឹះមិនមាំទាំដូច្នោះឯង សូម្បីតាក់តែងលម្អធ្វើឱ្យស្អាតស្រស់យ៉ាងណាក៏ដោយ ថ្ងៃណាមួយមិនយូរឡើយនឹងបាក់ស្រុតជាមិនខានមានអគារខ្លះសាងមិនទាន់ទាំងរួចផង ក៏ត្រូវស្រុតបាក់ទៅហើយ យ៉ាងណា មនុស្សដែលខ្វះខាតនូវកតញ្ញូតាធម៌ក៏ឈ្មោះថាខ្វះខាតនូវគ្រឹះមាំនៃជីវិតក៏ដូចគ្នាដែរ ។

ព្រោះដូច្នោះ ក្នុងករណីដែលយើងឃើញថា គេល្អគ្រប់យ៉ាង ហេតុដូចម្តេចបានជាមិនចម្រើននោះ គឺគេ



អាចមានការខ្វះខាតនូវអ្វីៗ ដែលយើងមិនអាចដឹង ឬមិនអាចមើលឃើញបាន ព្រោះថាគ្រប់យ៉ាងមិនអាចកើតឡើងបានឡើយ កាលណាបើខ្វះបច្ច័យគ្រប់គ្រាន់ ។

កតញ្ញូតាធម៌ ត្រូវឱ្យប្រព្រឹត្តទៅដល់បុព្វការីទាំងអស់ មិនចំពោះតែមាតាបិតានោះទេ គឺយើងមិនត្រូវរមិលគុណដល់អ្នកណាៗឡើយ សូម្បីតែអ្នកដទៃដែលធ្លាប់មានគុណបន្តិចបន្តួចយ៉ាងណាក៏ដោយ ដូចជាត្រឹមតែបាយមួយដុំ ទឹកមួយផ្តិលជាដើមដែលគេបានឱ្យដល់យើងដោយទឹកចិត្ត គឺយើងត្រូវចាំទុកថា នោះជាគុណបុណ្យដែលយើងគួររកឱកាសតបស្នងឱ្យបាន យ៉ាងហោចណាស់ក៏ម្តងដែរ យ៉ាងនេះ ទើបឈ្មោះថាជាមនុស្សល្អ ។

មនុស្សយើងគ្រប់គ្នា ក៏គួរតែនឹករលឹកមើលថា តើខ្វះខាតនូវចំណុចការដឹងគុណនេះដែរឬទេ កុំចេះតែសង្ស័យថាក្រែងធ្វើល្អមិនបានល្អនោះ ធ្វើជាមនុស្សត្រូវតែយល់ពីហេតុផល ។

## ៣-ការព្រមព្រៀងគ្នា

« **សុខា សង្ឃស្ស សាមគ្គី** ការព្រមព្រៀងគ្នា នៃពួកក្រុមនាំមកនូវសេចក្ដីសុខ » ។

នេះគឺព្រះពុទ្ធតម្រាស់ ដែលព្រះអង្គត្រាស់ជាង ២៥០០ ឆ្នាំហើយ ជាសេចក្ដីពិតរហូតមក និងរហូតទៅ ។

ការព្រមព្រៀងគ្នា នាំឱ្យសម្រេចនូវការងារដែលធ្វើគ្រប់យ៉ាង មិនថាការងារនោះជាការងារលំបាក ឬក៏ងាយស្រួលឡើយ ។ ការព្រមព្រៀងនេះត្រូវចាប់ផ្ដើមពីចិត្តទៅមុន រួចហើយត្រូវព្រមព្រៀងដោយវាចា ទីបំផុតត្រូវព្រមព្រៀងដោយកាយ តាមលំដាប់លំដោយដូច្នេះឯង ។

ការសាងនូវសេចក្ដីព្រមព្រៀងឱ្យកើតឡើងក្នុងពួកក្រុមនោះ ជារឿងដែលត្រូវសិក្សា ព្រោះមានរបៀបបែបបទព្រមទាំងឧបាយ និងវិធីផ្សេងៗច្រើនបែបច្រើនយ៉ាង ប៉ុន្តែដែលសំខាន់ក្នុងលំដាប់ដំបូង គឺត្រូវឱ្យសេចក្ដីសំខាន់



ដល់គ្នានិងគ្នា ។ យើងត្រូវមានការគិតថា មនុស្សយើងម្នាក់ៗសុទ្ធតែមាននូវសេចក្ដីសំខាន់រៀងៗខ្លួន ទោះបីសេចក្ដីសំខាន់នោះតិចខ្លាំងខុសគ្នាយ៉ាងណាក៏ដោយ ។

ការឱ្យសេចក្ដីសំខាន់ដល់គ្នានិងគ្នា ធ្វើឱ្យមនុស្សគ្រប់គ្នាសប្បាយចិត្តហើយមានកម្លាំងចិត្ត ព្រោះឃើញសេចក្ដីសំខាន់របស់ខ្លួនឯងថា ខ្លួនឯងក៏មាននូវយសសីរមានសេចក្ដីសំខាន់ក្នុងការរួមចំណែកក្នុងពួកក្រុមផងដែរ។ ផ្ទុយមកវិញ បើក្នុងពួកគណៈមានការមើលងាយ មើលថោកគ្នា មិនឱ្យសេចក្ដីសំខាន់ដល់អ្នកដទៃផង លើកតម្កើងតែខ្លួនឯង ឬបក្សពួករបស់ខ្លួន សង្កត់សង្កិន បន្តុះបង្អាប់ដល់អ្នកដទៃ ឬបក្សពួកអ្នកដទៃ គិតថាមានតែខ្លួនឯងប៉ុណ្ណោះដែលសមធ្វើជាអ្នកធំ អ្នកដទៃបានត្រឹមតែជាបរិវារប៉ុណ្ណោះ យ៉ាងនេះប្រាកដជាក្នុងពួកគណៈនោះៗមិនអាចឋិតនៅបានយឺនយូរឡើយ នឹងបែកបាក់គ្នាជាពុំខាន ឯការងារដែលរួមគ្នាធ្វើមកតាំងតែពីដំបូងនោះ ក៏មិនអាចបានសម្រេចដល់ទិសដៅឡើយ វាជាការដួលរលំ

ព្រោះបែកបាក់គ្នាហ្នឹងឯង ។

ដូច្នេះ យើងត្រូវចេះឱ្យសេចក្តីសំខាន់ដល់អ្នកដទៃផង ក្នុងពេលធ្វើការរួមគ្នា ហើយចាំសង្កេតមើលផលល្អចុះ ព្រោះអ្នកណាៗក៏មិនត្រូវការឱ្យខ្លួនអន់ថយដែរ គ្រប់គ្នាចង់មានមុខមាត់យសសីរ៍ ចង់បានទទួលការលើកតម្កើងឱ្យប្រាកដក្នុងពួកគណៈ ជាមួយគ្នាទាំងអស់នោះឯង ។

ជាបន្ទាប់មកទៀត គោលធម៌ដែលត្រូវអនុវត្តដើម្បីឱ្យពួកក្រុម និងការងាររបស់ពួកក្រុមនោះមានភាពឋិតថេរ គឺ **សារាណីយធម៌ ៦ ប្រការ** :

**១-មេត្តាកាយកម្ម** : ការសម្តែងចេញតាមផ្លូវកាយដោយមេត្តា មានការជួយគ្នាដោយកម្លាំងកាយ និងការសម្តែងអាកប្បកិរិយាសុភាពរាបសា គោរពរាប់អានគ្នាជាដើម ។

**២-មេត្តាវចីកម្ម** : ការសម្តែងចេញតាមផ្លូវវាចាដោយមេត្តា មានការប្រាប់ ការណែនាំ រំលឹក



ដាស់តឿនដោយបំណងល្អ និងពោលវាចាសុភាពដល់គ្នាជាដើម ។

**៣-មេត្តាមនោកម្ម** : ការគិតដល់គ្នាដោយមេត្តា មានការមើលគ្នាក្នុងផ្លូវល្អ គិតល្អដល់គ្នា គិតរកប្រយោជន៍ឱ្យបានសម្រេចដល់អ្នកដទៃ និងមានទឹកមុខស្រស់បស់ញញឹមសមរម្យជាដើម ។

**៤-សាធារណភោគី** : បែងចែកលាភដែលប្រកបដោយធម៌ បានមកតាមធម៌ ឱ្យដល់ពួកក្រុមជាទូទៅ ។

**៥-សីលសាមញ្ញតា** : មានការប្រព្រឹត្តសុចរិតស្មើគ្នាជាមួយអ្នកដទៃ មិនធ្វើខ្លួនឱ្យជាទីរង្កៀសដល់ពួកក្រុមឡើយ ។

**៦-ទិដ្ឋិសាមញ្ញតា** : មានការឃើញត្រូវរួមគ្នាជាមួយពួកក្រុម ប្រព្រឹត្តទៅរកការកម្ចាត់បង់នូវបញ្ហាផ្សេងៗ ។

ធម៌ទាំង ៦ យ៉ាងនេះ នាំឱ្យមានការនឹករលឹករកគ្នានិងស្រុះស្រួលគ្នា ជាការដើរឆ្ពោះទៅរកសេចក្តីសុខ

របស់ពួកក្រុម ។

ការព្រមព្រៀងគ្នា គឺជាការជួយគ្នាឱ្យសម្រេចនូវការងារ ដែលការងារនោះមិនអាចសម្រេចទៅបានដោយកម្លាំងយើងម្នាក់ឯងឡើយ ។ កាលណាបើការងារតូចធំបានសម្រេច យើងក្តី ពួកក្រុមក្តី សង្គមជាតិក្តី រមែងចម្រើនរុងរឿង ។

| | |
|---|---|
| ការព្រមព្រៀងគ្នានៃពួកក្រុម | ការងារតូចធំពុំលំបាក |
| បើបែកបាក់គ្នាទុក្ខឥតស្រាក | ស្រកេកស្រកាកការពុំស្រេច ។ |
| ប្រៀបដូចជាមគ្គអង្គប្រាំបី | នៅជាលោកីយ៍កាត់មិនដាច់ |
| ព្រោះមិនគ្រប់អង្គទើបមិនស្រេច | លោកុត្តរផ្តាច់ព្រោះព្រមព្រៀង។ |



## ៤-ត្រួតត្រារមើលខ្លួនឯង

ប្រក្រតីមនុស្សយើង ច្រើនតែសម្លឹងមើលអ្នកដទៃពិចារណាវែកញែកគ្នាពីអ្នកដទៃ និងច្រើនតែមើលឃើញកំហុសរបស់គេប៉ុណ្ណោះ ។ សភាពបែបនេះ ព្រោះមកអំពីគុណភាពរបស់ចិត្តក្នុងពេលសម្លឹងមើល ។ បើអ្នកសម្លឹងមានចិត្តលំអៀង ទៅក្នុងផ្លូវដែលមិនល្អស្រេចជាមុនហើយការសម្លឹង ក៏រមែងផៀងទៅរកតែចំណុចខ្វះខាតរបស់គេប៉ុណ្ណោះ គឺ មើលរំលងសេចក្តីល្អប្រសើររបស់គេទៅទាំងអស់ ។ ក្នុងការសម្លឹងមើលនេះ ប្រសិនបើមានចិត្តលំអៀងទៅក្នុងសេចក្តីស្រឡាញ់ ដោយមានការនិយមរាប់អានជាគ្នាឯងមកវិញនោះ ការសម្លឹងក៏រមែងផៀងទៅរកតែចំណុចល្អរបស់គេ សូម្បីចំណុចល្អនោះមានតិចក៏ឃើញច្រើន ហើយលើកយកមករៀបរាប់ពណ៌នាវែងឆ្ងាយឯចំណុចខ្វះខាតវិញសូម្បីមើលឃើញហើយ ក៏រំលងចោលទៅ មិនយកចិត្តទុកដាក់ឡើយ ។

ទោះជាការសម្លឹងមើលអ្នកដទៃ ដោយមិនលំអៀងយ៉ាងណាក៏ដោយ ក៏មិនប្រសើរដូចជាការសម្លឹងមើលខ្លួនឯងដែរ ។

ជាការពិត ដែលថាមានមនុស្សមិនតិចនាក់ មានការសប្បាយចិត្តក្នុងការចាំចាប់កំហុសអ្នកដទៃ ឬថាមានសេចក្តីសុខក្នុងការប្រជុំគ្នា និយាយនិន្ទាពីអ្នកនេះ ពីអ្នកនោះ ព្រមខាតពេលក្នុងការតាមដានរឿងរ៉ាវ ព្រមខ្វះពេលក្នុងការរង់ចាំមើលផលចាញ់ឈ្នះរបស់គេ ព្រមឱ្យពេលវេលាសម្លាប់ជីវិតរបស់ខ្លួន ដោយគ្រាន់តែប្តូរយកបាននូវការសប្បាយចិត្តបន្តិចបន្តួច ឬដោយគ្រាន់តែបានស្រណុកមាត់ក្នុងការនិយាយពីគេប៉ុណ្ណោះ ។ អ្នកណាយ៉ាងម៉េច អ្នកណាធ្វើអ្វី នៅឯណា គឺដឹងសព្វដឹងគ្រប់ល្អិតល្អន់ហ្មត់ចត់ ថែមទាំងចេះវែកញែកទៀតផង ថាវាគួរតែយ៉ាងនេះ វាគួរតែយ៉ាងនោះ គឺតាំងខ្លួនជាអ្នកជំនាញក្នុងគ្រប់រឿង ។

ក្នុងពេលដែលអង្គុយវែកញែកពីរឿងអ្នកដទៃនោះ



រឿងរបស់ខ្លួនឯងនិងរឿងក្នុងក្រុមគ្រួសាររបស់ខ្លួនក៏កំពុងតែនៅដោះស្រាយមិនចេញ នៅខ្វះខាតប្រាក់ ណាមួយអត់ការធ្វើ ឯប្តីប្រពន្ធខ្លួនឯងមិនសូវត្រូវគ្នា ។ល។ បញ្ហាទាំងអស់នេះត្រឡប់ជាមិនគិត មិនពិចារណារកការដោះស្រាយ រវល់តែទៅគិតរឿងអ្នកដទៃ ដែលមិនមែនជារឿងរបស់ខ្លួនឯងសោះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងឱ្យសម្លឹងមើលរឿងរ៉ាវរបស់ខ្លួនឯងឱ្យច្រើន តើអ្វីដែលខ្លួនឯងបានធ្វើហើយ និងអ្វីដែលខ្លួនឯងនៅមិនទាន់បានធ្វើ ។ ម្យ៉ាង-ទៀតត្រូវពិនិត្យមើលទោសកំហុស ឬចំណុចខ្វះខាតរបស់ខ្លួន ទោះជាលំបាកក្នុងការសម្លឹងមើលយ៉ាងណាក៏ដោយ ព្រោះជាធម្មតា ចិត្តរបស់យើងមិនងាយព្រមទទួលនូវការភ្លាំងភ្លាត់ ថាជាកំហុសរបស់ខ្លួនឯងឡើយ ។

ដើម្បីសេចក្តីចម្រើននៃខ្លួនឯង យើងត្រូវតែព្យា-យាមពិចារណា ពេលពិចារណាឃើញទោសកំហុសរបស់ខ្លួនហើយ ក៏ជាភ័ព្វសំណាង ព្រោះយើងនឹងបានកែតម្រូវ

ឱ្យបានល្អវិញ ។ អ្នកដែលសម្លឹងឃើញការខ្វះខាតរបស់ខ្លួនឯងបាន រាប់ថាជាមនុស្សប្រសើរ ហើយបើព្រមទទួលការភ្លាំងភ្លាត់ដែលជាទោសកំហុសនោះ ថែមទាំងអាចកែលម្អខ្លួនឱ្យដល់នូវសេចក្ដីសង្រួមតទៅទៀតបាន គឺចាត់ថាជាកំពូលមនុស្សរកបានដោយកម្រក្នុងលោក ។

មានចោរពីរនាក់ដើរចូលទៅក្នុងវត្ត ចោរម្នាក់ភ្ញាក់ខ្លួនឃើញកំហុស ខំប្រឹងស្ដាប់ធម៌បានទៅជាមនុស្សដ៏ល្អ ឯចោរម្នាក់ទៀតលួចទ្រព្យគេពីវត្តបានមក ។ ចោរដែលនៅតែជាចោរនោះ បានបន្ទោសស្តីថាឱ្យដល់ម្នាក់ទៀតដែលឈប់ធ្វើជាចោរថាជាមនុស្សល្ងង់ខ្លៅ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា « បុគ្គលណា ល្ងង់ហើយដឹងខ្លួនឯងថាល្ងង់ បុគ្គលនោះ អាចនឹងបានជាបណ្ឌិត ឯបុគ្គលណា ល្ងង់តែសម្គាល់ខ្លួនថាជាបណ្ឌិត បុគ្គលនោះ ពិតជាបុគ្គលល្ងង់ ព្រោះមិនព្រមរៀនដឹងពីអ្នកដទៃ ដោយគិតថាខ្លួនឯងឆ្លាតហើយ ដូច្នោះគេទើបជាបុគ្គលល្ងង់រហូតទៅ » ។



## ៥-ឈ្លោះនិងសុខ

នៅក្នុងសង្គមគ្រួសារនីមួយៗ តែងមានសុខមានទុក្ខលាយឡំគ្នា ទាំងដែលគ្រប់គ្នាក្នុងក្រុមគ្រួសារមិនប្រាថ្នាទុក្ខ ប្រាថ្នាតែសេចក្ដីសុខហ្នឹងឯង ។

ចាប់តាំងអំពីមានគំនិតគ្រប់គ្រងផ្ទះមក រហូតដល់រៀបការមានគ្រួសារប្ដីប្រពន្ធកូនចៅ ម្នាក់ៗខំធ្វើការសន្សំទ្រព្យ ដោយបោះបង់ចិត្តខ្លួនឯងចោល ខ្វះការអប់រំទូន្មានធ្វើឱ្យចិត្តមានតែការស្រេកឃ្លាន រហេមរហាម សៅហ្មងស្មោកគ្រោក មានរោគរួបរឹត រីងរៃរ៉ុាំរ៉ៃ កំព្រឹកំព្រា រងាតែលតោល ។ ដូចពោលមកនេះ ឈ្មោះថា បោះបង់ខ្លួនឯងចោលដោយពិត ហើយមិនបានចេះគិតអាណិតខ្លួនឡើយ ព្រោះមានសេចក្ដីដឹងខ្លួនថា ខ្លួនបានប្រឹងប្រែងជួយខ្លួនឯងទៅហើយ ដោយការខំស្វែងរកទ្រព្យសម្បត្តិតែម្យ៉ាង ។

ការរស់នៅជាមួយអ្នកដទៃ សូម្បីក្នុងក្រុមគ្រួសារ

តើយើងត្រូវការយកឈ្នះគ្នា ឬក៏ត្រូវការសេចក្តីសុខ ?

តាមពិត សេចក្តីសុខជាទិសដៅប្រាថ្នានៃមនុស្ស យើងគ្រប់គ្នា ពាក្យថា « សុភមង្គល » ក៏ជាឈ្មោះនៃ សេចក្តីសុខនេះដែរ ឯសេចក្តីសុខដ៏សំខាន់នៃជីវិត គឺ សុខចិត្ត ។

សេចក្តីសុខមានហេតុច្រើនប្រការ ត្រូវចាំថាមិន មែនមានទ្រព្យជាមហាសេដ្ឋីហើយ បានសុខគ្រប់យ៉ាង នោះទេ ហើយក៏មិនមែនទាល់តែជាអ្នកមានទ្រព្យសម្បត្តិ ច្រើន ទើបអាចរកសេចក្តីសុខឱ្យខ្លួនឯងនិងអ្នកដទៃបាន នោះដែរ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា « សម្លាប់ សេចក្តីក្រោធបានរមែងដេកនៅជាសុខ » នេះជាការពិត ដែលយើងគ្រប់គ្នាត្រូវចាំកុំភ្លេច ហើយត្រូវបដិបត្តិកម្ចាត់ ការខឹងក្រោធបន្តិចម្តង១ យើងត្រូវតែយល់ដឹងដូចតទៅ នេះគឺ :

-ខឹងនឹងគេ គឺដុតចិត្តខ្លួនឯង បើយើងដុតចិត្តខ្លួន



ឯង យើងហ្នឹងឯងល្ងង់ហើយឆ្កួតទៀត ។

-ខឹងនឹងគេ គឺអន់ជាងគេ គឺអន់ថយជាងអ្នកដែល យើងខឹងនោះទៅទៀត ដូចជាលុតជង្គង់អង្វរសូមសេចក្តី សុខពីគេអ៊ីចឹង ។

-ខឹងនឹងគេ គឺចាប់ផ្តើមពីការទាស់ចិត្ត ការទាស់ ចិត្តមកពីគិតថា គេហ្នឹងឯងជាអ្នកធ្វើនូវអ្វី១ឱ្យយើងទាស់ ចិត្ត តែការពិត មកពីយើងមិនយល់អំពីធម្មជាតិក្នុងមនុស្ស ហើយយើងប្រកាន់ខុសទៅក្នុងធម្មជាតិនោះឯង ។

-យើងស្អប់គេ គឺស្អប់ខ្លួនឯង ព្រោះសាងភាព សៅហ្មងឱ្យប្រឡាក់ចិត្តខ្លួនឯងតែប៉ុណ្ណោះ ដោយមិនបាន ឱ្យភាពសៅហ្មង គឺការស្អប់នោះចូលទៅក្នុងខ្លួនអ្នកដទៃ ឡើយ ។ ដូច្នេះ បើយើងពិតជាស្រឡាញ់ខ្លួនឯងមែន ត្រូវ ព្យាយាមរក្សាចិត្តរបស់ខ្លួនកុំឱ្យសៅហ្មងឡើយ ។

-អ្នកដទៃធ្វើល្អមិនបាន ព្រោះមកអំពីមហាកុសល មិនបានកើតឡើងក្នុងចិត្តរបស់គេ មិនមែនមកពីគេមិនធ្វើ ល្អឱ្យយើងទេ ។ អ្វី១មានហេតុមានបច្ច័យទើបកើតឡើង។

ដូច្នេះ យើងត្រូវយល់ថា អ្នកដទៃធ្វើល្អឱ្យខ្លួនគេមិនបាន ផង មានរឿងអ្វីដែលគេមកធ្វើល្អឱ្យយើងបាន ។

-អ្នកណាៗ ដែលធ្វើអំពើមិនល្អ និយាយអាក្រក់ គិតអាក្រក់ក្នុងលោកនេះនោះ តាមពិត ដោយធម្មជាតិគឺ មិនមែនអ្នកនោះធ្វើ និយាយ និងជាអ្នកគិតនោះទេ នេះ ព្រោះអាស្រ័យហេតុ ៣ ដែលស្ថិតនៅក្នុងសន្តានតែ ប៉ុណ្ណោះ ។ ហេតុ ៣ គឺ លោភហេតុ ទោសហេតុ និង មោហហេតុ ។ បើហេតុ ៣ នេះត្រូវបានលះអស់ពីចិត្ត សន្តានហើយ គឺមិនមានអ្នកណាធ្វើអាក្រក់សោះឡើយ ។ ហេតុទាំង ៣ នេះឯង ដូចជាខ្មោចបិសាចដែលស្ថិតនៅ ក្នុងខ្លួនមនុស្សយើងអ៊ីចឹង ។ ដូច្នេះ យើងមិនត្រូវក្រោធ ខឹងជាមួយមនុស្សណាម្នាក់ឡើយ ។

-បើយើងមិនក្រោធខឹងហើយ គឺយើងហ្នឹងឯង មាននូវសេចក្តីសុខ ។ សេចក្តីសុខក្នុងការមិនក្រោធខឹង នេះ ព្រោះបានយល់ដឹងពីធម្មជាតិ ព្រោះមានអំណត់ អត់ធន់ និងព្រោះមានមេត្តាជាដើម គឺជាបុណ្យបារមីដ៏



ប្រសើរខ្ពង់ខ្ពស់ ។ បើសម្លាប់សេចក្តីក្រោធហើយ ក្នុង លោកនេះមិនមានអ្នកណាសម្រាប់ឱ្យយើងសម្លាប់ ឬ សូម្បីគ្រាន់តែស្អប់នោះឡើយ ។ អ្វីៗជុំវិញជីវិតរស់នៅ មានតែភាពមនោរម្យ ហាក់ដូចជាវិមានក្នុងព្រហ្មលោក ។

រឿងក្នុងគ្រួសារការសុបិន មានឆៅមានឆ្អិនគួរជិនណាយ
មានទុក្ខកង្វល់ពុំរសាយ លុះដល់ឃ្លាតឆ្ងាយបែរអាល័យ។
ចិត្តជាប់ជំពាក់ក្នុងកាមគុណ មានទុក្ខទារុណធ្ងន់ពេកក្រៃ
ប្រយោជន៍បាត់បង់តាមយប់ថ្ងៃ កាមគុណឧបមេយ្យបីដូចចោរ។

## ៦_ឈ្នះនិងសុខ (ត)

ការប្រកួតកីឡា គេបានឈ្នះហើយ គេសប្បាយ ឯការបោះឆ្នោត បើមានអ្នកគាំទ្រភាគច្រើន គឺត្រូវឈ្នះ ហើយបានធ្វើជាអ្នកធំ ។

នៅក្នុងគ្រួសារ ជារឿងមនោសញ្ចេតនានៃមាតាបិតា ភរិយាស្វាមី កូនប្រុសស្រី ។ល។ ដូច្នេះ មិនមែនជារឿងប្រកួតប្រជែង និងមិនមែនចេះតែប្រកាន់យកមតិភាគច្រើននោះទេ ។ ម្នាក់ៗមានតួនាទីរៀងៗខ្លួន ត្រូវចេះគោរពតួនាទីរបស់ខ្លួន មានការអ្វីៗត្រូវពិគ្រោះពិភាក្សា មេគ្រួសារជាអ្នកសម្រេចក្នុងកិច្ចការងារ ប៉ុន្តែ ការសំខាន់គឺម្នាក់ៗត្រូវមានធម៌ក្នុងខ្លួន ។

មានធម៌ក្នុងខ្លួន ទើបអាចបណ្តេញអធម៌ឱ្យចេញពីខ្លួនបាន នេះជាការយកឈ្នះខ្លួនឯង ហើយគ្រប់គ្រងខ្លួនដោយសតិសម្បជញ្ញៈ ។



មានធម៌ក្នុងខ្លួនឈ្មោះថា មានខ្លួនជាទីពឹង និងមានសុខក្នុងខ្លួនឯង ដោយមិនវង្វេងស្វែងរកសុខក្នុងវត្ថុដទៃ មនុស្សដទៃជាខាងក្រៅឡើយ ។

មានធម៌ក្នុងខ្លួន នាំឱ្យមិនកើតទុក្ខជាមួយនឹងរឿងគ្រប់យ៉ាង គឺទាន់ពេលភ្លាមៗ ដែលបានទទួលដឹងនូវរឿងនោះឯង ។ ការមិនកើតទុក្ខ គឺជាសុខដ៏វិសេសស្រេចតែម្តង ដោយការស្ងប់តណ្ហា ។

មានធម៌ក្នុងខ្លួន ទើបដឹងថាបញ្ហាមិនមែនអ្នកដទៃធ្វើឱ្យខ្លួនឯងទេ គឺបញ្ហានៅក្នុងចិត្តរបស់ខ្លួន ព្រោះតែសេចក្តីប្រកាន់ ។ ការមិនប្រកាន់ជាសុខដ៏ក្រៃលែង ។

មានធម៌ក្នុងខ្លួន នាំឱ្យមិនប្រកាន់ទៅក្នុងរឿងទាំងពួង ព្រោះបានដឹងអំពីធម្មជាតិតាមសេចក្តីពិត ។ ក្នុងជីវិតមនុស្ស សត្វទាំងអស់គឺជាធម្មជាតិ មានរូបធាតុ មាននាមធាតុ ប្រព្រឹត្តទៅតាមហេតុ ។

មានធម៌ក្នុងខ្លួន នាំឱ្យយល់ដឹងអំពីធម្មជាតិគ្រប់យ៉ាងថា « មិនគួរប្រកាន់មាំឡើយ » ។ ធម្មជាតិរមែង

តែងតែកើតឡើងហើយវិនាសទៅវិញ គឺការវិនាសប្រែប្រួលជាម្ចាស់លើធម្មជាតិ ។

មានធម៌ក្នុងខ្លួន នាំឱ្យមានចិត្តទំនេរមិនមានកង្វល់ក្នុងការហួងហែងជីវិត ហួងហែងបញ្ចក្ខន្ធឡើយ ។ ការមិនកង្វល់ និងការមិនប្រកាន់ទើបជាទីពឹងពិតក្នុងជីវិតនិងក្នុងព្រះពុទ្ធសាសនា ។

មានធម៌ក្នុងខ្លួន ទើបដឹងថា សេចក្តីសុខមិនមែននៅលើការយកឈ្នះអ្នកដទៃនោះទេ គឺសេចក្តីសុខរមែងមានហេតុនៃសេចក្តីសុខដោយឡែកផ្សេង មានដូចនេះជាដើមគឺ :

-សុខព្រោះមិនបៀតបៀនអ្នកដទៃ

-សុខព្រោះសន្សំសេចក្តីល្អ

-សុខព្រោះការព្រមព្រៀងគ្នា

-សុខព្រោះមានបញ្ញាយល់ដឹងការពិត

-សុខព្រោះការមិនក្រោធខឹង

-សុខព្រោះការមិនប្រកាន់



-សុខព្រោះការឱ្យអភ័យ

-សុខព្រោះការមិនយកទុក្ខមកដាក់ខ្លួន

-សុខព្រោះការបានឈ្នះខ្លួនឯង ។

រឿងរ៉ាវនៅក្នុងក្រុមគ្រួសារ ពេលខ្លះគឺមិនអាចនាំយកហេតុផលមកជជែកគ្នាបានឡើយ ព្រោះរឿងរ៉ាវវានៅពីលើហេតុផលដែលយើងចង់និយាយទៅទៀត ដូច្នេះមានតែការសម្រួល មានតែសម្បទាន និងការយល់ដឹងអំពីសេចក្តីពិតហើយព្រមទទួលប៉ុណ្ណោះ ទើបវាជាការល្អ ។

មានការបែកបាក់គ្នាច្រើនណាស់ គឺមកអំពីការប្រកាន់ហេតុផលរៀង១ខ្លួន ចង់យកឈ្នះគ្នា ដោយអាងហេតុផលដែលខ្លួនមាន ដោយប្រកាន់ថាហេតុផលរបស់ខ្លួនត្រឹមត្រូវ ឯម្ខាងទៀតមិនមានហេតុផលអ្វីឱ្យត្រឹមត្រូវឡើយ ម្ល៉ោះហើយទីបំផុតចុងក្រោយក៏ត្រូវបែកគ្នា ។ ហេតុផលគឺពិតជារបស់ល្អហើយ តែត្រូវប្រើឱ្យសមជាមួយគ្នានឹងករណីព្រមទាំងពេលវេលាផង ។

សរុបសេចក្តីមក បើមានការភ្លាំងភ្លាត់អ្វី កុំចេះតែ

មកបន្ទោសគ្នា ប្រកែកគ្នា ត្រូវមានគុណធម៌ប្រចាំចិត្ត សម្រាប់ដោះស្រាយនូវបញ្ហានោះ ។ ។

រឿងក្នុងគ្រួសារការសម្តែង ដូចល្ខោនគេតែងលេងប្រឌិត
គួរកុំប្រកាន់ល្ខោនជីវិត សិក្សាការពិតបរមត្ថធម៌ ។
អ្វីៗបីដូចជាខ្ទីគេ ដូចផ្លឹងទទេតែបិទជរ៉ំ
កាមគុណបីដូចការតាំងគភ៌ ញាប់ញ័រប្រសូតសោយសោកា។
ទ្រទ្រង់គុណធម៌សាងក្តីស្ងប់ បានអ្វីគ្រប់សព្វចប់តណ្ហា
អស់ទុក្ខកង្វល់អស់ប្រាថ្នា លែងសោយសោកាសុខពិតហោង។



## ៧-វាសនាបារមី

វាសនាបារមី យើងបានយល់ដឹងជាទូទៅថា បើអ្នកណាមានហើយ នឹងជាមនុស្សសម្បូណ៌ទៅដោយសេចក្តីសុខ លាភយស និងឋានៈមុខនាទី ។ មនុស្សដែលមានវាសនាបារមីល្អ រមែងជាទីរាប់អាន គោរពស្រឡាញ់របស់មនុស្សគ្រប់ជាន់គ្រប់ថ្នាក់ បើមានបុគ្គលណាប៉ងប្រទូសរ៉ាយ ឬច្រណែនឈ្នានីសគិតផ្តួលរំលំ រមែងប្រព្រឹត្តទៅមិនបានឡើយ ត្រឡប់បែរទៅជាចាញ់ខ្លួនឯងវិញ ។

វាសនាបារមីនោះ សំដៅដល់សេចក្តីល្អដែលបានសន្សំទុកមកយូរហើយ រហូតក្លាយជាបុណ្យបារមីដែលសម្បូណ៌ពេញទី អាចតបស្នងផលឱ្យដល់អ្នកធ្វើ បានសម្រេចតាមប្រាថ្នា ។

មនុស្សយើងអាចសាងបំពេញនូវវាសនាបារមីនោះបាន គឺធ្វើឱ្យកើតមានក្នុងខ្លួន ដោយបដិបត្តិចម្រើនគុណធម៌ ៣ ប្រការ :

**១-បុព្វេកតបុញ្ញតា** ភាពជាអ្នកមានបុណ្យបានធ្វើទុកក្នុងកាលមុន ។ ពាក្យថា « មុន » ក្នុងទីនេះមាន ២ ផ្នែកគឺ ក្នុងជាតិមុនៗ និងក្នុងជាតិនេះឯង ។ បុណ្យដែលបានធ្វើក្នុងជាតិមុនៗ ដូចជា ធ្លាប់ឱ្យទានមកច្រើន ធ្លាប់រក្សាសីលបានបរិសុទ្ធ ធ្លាប់អប់រំចិត្តបានល្អជាដើម ដូច្នេះ រមែងតបស្នងឱ្យអ្នកធ្វើតាំងតែអំពីបដិសន្ធិ ដូចជាកើតក្នុងត្រកូលខ្ពង់ខ្ពស់ មានសម្បត្តិច្រើន កើតមកមានរូបរាងល្អ មានប្រាជ្ញាឈ្លាសវៃជាដើម ជាប្រភេទមនុស្សអ្នកមានបុណ្យបារមីមកកើត ។ ចំណែកបុណ្យដែលបានធ្វើក្នុងថ្ងៃមុនៗក្នុងជាតិនេះនោះ សំដៅដល់ការដែលបានកើតមកជាមនុស្សហើយ មិនបានប្រមាទក្នុងជីវិត តាំងចិត្តធ្វើសេចក្តីល្អផ្សេងៗ ចេះប្រយ័ត្នប្រយែង និងឧស្សាហ៍ព្យាយាម ។

មនុស្សដែលមានបុណ្យបានធ្វើទុកមកទាំងពីរផ្នែក គឺទាំងសេចក្តីល្អក្នុងជាតិមុន និងសេចក្តីល្អក្នុងជាតិនេះ បុណ្យវាសនាបារមីនោះឯង រមែងធានារ៉ាប់រងជីវិតក្នុង



ការធ្វើឱ្យជីវិតឈានទៅដល់សេចក្តីសម្រេច ។

**២-សប្បុរិសូបសំសេវ** ការបានចូលទៅសេពគប់ជាមួយនឹងសប្បុរស ។ គុណធម៌ទី ២ នេះ ដោយអាស្រ័យបាននៅក្នុងប្រទេសដ៏សមគួរ គឺប្រទេស ឬកន្លែងដែលមានសប្បុរស នេះជាគុណធម៌ដ៏សំខាន់ក្នុងបច្ចុប្បន្នជាតិ ព្រោះការសេពគប់នឹងសប្បុរសនាំឱ្យបានស្តាប់នូវព្រះធម៌ ដែលជាប្រទីបបំភ្លឺប្រាប់អំពីការពិតនៃជីវិត ។ ការបានស្តាប់ព្រះធម៌នាំមកនូវបញ្ញា ដែលជាការជ្រោមជ្រែងដល់វាសនាបារមីដ៏សំខាន់បំផុត ។

**៣-អត្តសម្មាបណិធិ** ការតម្កល់ខ្លួនដោយប្រពៃ ។ គុណធម៌ទី ៣ នេះ បានដល់ការប្រព្រឹត្តបដិបត្តិល្អ គឺជាមនុស្ស ដែលប្រកាន់យកនូវគុណធម៌ជាសម្បត្តិដ៏មានតម្លៃបំផុតក្នុងជីវិត ។ មនុស្សយើងពិតមែនតែមានបុណ្យវាសនាចាស់បានសាងទុកមក តែបើបច្ចុប្បន្នជាមនុស្សប្រមាទឡេះឡោះ ប្រព្រឹត្តតែអំពើថោកទាបផ្សេងៗ បុណ្យវាសនាដែលបានសាងពីមុននោះ រមែងកប់បាត់ មិន

បានឱ្យផលសម្រេចឡើយ ។ ផ្ទុយមកវិញ បើវាសនាបារមីចាស់ដែលបានសាងមក ពុំសូវសម្បូណ៌យ៉ាងណាក៏ដោយ តែបច្ចុប្បន្នបានប្រព្រឹត្តល្អ បដិបត្តិដោយប្រពៃ តម្កល់ខ្លួនក្នុងសទ្ធា សីល សុតៈ ចាគៈ និងបញ្ញា មិនញាប់ញ័រទៅតាមអំណាចនៃវត្ថុញុះញង់ក្នុងលោក រមែងធ្វើឱ្យមានវាសនាបារមីដល់ព្រមដោយសព្វគ្រប់ ។

សរុបសេចក្តីមក គ្រប់គ្នាមានឱកាសបំពេញវាសនាបារមី ។ ប្រសិនបើគុណធម៌ទី ១ មិនបានបំពេញ ព្រោះកាលដែលកន្លងទៅ ត្រូវសេចក្តីប្រមាទគ្របសង្កត់ តែមនុស្សយើង អាចបំពេញបាននូវគុណធម៌ទាំងពីរប្រការចុងក្រោយ គឺអាចធ្វើបានក្នុងជាតិនេះ ។

ក្មេងចេញពីស្រុកស្រែមក បានជារដ្ឋមន្ត្រី មនុស្សដែលរត់ពីស្រុកក្រៅមក មានខោអាវតែមួយចង្កេះ អាចបានជាសេដ្ឋី មនុស្សអ្នកបម្រើគេ អាចបានជាព្រះរាជាទាំងអស់នេះមានមកជាហូរហែ ជាការបញ្ជាក់ប្រាប់អំពីបុណ្យវាសនាបារមីរបស់មនុស្សយើង ។



## ៨.មុទិតាចិត្ត

មុទិតាចិត្ត បានដល់ចិត្តដែលប្រកបដោយភាពទន់-ភ្លន់ រីករាយត្រេកអរក្នុងពេលដែលអ្នកដទៃបានល្អ ឬបានទទួលនូវសេចក្តីសម្រេចយ៉ាងណាមួយ គឺជាអាការនៃសភាវៈដែលកើតឡើងក្នុងចិត្ត ព្រោះប្រាសចាកនូវការច្រណែន ។ មុទិតាចិត្ត ជាចិត្តកើតមានក្នុងបុគ្គលដែលមានប្រក្រតីព្រមទទួលនូវផលសម្រេច ឬសេចក្តីល្អរបស់អ្នកដទៃ ។

គុណធម៌មួយនេះ មិនមែនកើតឡើងបានដោយងាយៗឬចេះតែកើតបានក្នុងគ្រប់មនុស្សនោះឡើយ ព្រោះជាប្រក្រតីធម្មតានៃមនុស្សទូទៅ ច្រើនតែមិនព្រមទទួលនូវសេចក្តីល្អរបស់អ្នកដទៃ មិនទន់ភ្លន់ចិត្តនៅពេលដែលអ្នកដទៃបានទទួលនូវការសរសើរ ឬបានលាភបានយសខ្ពស់ជាងខ្លួន ជាពិសេសចំពោះអ្នកដែលខ្លួនមិនពេញចិត្តនិងកំពុងតែប្រៀបផ្ទឹមគ្នា ។

មនុស្សដែលមានមុទិតាចិត្ត គឺជាមនុស្សពិសេស ខ្ពង់ខ្ពស់ ជាមនុស្សរស់នៅជាមួយនឹងសេចក្ដីសុខរបស់ខ្លួន មានចិត្តប្រសើរខ្ពស់ជាងមនុស្សសាមញ្ញធម្មតា មានចិត្តទូលាយ ព្រមទទួលយកសេចក្ដីល្អរបស់អ្នកដទៃ និងមានចិត្តរីករាយស្មើជានិច្ចបីដូចជាព្រះព្រហ្ម ។ មុទិតាជាព្រហ្មវិហារធម៌ ១ ជាជម្រកដ៏ប្រសើររបស់ចិត្ត មិនងាយនឹងកើតឡើងឡើយ លុះត្រាតែហ្វឹកហាត់អប់រំដោយការតាំងចិត្តមាំ ប្រកបដោយបញ្ញាយល់ដឹង ។

ការអប់រំមុទិតាចិត្តឱ្យចម្រើនជាប្រក្រតី ត្រូវកម្ចាត់នូវសត្រូវដ៏សំខាន់របស់មុទិតា គឺ « អរតិ » ឱ្យបានជាដាច់ខាត ។ អរតិ បានដល់សេចក្ដីមិនត្រេកអរ ព្រោះឥស្សាការច្រណែនកើតឡើងហ្នឹងឯង ។ ដើម្បីកម្ចាត់នូវអរតិនេះ ត្រូវពិចារណាអំពីហេតុផលនៃជីវិត ព្រោះអ្វីៗក្នុងជីវិតសុទ្ធតែមានហេតុមានផល ។ អ្នកដទៃបានលាភ បានយស បានការសរសើរការគោរពរាប់អាន គឺសមគួរនឹងបានពិតហើយ មិនមានភាពអយុត្តិធម៌ក្នុងច្បាប់ហេតុ



ផលនេះឡើយ ។

អរតិជាបាបធម៌ម្យ៉ាងដែលបាំងចិត្តបិទបញ្ញា មិនឱ្យមានការទទួលខុសត្រូវចំពោះអ្វីដែលល្អពិត និងអ្វីដែលអាក្រក់ពិតនោះឡើយ ធ្វើឱ្យត្រេកអរនឹងគេមិនបាន សរ-សើរគេមិនកើត សម្លឹងមើលអ្នកដទៃក្នុងផ្នែកល្អក៏មិនបានដែរ មានតែគំនិតទម្លាយសេចក្ដីល្អរបស់គេ ដោយការពោលទោស ផ្សំរឿងមិនល្អ និងចោទប្រកាន់ផ្សេងៗឱ្យដល់អ្នកដទៃនោះៗ ឯសេចក្ដីល្អព្រមទាំងគុណរបស់គេប្រៀបបាននឹងភ្នំធំ បែរជាមើលមិនឃើញ នេះគេហៅថាមនុស្សចិត្តខ្វាក់ ។

ដើម្បីសេចក្ដីសុខទាំងខ្លួនឯង ទាំងអ្នកដទៃ មនុស្សយើងត្រូវសាងមុទិតាចិត្ត ឱ្យកើតឡើងជំនួសកន្លែងឥស្សាដោយការព្យាយាមសម្លឹងរកសេចក្ដីល្អរបស់អ្នកដទៃ សូម្បីតែសេចក្ដីល្អនោះបន្តិចបន្តួចក៏ដោយ ។ ត្រូវហាត់យកសេចក្ដីល្អរបស់គេដែលមាន សូម្បីបន្តិចបន្តួចមកសរសើរទោះបីមុនដំបូងមានការលំបាកនឹងនិយាយ ក៏ត្រូវតែ

ព្យាយាមដែរ យូរៗទៅក្លាយជាទម្លាប់ហើយអាចនិយាយបានច្រើនទៀតផង។ កាលជំនាញក្នុងការនិយាយសរសើរសេចក្ដីល្អរបស់គេហើយ ត្រូវឱ្យចេះសម្ដែងនូវសេចក្ដីត្រេកអរចំពោះទៅរកសេចក្ដីសម្រេចខ្លះៗ របស់អ្នកដទៃចាប់ផ្ដើមតាំងពីមនុស្សក្នុងគ្រួសារទៅមុន ពង្រីកទៅរកញាតិមិត្ត តទៅដល់អ្នករួមការងារជាដើម ។ ដូច្នេះឯងមិនយូរឡើយមុទិតាក៏នឹងកើតឡើងពេញនៅក្នុងចិត្ត ភាពក្ដុកក្ដួលរំជើបរំជួល ជំងឺក្នុងចិត្ត ព្រោះការច្រណែនក៏រមែងស្ងប់រម្ងាប់ទៅ ។

មុទិតាធម៌ ជាថ្នាំដ៏វិសេសដែលធ្វើឱ្យមនុស្សយើងញញឹមញញែមរកគ្នា គប់រកគ្នាដោយស្និទ្ធស្នាល ជាសោមាសចាក់ចិត្តគ្នាប្រកបដោយសុខ និងចម្រើនអស់កាលជានិច្ច ដែលផ្ទុយពីឥស្សាការច្រណែន ជាសស្ត្រាវុធសម្រាប់កាត់ចំណងមិត្តភាព និងជាតួទម្លាយនូវប្រយោជន៍គ្រប់យ៉ាងក្នុងលោក ។



## ៩-លក្ខណៈមនុស្សពូកែ

មនុស្សយើងពូកែផ្សេងៗគ្នា ខ្លះពូកែខ្លាំង ខ្លះពូកែល្មម ខ្លះពូកែច្រើនមុខ ខ្លះពូកែតែមួយមុខ ។ ភាពខ្លាំងពូកែរបស់មនុស្សយើងនេះឯង ដែលធ្វើឱ្យមនុស្សយើងអាចរស់នៅបាន ព្រោះយកភាពខ្លាំងពូកែរបស់ខ្លួននោះមកប្រើក្នុងការប្រកបអាជីវកម្ម ចិញ្ចឹមជីវិតព្រមទាំងក្រុមគ្រួសារ ។ អ្នកណាពូកែខ្លាំង អ្នកនោះក៏បានផលតបស្នងច្រើន អ្នកណាពូកែល្មម អ្នកនោះក៏បានផលថយចុះទៅតាមភាពពូកែរបស់ខ្លួននោះ ៗ ។

មនុស្សល្អ មានលក្ខណៈសំគាល់នៅត្រង់ការដឹងគុណ និងតបគុណ យ៉ាងណា មនុស្សពូកែក៏មានលក្ខណៈជាគ្រឿងសំគាល់ យ៉ាងនោះដែរ ។ លក្ខណៈរបស់មនុស្សពូកែ ក៏គឺ « ការងារ » ហ្នឹងឯង ។

នៅក្នុងមង្គលសូត្រ ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ត្រាស់សម្ដែងថា « សិប្ប » ជាមង្គលដ៏ឧត្ដម ១ ក្នុង

មង្គល ៣៨ ប្រការ ។ សិប្ប គឺជាសិល្បៈ បានដល់ស្នាដៃដែលសម្តែងចេញមកអំពីការចេះដឹង បញ្ជាក់អំពីសមត្ថ-ភាពដែលខ្លួនមាន ។ មនុស្សដែលមានសិល្បៈ គឺជាមនុស្សដែលមានស្នាដៃក្នុងការងារ មិនថាការងារនោះត្រូវប្រើដៃប្រើជើង ឬប្រើមាត់ឡើយ សុទ្ធតែអាចហៅបានថា ជាមនុស្សមានស្នាដៃទាំងអស់ ។ មនុស្សដែលមានស្នាដៃធ្វើការងារបានល្អ បញ្ចេញនូវសមត្ថភាព និងចំណេះដឹងឱ្យប្រាកដ ចាត់ថាជាមនុស្សពូកែក្នុងទីនេះ ។

មនុស្សដែលមានការចេះដឹង និងចងចាំបានច្រើន លោកហៅថា ពហុស្សូត ប៉ុន្តែ ពហុស្សូតនោះ ប្រសិនបើនៅមិនទាន់បញ្ចេញស្នាដៃមកទេ គឺមិនទាន់ធ្វើការងារឱ្យប្រាកដ ក៏នៅមិនទាន់ចាត់ថាជាមនុស្សពូកែក្នុងសិល្បៈដែរ ព្រោះសិល្បៈនោះ ត្រូវសម្តែងបញ្ចេញមកឱ្យគេដឹងបាន គឺសម្រេចបានមកជាកិច្ចការងារ ទាំងដែលជាការងារប្រាសចាកទោសទៀតផង ទើបជាមង្គលដ៏ឧត្តម ។

តាមប្រក្រតីនៃមនុស្សភាគច្រើន ដែលមានស្នាដៃ



គឺមនុស្សដែលបានរៀនសូត្រពូកែមកហ្នឹងឯង ព្រោះបានប្រើនូវចំណេះដឹងដែលមាន ឱ្យសម្រេចជាការងារមានស្នាដៃល្អ ។ ការងារដែលចាត់ជាសិល្បៈនោះ មានច្រើនបែប ដូចជាការសរសេរ ការនិយាយ ការសម្តែងដោយកាយ និងការងារជាប្រយោជន៍ច្រើនទៀតសម្រាប់សង្គមទូទៅ ។ អ្នកណាស្ទាត់ផ្នែកណា និងធ្វើបានល្អជាពិសេស ក៏ជាមនុស្សពូកែទៅតាមនោះ ។ បើរឹងរឹតតែខ្លាំងពូកែ រហូតដល់អ្នកដទៃធ្វើមិនបាន ឬថាពូកែដាច់ទៅតែម្នាក់ឯង ដូច្នេះកេរ្តិ៍ឈ្មោះ កិត្តិយស រួមទាំងលុយកាក់ក៏រមែងហូរចូលមក ។ ភាពខ្លាំងពូកែនៃមនុស្សម្នាក់ៗ ទាំងប្រកបដោយសីលធម៌ផងនោះ គឺជាអណ្តូងកើតនៃសេចក្តីចម្រើនឈានទៅមុខ ។

ដើម្បីឱ្យបានជាមនុស្សពូកែ ត្រូវរៀនផងធ្វើផងព្រមដោយកុសលឆន្ទៈ គឺពេញចិត្តនឹងធ្វើនូវការងារដែលប្រាសចាកទោស ។ ត្រូវហ្វឹកហាត់ឱ្យរឿយៗដោយសេចក្តីអត់ធន់ដើម្បីការងារបានល្អ និងមានព្យាយាមទើបការងារ

បានសម្រេច ។ ត្រូវចាំថា « មនុស្សសាងការងារ ការងារសាងមនុស្ស » ។

ការដែលគ្រាន់តែនិយាយថា ចង់បានយ៉ាងនេះ ចង់បានយ៉ាងនោះ គឺមិនអាចសម្រេចផលបានឡើយ ត្រូវធ្វើតាមដែលនិយាយផង ឬត្រូវធ្វើឱ្យសម្រេចតាមដែលប្រាថ្នា ទើបជាមនុស្សពូកែពិត ។ ត្រូវចាំថា « ការនិយាយជាការសាងសេចក្ដីសង្ឃឹម ឯការធ្វើជាការសាងនូវការពិត » ។

កើតមកជាមនុស្ស បើមិនពូកែអ្វីច្រើនមុខ ក៏ត្រូវឱ្យពូកែមួយមុខដែរ ហើយត្រូវតែពូកែពិតៗ ដែលអាចចិញ្ចឹមជីវិតបានផង ជាកិត្តិយសផង និងជាប្រយោជន៍ដល់សង្គមផង ។



## ១០-សុខនិងទុក្ខនៅក្នុងចិត្ត

ច្រែះ ពេលដែលកើតនឹងដែកណា រមែងស៊ីដែកនោះ មួយថ្ងៃបន្តិចៗ រហូតដល់ដែកនោះរលេះរលួយអស់ទៅ យ៉ាងណាមិញ សេចក្ដីទុក្ខកាលកើតក្នុងចិត្តនៃបុគ្គលណា ក៏រមែងបៀតបៀនចិត្តនៃបុគ្គលនោះជារៀងរាល់ថ្ងៃ ធ្វើឱ្យចិត្តក្ដៅក្រហាយរសាប់រសល់អួលណែន និងឈឺផ្សាមកដល់រូបកាយរហូតដល់ដាច់ខ្យល់ស្លាប់ក៏យ៉ាងនោះដែរ។

តាមការពិត ទុក្ខសោកនោះមិនមានអ្នកណាចង់ជួបចង់មានឡើយ ប៉ុន្តែ ទាំងដែលមិនចង់ជួបមិនចង់មាននោះឯង សេចក្ដីទុក្ខក៏នៅតែជាភ្ញៀវដែលអត់មារយាទ សូម្បីមិនបានអញ្ជើញ ក៏នៅតែមករកយើងទៀត ។ មកដល់ហើយ ទោះជាយើងបណ្ដេញ ក៏មិនព្រមទៅដោយងាយឡើយឬពេលខ្លះទៅហើយមិនជាប៉ុន្មានថ្ងៃ ក៏ត្រឡប់មកវិញ វិលវល់ជួចេ្ចះឯងកាន់ខែ កាន់ឆ្នាំ រហូតក្លាយជាសភាវៈប្រចាំថ្ងៃ ប្រចាំជីវិតរបស់មនុស្សយើង ។ នេះ

ពោលចំពោះការដែលមនុស្សយើងខ្វះឧបាយនៃបញ្ញា ។

បើយើងសាកល្បងពិចារណាមើលឱ្យល្អ យើងរមែងជួបនូវចំណុចនៃការពិតមួយថា សុខទុក្ខនោះឯងវាកើតឡើងនៅនឹងចិត្ត ហើយចិត្តហ្នឹងឯង ដែលជាធម្មជាតិទទួលយកនូវសុខនិងទុក្ខនោះ ។ កាលបើសុខកើតនឹងចិត្ត ចិត្តខ្លួនឯងរមែងជាសុខ តែបើទុក្ខកើតវិញ ចិត្តក៏ជាទុក្ខខ្លួនឯងដែរ ។ នេះជាការពិតប្រាកដណាស់ គឺសុខទុក្ខនោះចិត្តរបស់មនុស្សយើងបានទៅនាំយកមក ឱ្យនៅជាមួយពោលគឺធ្វើឱ្យវាកើតឡើងក្នុងចិត្តខ្លួនឯង ។ ដោយចំពោះសេចក្តីទុក្ខដែលប្រៀបដូចជាច្រែះស្នឹមនោះ គឺចិត្តរបស់យើងបាននាំយកមកដោយខ្លួនឯង ស្រេចហើយខ្លួនឯងក៏រមែងជាទុក្ខ ដូចដែកដែលច្រែះស៊ីដូច្នោះ ។

មនុស្សយើងដោយច្រើន ចូលចិត្តគិតទៅក្នុងរឿងផ្សេង១ ហើយសន្សំទុកនូវរឿងដែលមិនល្អក្នុងចិត្ត។ រឿងក្នុងអតីតកាលខ្លះ រឿងខ្លួនឯងខ្លះ រឿងអ្នកដទៃខ្លះ រឿងដែលមិនមែនជាសភាវៈពិត គ្រាន់តែជាបញ្ញត្តិ ទាំងដែល



រឿងខ្លះកិលេសក្នុងចិត្តខ្លួនឯង បាននិមិត្តឱ្យកើតឡើងទាំងស្រុងទៀតផង ។

បើក្នុងចិត្តប្រាសចាកលោភៈហើយ រឿងក្នុងលោកដែលសម្រាប់ឱ្យជាប់ជំពាក់រមែងមិនមាន ។

បើក្នុងចិត្តប្រាសចាកទោសៈហើយ រឿងក្នុងលោកដែលសម្រាប់ឱ្យទាស់ចិត្តរមែងមិនមាន ។

បើក្នុងចិត្តប្រាសចាកមោហៈហើយ រឿងក្នុងលោកដែលសម្រាប់ឱ្យវង្វេងនិងយល់ខុស រមែងមិនមាន សេចក្តីពិតក៏រមែងប្រាកដឱ្យដឹងច្បាស់ ។

ដោយអំណាចកិលេសក្នុងចិត្ត មនុស្សយើងរមែងខ្វាយខ្វល់ចូលទៅជំពាក់វាក់វិនក្នុងរឿងទាំងឡាយ សូម្បីដែលកន្លងទៅហើយ រួចទៅហើយ ក៏នៅតែយកមកគិតឱ្យស្អុកចិត្ត តឹងណែនក្នុងក្បាល ។ ប្រសិនបើរឿងកន្លងទៅហើយ វារួចបាត់ទៅហើយ ឱ្យវាហើយទៅចុះ មិនយកមកទុកឱ្យស្អុកណែនក្នុងចិត្ត ដូច្នេះ វាក៏មិនមានអ្វីបង្កការបៀតបៀនដល់ចិត្តដែរ ។

មនុស្សយើងដែលទន់ខ្សោយដោយបញ្ញា រមែងគិតដោះស្រាយចំពោះតែអ្វីដែលរួចទៅហើយ មានការកើតទុក្ខ មិនសុខចិត្តចំពោះការប្រព្រឹត្តរួចហើយរបស់អ្នកដទៃ មានការស្តីបន្ទោសដោយការខឹងក្រោធជាដើម ។ ចិត្តមិនស្ងប់ គឺមិនអាចដោះស្រាយបញ្ហាក្នុងបច្ចុប្បន្នទៅបានទេ ព្រោះថាបញ្ហាដែលត្រូវដោះស្រាយគឺបច្ចុប្បន្ន ។

បើយើងសិក្សាឱ្យបានស្គាល់បច្ចុប្បន្នច្បាស់ ថាតើបច្ចុប្បន្នគឺជាអ្វី យើងនឹងមិនប្រកាន់មាំឡើយ ព្រោះថា «ទោះបី បច្ចុប្បន្នវាជាសភាវៈដទៃដែលត្រូវតាមចិត្តរបស់យើងប្រាថ្នាក៏ដោយ ក៏វាត្រឹមតែជាបច្ចុប្បន្នប៉ុណ្ណោះ វារមែងបែកធ្លាយ មិនទៀង សោះសូន្យ» តើយើងចាំបាច់ចង់បានរបស់ដទៃ គ្រាន់តែតម្រូវតាមចិត្តយើងមកធ្វើអ្វី ។



## ១១-សុខនិងទុក្ខនៅក្នុងចិត្ត (ត)

បច្ច័យ ៤ សម្រាប់សេចក្តីសុខនៃរូបកាយ ហើយក៏នាំឱ្យសប្បាយចិត្តទៅជាមួយផងដែរ ប៉ុន្តែបច្ច័យ ៤ មិនមែនសម្រាប់សេចក្តីសុខនៃចិត្តដោយត្រង់ពិតនោះទេ។ អ្វីក៏ដោយ ឱ្យតែមិនបានកម្ចាត់បង់នូវបាបធម៌ក្នុងចិត្ត ដោយគ្រាន់តែនាំមកនូវការរីករាយនៃចិត្តប៉ុណ្ណោះ អ្វីនោះៗ គឺជាគ្រឿងស្រវឹងរបស់ចិត្ត ជាគ្រឿងញៀនដោយពិត ។

ចិត្តជាប់ជំពាក់នឹងអ្វីណា អ្វីនោះជាចំណងចងចិត្ត ចិត្តជាប់ចំណងរមែងទទួលនូវទារុណកម្ម គឺសេចក្តីទុក្ខសោក ។

មនុស្សយើង តែងស្វែងរកការសប្បាយអំពីរបស់ខាងក្រៅ ត្រូវចំណាយពេលវេលាយ៉ាងច្រើនដើម្បីបាននូវរបស់នោះ ព្រមទាំងត្រូវចំណាយអ្វីៗផ្សេងទៀតយ៉ាងច្រើនផងដែរ ។ ការសប្បាយក៏មិនទៀង របស់ដែលនាំឱ្យសប្បាយក៏មិនទៀង ម្ល៉ោះហើយត្រូវខាតបង់នូវពេលវេលា

និងអ្វីៗច្រើនទៀត ដែលត្រូវបានចំណាយទៅនោះឯងឥត
ប្រយោជន៍ ។

តាមពិតបច្ច័យ ៤ គ្រាន់តែជាទីអាស្រ័យ រួចហើយ មនុស្សយើងត្រូវស្វែងរកសុខពីចិត្តរបស់ខ្លួន ព្រោះថា មនុស្សយើងបានសុខ ព្រោះចិត្តមាននូវសេចក្ដីសុខ ។ ការគ្រប់គ្រងថែរក្សាចិត្ត កម្ចាត់បង់រោគគឺកិលេសដែលបៀត-បៀននូវចិត្តសន្តាន សម្រេចបាននូវសេចក្ដីស្ងប់ ចិត្តរមែងជាសុខ ។

មនុស្សយើងដែលព្រមសមាទានសីល កាន់សីល គឺជាការធ្វើឱ្យចិត្តរបស់ខ្លួនមានសីល ។ ចិត្តមានសីល រមែងមានសុខភាពល្អ ជាចិត្តដែលស្មោះត្រង់ ល្អស្អាត មាននូវសេចក្ដីសុខល្មមសមរម្យដោយខ្លួនឯង មិនត្រដាប-ត្រដួសដូចកាលពីមិនទាន់មានសីលឡើយ ។

សីលជាសម្លៀកបំពាក់ ជាគ្រឿងអលង្ការរបស់ចិត្ត ជាផ្ទះ ជាជម្រករបស់ចិត្ត ជាអាហារនិងជាថ្នាំកែរោគរបស់ចិត្ត ។



ដូច្នេះ មនុស្សយើងកាលដែលប្រាថ្នានូវសេចក្ដីសុខសម្រាប់ខ្លួន ត្រូវតែទូន្មានចិត្តរបស់ខ្លួន អប់រំចិត្តរបស់ខ្លួនឱ្យចេះកាន់សីល ។

សមាធិ គឺជាការសម្រាកយកកម្លាំងរបស់ចិត្ត ដូចជាការសម្រាក ឬការទទួលទានដំណេកនៃរូបកាយដែរ ។ កម្លាំងរបស់ចិត្តសម្រាប់ច្បាំងជាមួយសត្រូវក្នុងខ្លួនមាន ៥ គឺ :

**១-សទ្ធាពលៈ** កម្លាំងគឺការជឿចំពោះសេចក្ដីពិត។

**២-វិរិយពលៈ** កម្លាំង គឺការព្យាយាមកម្ចាត់បាបចម្រើនបុណ្យ ។

**៣-សតិពលៈ** កម្លាំង គឺស្មារតីភ្ញាក់រលឹកដឹងទាន់និងយល់អំពីការពិត ។

**៤-សមាធិពលៈ** កម្លាំង គឺចិត្តស្ងប់ដោយប្រពៃ ។

**៥-បញ្ញាពលៈ** កម្លាំង គឺការដឹងហេតុផលពិត ។

បញ្ញា គឺជាគោលសំខាន់និងជាកំពូលនៃធម៌បដិបត្តិក្នុងព្រះពុទ្ធសាសនា ។ បញ្ញាអាចដោះស្រាយបញ្ហាបាន

គ្រប់យ៉ាង ដែលជាបញ្ហានាំមកនូវទុក្ខកង្វល់ក្នុងចិត្ត ។ បញ្ញានាំមកនូវសេចក្តីសុខ សូម្បីក្នុងរឿងដែលថាគួរឱ្យកើតទុក្ខ ។

ព្រោះហេតុគិតខុសថាមានខ្លួន ក៏នាំឱ្យគិតពីខ្លួនឯង ខំប្រឹងចិញ្ចឹមបីបាច់ថែរក្សាខ្លួនឯងដោយលំបាកលំបិន ហួងហែងការពារអ្វីៗគ្រប់យ៉ាងឱ្យខ្លួនឯង។ សូម្បីសប្បាយចិត្តក៏ព្រោះមកពីគិតថាខ្លួនឯងបានផលសម្រេចដែរ ប៉ុន្តែបញ្ញាអាចធ្វើឱ្យមិនមានខ្លួនសម្រាប់កើតទុក្ខកង្វល់ ពោលគឺមិនមានខ្លួនសម្រាប់គិត សម្រាប់ហួងហែងការពារ បញ្ញាធ្វើឱ្យនៅសល់តែរូបធម៌ និងនាមធម៌តែប៉ុណ្ណោះ ។

អ្នកមានបញ្ញា ប្រើប្រាស់រូបកាយសាងប្រយោជន៍ ទុកដាក់រូបកាយដូចជាឧបករណ៍សម្រាប់ប្រើប្រាស់ ទោះចាស់ ទោះឈឺ ឬនឹងត្រូវបែកធ្លាយ ក៏ចំពោះតែរូបកាយប៉ុណ្ណោះ អ្នកមានបញ្ញាមិនបានត្រាំត្រាផ្លូវចិត្តទេ ផ្ទុយពីមនុស្សល្ងង់ដែលរវល់តែបម្រើរូបកាយ ព្រោះសំគាល់ថាជាខ្លួន ហើយក៏មិនបានបំពេញនូវប្រយោជន៍ពិតឡើយ ។



## ១២-សទ្ធា

សទ្ធា គឺការជឿ ការចុះចិត្តស៊ប់ ការដោតជាប់ដោយចិត្ត ព្រោះបានពិចារណាឃើញហេតុផលដោយបញ្ញា ។ មានការចែកជា ៣ ផ្នែក :

១-ការជឿ ការចុះស៊ប់ដោតជាប់ទៅក្នុងព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គជាបុគ្គលគំរូ ។ ព្រះអង្គទ្រង់បានអះអាងចំពោះសមត្ថភាពរបស់មនុស្សថា មនុស្សអាចត្រាស់ដឹងនូវសច្ចធម៌ គឺចូលដល់ការពិត និងសេចក្តីល្អដ៏ខ្ពង់ខ្ពស់បំផុតបាន ដោយសតិបញ្ញា និងសេចក្តីព្យាយាមរបស់មនុស្សខ្លួនឯង ។

មនុស្សជាសត្វដែលអាចហ្វឹកហាត់បាន អាចមានការចម្រើនឡើងបាន ទាំងផ្នែករបៀបរបបនៃជីវិតដែលមានទំនាក់ទំនងជាមួយសង្គម ប្រព្រឹត្តទៅដោយកាយដោយវាចា ទាំងក្នុងផ្នែកគុណធម៌ដែលគប្បីអប់រំឱ្យចាស់ក្លាឡើងក្នុងសន្តានចិត្ត ទាំងក្នុងផ្នែកបញ្ញាចាក់ធ្លុះយល់ដឹង

នូវហេតុផល រហូតអាចរួចផុតចាកគ្រឿងចងគឺកិលេស និងទារុណកម្មគឺកងទុក្ខ ។

ការដែលធ្វើទុក្ខឱ្យអស់ទៅ ព្រមទាំងបានជួបប្រសព្វនូវភាពជាឥស្សរៈក្នុងចិត្ត និងរួចផុតពីទាសភាព សភាពបែបនេះ រមែងមិនមានសត្វវិសេសណាៗ មានទេវតាមារព្រហ្មជាដើម ដែលអាចមានសមត្ថភាពនិងបានប្រសើរជាងមនុស្សឡើយ ។ មនុស្សដែលបានហ្វឹកហាត់រហូតដល់បានសម្រេចដល់នូវភាវៈដ៏ខ្ពង់ខ្ពស់ហើយ រមែងមានគុណវិសេសដ៏អស្ចារ្យ ដែលសមគួរនឹងដើរតាមនៃបុគ្គលទាំងឡាយ ។

កាលបើមនុស្សមានការជឿជាក់មាំទាំក្នុងចិត្ត ចំពោះសមត្ថភាពដូចដែលពោលមកខាងលើនេះ ក៏គួរតែព្យាយាមបដិបត្តិ សាងគុណវិសេសនោះឱ្យចម្រើនឡើងក្នុងខ្លួន ឬគួរបដិបត្តិឱ្យបានចូលដល់ធម៌ ដែលព្រះសម្មាសម្ពុទ្ធជាអង្គគំរូ បានស្វែងរកជួបប្រទះ និងនាំយកមកសម្តែងទុកនៅរហូតដល់សព្វថ្ងៃ ។



២.ការជឿ ការចុះចិត្តស៊ប់ដោតជាប់ទៅក្នុងព្រះធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងទុកមកនោះឯង ព្រមទាំងព្រះធម៌ដែលទ្រទ្រង់សត្វឱ្យរួចផុតចាកទុក្ខ ។

ធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹង និងត្រាស់សម្តែង គឺជាសភាវៈដែលប្រព្រឹត្តទៅតាមធម្មតា ពោលគឺជាទំនៀមនៃហេតុផល ដែលយើងតែងហៅថា « ច្បាប់នៃធម្មជាតិ » ។

ធម្មជាតិដែលជាការពិតនៃហេតុផល មានក្នុងជីវិតនៃសត្វលោក កាលណាបើបុគ្គលអប់រំនូវបញ្ញាបានចាស់ក្លាហើយ បានឃើញច្បាស់នូវធម្មជាតិនោះដោយខ្លួនឯង រមែងដោះស្រាយបាននូវបញ្ហា រំលត់ទុក្ខក្នុងសន្តាន បានដល់នូវទីបំផុតទុក្ខ ។

៣.ការជឿ ការចុះចិត្តស៊ប់ដោតជាប់ទៅក្នុងព្រះសង្ឃ ដែលជាសង្គមនៃមនុស្សមានការឋិតនៅក្នុងធម៌វិន័យ ឬថាជាសង្គមនៃមនុស្សដែលប្រាសចាកទុក្ខ ។

ក្នុងលោកមានព្រះសង្ឃ ជាការបញ្ជាក់ឱ្យឃើញ

ថា មនុស្សទូទៅអាចមានសមត្ថភាពធ្វើឱ្យសម្រេចបាននូវ គុណធម៌ដ៏ខ្ពង់ខ្ពស់ បានចូលដល់ការពិត រួចផុតពីទុក្ខកង្វល់ ដូចព្រះសម្មាសម្ពុទ្ធជាអង្គគំរូដែរ ប៉ុន្តែ ត្រូវតែជាមនុស្សដែលមានឧបនិស្ស័យល្អ និងព្យាយាមហ្វឹកហាត់ ដោយសេចក្តីមិនប្រមាទ ។

សង្គមមនុស្សដ៏យ៉ាងល្អបែបនេះ កើតឡើងនិងប្រព្រឹត្តទៅបាន ក៏ដោយអាស្រ័យការប្រព្រឹត្តល្អឥតខ្ចោះនៃបុគ្គលមានគុណធម៌ជាខ្លឹមនៃជីវិត ។ មនុស្សយើងគួរតែលើកតម្កើងនូវសង្គមបែបនេះឯង គួរថែរក្សានិងចូលរួមដោយខ្លួនឯងផ្ទាល់ ។

បុគ្គលដែលមាននូវសទ្ធាជឿគុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដូចដែលបានពោលមកហើយនេះ រមែងជឿជាក់នៅក្នុងកម្មគឺការធ្វើ និងជឿជាក់ក្នុងផលរបស់កម្ម ដែលប្រព្រឹត្តទៅជាទំនៀមនៃហេតុផល ព្រោះថាក្នុងព្រះ-ពុទ្ធ ព្រះធម៌ ព្រះសង្ឃ សុទ្ធតែមានហេតុផលទាំងអស់ ។



## ១៣-សីល

សីល គឺជាមារយាទល្អក្នុងការប្រព្រឹត្ត ឬជារបៀបនៃការរស់នៅ ទាំងជាផ្នែកផ្ទាល់ខ្លួន និងទាំងជាផ្នែកទំនាក់ទំនងជាមួយសង្គមជុំវិញដោយកាយវាចា រហូតដល់ការងារចិញ្ចឹមជីវិត ។

សីល ប្រព្រឹត្តទៅដើម្បីធ្វើឱ្យការរស់នៅនោះឯង មានអំណោយផលដល់ការបដិបត្តិផ្សេងៗ ដែលប្រព្រឹត្តទៅដើម្បីចូលដល់ទីបំផុតនៃសេចក្តីល្អ គឺជាឧត្តមគតិរបស់មនុស្សក្នុងសង្គម ។

សីល ដែលជារបៀបនៃការប្រព្រឹត្តនេះ គឺមានលក្ខណៈបិទខ្ទប់ ឬរាំងស្ទះនូវឱកាសនៃការប្រព្រឹត្តអាក្រក់ និងជ្រោមជ្រែងនូវឱកាសនៃការប្រព្រឹត្តល្អ ។

សីល បានបង្វឹកបង្ហាត់មនុស្សឱ្យចេះសាងសម្ពន្ធ-ភាពដោយកាយវាចាដែលល្អប្រពៃ ជាមួយនឹងជីវិតដទៃក្នុងសង្គម ជាមួយនឹងបរិស្ថាន ដែលនាំឱ្យផលដល់ការ

តាំងនៅនៃសន្តិសុខសង្គម ភាពថ្លៃថ្នូរសម្បូណ៌សប្បាយរបស់ខ្លួន និងសង្គមរបស់ខ្លួន ជាពិសេសយ៉ាងក្រៃលែង គឺអំណោយផលដល់ការរស់នៅជាមួយគ្នាដោយល្អ ប្រាស-ចាកការគំរាមកំហែង សម្លុតបៀតបៀន រវាងជីវិតដែលប្រាថ្នាសុខទាំងអស់គ្នា ។

ក្នុងសភាពនៃការជ្រោមជ្រែងរបស់សីល ដែលធ្វើឱ្យសន្តិសុខសង្គមមានស្ថេរភាព សមាជិកម្នាក់ៗក្រៅអំពីរស់នៅបានដោយសុខស្រួលហើយ នៅមានឱកាសដែលនឹងសាងការងារល្អ ដែលជាសេចក្តីចម្រើនរុងរឿង ទាំងផ្នែកសង្គម ទាំងផ្នែកចិត្តវិញ្ញាណរបស់ខ្លួន ។

សម្រាប់សង្គមមនុស្សលោកជាទូទៅ របៀបនៃការប្រព្រឹត្តជាខាងដើម ឬសីលថ្នាក់ដំបូង សីលជាគ្រឹះជាភូមិឋាន ដែលរមែងសាងនូវសេចក្តីចម្រើនឱ្យកើតឡើង គឺសីល ៥ ។

សីល ៥ មានសារៈសំខាន់ដ៏ក្រៃលែង មានន័យមានតម្លៃសម្រាប់អ្នកប្រព្រឹត្តណាស់ ដូច្នេះមនុស្សគ្រប់វ័យ



គ្រប់ភេទ គ្រប់ឋានៈ គួរយកចិត្តទុកដាក់ពិចារណាអំពីខ្លឹមសារ និងសិក្សាប្រព្រឹត្តឱ្យបានល្អ ទៅតាមសិក្ខាបទនីមួយៗ :

១-ការមិនប្រព្រឹត្តល្មើសចំពោះជីវិត មនុស្សសត្វដទៃ មិនបៀតបៀន មិនសម្លាប់ គឺជាការដាក់ចុះនូវអំណាចអាជ្ញាក្នុងការប្រហារជីវិតសត្វ ។ ជាការសម្តែងបញ្ជាក់ពីសតិសម្បជញ្ញៈ មានការចម្រើនឡើងក្នុងមនុស្សមិនដូចជាគតិធម្មតានៃសត្វតិរច្ឆាន ។ មនុស្សដែលចម្រើនដោយសតិសម្បជញ្ញៈ រមែងចេះគិតចេះពិចារណា ចេះប្រៀបធៀប ចេះយកខ្លួនឯងជាឧបមា រួចហើយយល់ដឹងដោយបញ្ញាចំពោះជីវិតនៃសត្វលោកមានមនោសញ្ចេតនាមានការឱ្យអភ័យ និងមានមេត្តាករុណា ។

២-ការមិនប្រព្រឹត្តល្មើសចំពោះទ្រព្យសម្បត្តិនៃអ្នកដទៃ មិនលួច មិនប្លន់ និងមិនកាន់យកនូវការងារចិញ្ចឹមជីវិតណាមួយដែលមិនប្រពៃឡើយ ។

៣-ការមិនប្រព្រឹត្តល្មើសចំពោះមេថុនធម្ម មានការ

សង្គ្រួមក្នុងកាម ព្រោះបានពិចារណាឃើញថា កាមទាំង-ឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ។

៤-ការមិនប្រព្រឹត្តល្មើសចំពោះសច្ចវាចា ការរក្សាសម្តីឱ្យមានតម្លៃ ការរក្សាសេចក្តីល្អទុកក្នុងខ្លួន មិននិយាយកុហក មិនឱ្យលាមកចេញពីមាត់ ។ សម្តីដូចជាផ្កាវាចាដូចទឹកឃ្មុំ មានសារៈសំខាន់សម្រាប់មនុស្សណាស់ក្នុងសង្គម ។

៥-ការមិនប្រព្រឹត្តល្មើសចំពោះសតិសម្បជញ្ញៈ មិនទម្លាយនូវសម្បត្តិដ៏វិសេសរបស់ខ្លួនជាមនុស្ស គឺគំនិតដែលចេះគិតខុសត្រូវល្អអាក្រក់ ដោយការបរិភោគសេពសោយនូវគ្រឿងស្រវឹងនោះឡើយ ។

មនុស្សយើងកើតមកជាមនុស្សដោយរូបកាយ ប៉ុន្តែ ចិត្តវិញ្ញាណមិនទាន់បានជាមនុស្សឡើយ ដរាបណាមិនទាន់មាននូវសីល ៥ ទេនោះ ។



## ១៤-សុតៈ

សុតៈ គឺជាចំណេះដឹងដែលបានមកអំពីការស្តាប់ ការរៀន ការអាន ។ ការចេះដឹងដែលបានមកអំពីការសិក្សាសិល្បវិទ្យាផ្សេងៗ ទាក់ទងនឹងការងារចិញ្ចឹមជីវិតព្រមទាំងការប្រកបកិច្ចការផ្សេងៗទៀតក្នុងផ្លូវលោកសូម្បីជាសុតៈក៏ដោយ ប៉ុន្តែនៅមិនទាន់បានគ្រប់គ្រាន់សម្រាប់ចូលទៅរកភាពជាអរិយសាវ័កឡើយ ។

បុគ្គលម្នាក់ៗ អាចមាននូវសុតៈក្នុងសិល្បវិទ្យាត្រឹមតែមួយមុខ ក៏ល្មមសម្រាប់ការងារអាជីព ញ៉ាំងជីវិតឱ្យរស់នៅបាន ។ មនុស្សម្នាក់ៗមានសុតៈក្នុងផ្នែកមួយៗ អាចផ្សេងៗគ្នាបាន សុតៈរបស់មនុស្សម្នាក់ មិនចាំបាច់សម្រាប់មនុស្សម្នាក់ទៀតក៏បានដែរ ពោលគឺសុតៈក្នុងលោកនេះមិនសុទ្ធតែចាំបាច់ឱ្យមានដូចៗគ្នានោះឡើយ ។

សុតៈដែលនៅប្រកបដោយទោស លាយច្រឡំដោយលោភៈទោសៈមោហៈ សូម្បីទិសដៅប្រព្រឹត្តទៅ

ដើម្បីដោះស្រាយបញ្ហាជីវិត ធ្វើឱ្យបានជួបនូវសេចក្តីសុខសប្បាយ ប៉ុន្តែជាច្រើនដងវាត្រឡប់ក្លាយមកជាការសាងបញ្ហា បង្កសេចក្តីទុក្ខសោកដែលលំបាកនឹងដោះស្រាយ ។

សុតៈនៅក្នុងព្រះពុទ្ធសាសនា ជាសុតៈប្រាសចាកទោស ជាគុណសម្បត្តិរបស់ព្រះអរិយសាវ័ក សំដៅដល់ការចេះដឹងដែលចាំបាច់ដល់មនុស្សគ្រប់គ្នា ដើម្បីរៀបចំដំណើរជីវិតឱ្យបានល្អបរិសុទ្ធ ធ្វើឱ្យចេះប្រើសុតៈដទៃ១មានវិជ្ជាជីវៈជាដើម ប្រព្រឹត្តទៅក្នុងផ្លូវដែលជាគុណជាប្រយោជន៍ទាំងដល់ខ្លួនឯងនិងអ្នកដទៃ ។

សុតៈដែលនៅក្នុងក្រុមអរិយទ្រព្យ មានសទ្ធានិងសីលជាខាងដើមនេះ ជាជំនួយសម្រាប់រារាំងនូវទោស ជួយធ្វើឱ្យសុតៈដទៃមានគុណតម្លៃពេញបរិបូណ៌ជាចំណេះដឹងសម្រាប់ដោះស្រាយនូវបញ្ហា សម្រេចទិសដៅដែលជាបំណងប្រាថ្នាពិតប្រាកដ ។ សុតៈនេះមានតែគុណម្យ៉ាងប៉ុណ្ណោះ យ៉ាងក្រៃលែងនោះ សុតៈនេះឯង គឺជាការចេះដឹង ដែលធ្វើឱ្យបុថុជ្ជន ក្លាយទៅជាព្រះអរិយបុគ្គលបាន



សុតៈនេះក៏គឺការចេះដឹងក្នុងអរិយធម៌ ។

អរិយធម៌ គឺធម៌ពិតព្រមទាំងធម៌ល្អផ្សេង១ដែលព្រះអរិយៈបានសម្តែង បានប្រាប់បង្ហាញ ប្រព្រឹត្តទៅដើម្បីគ្រប់គ្រងជីវិតបានល្អបានប្រសើរ ក្នុងដំណើរទៅកាន់ភាពជាអរិយជន ។

សុតៈក្នុងសិល្បវិទ្យាផ្សេង១ ត្រូវគ្រប់គ្រងដោយសុតៈក្នុងអរិយធម៌គ្រប់កាលទាំងពួង ទើបល្មមឱ្យទុកចិត្តបានថា ជាការដោះស្រាយបញ្ហា មិនមែនជាចំណេះដឹងសម្រាប់សាងនូវបញ្ហាឡើយ ។

សុតៈក្នុងអរិយធម៌ គឺជាឃ្លាំងទុកដាក់នូវឧបករណ៍សម្រាប់សាងបញ្ញា ពោលគឺបញ្ញាមានការចម្រើន ព្រោះសុតៈក្នុងអរិយធម៌ ។ ត្រឡប់មកវិញសុតៈគ្រប់យ៉ាងក្នុងលោក កាលបើប្រើប្រាស់ដោយបញ្ញាដែលចម្រើនហើយរមែងប្រព្រឹត្តទៅជាប្រយោជន៍ ដូចជាឧបករណ៍ក្នុងលោកដែលប្រើប្រាស់ដោយអ្នកជំនាញហើយដូច្នោះឯង ។

សុតៈក្នុងអរិយធម៌ គឺជាកំពូលនៃសុតៈក្នុងលោក ។

បុគ្គលដែលមានការសិក្សាដោយល្អក្នុងព្រះពុទ្ធវចនៈ គឺជាការទទួលយកនូវព្រះសម្មាសម្ពុទ្ធជាសាស្តា មានការយល់ដឹងក្នុងគោលនៃការពិត ច្បាប់ធម្មជាតិ ហេតុផលក្នុងជីវិត ប្រព្រឹត្តទៅដើម្បីយោនិសោមនសិការ ក្នុងការញុំាងសម្មាទិដ្ឋិឱ្យកើតឡើង ។

មនុស្សមួយចំនួន កាន់យកនូវការបដិបត្តិ ដោយការខ្វះខាតនូវសុតៈក្នុងអរិយធម៌ ទាំងគ្រូអ្នកដឹកនាំក៏ខ្វះខាត មិនអាចដើរត្រូវផ្លូវបានឡើយ ។ ការបដិបត្តិនូវធម៌ពិតជាសំខាន់ ប៉ុន្តែការបដិបត្តិប្រៀបដូចជាការដើរផ្លូវ ត្រូវអាស្រ័យសុតៈក្នុងអរិយធម៌ ដែលដូចជាអ្នកនាំផ្លូវ ត្រូវឱ្យយល់ច្បាស់ប្រាកដថា អ្វីណាត្រូវកំណត់ដឹង ។



## ១៥-ចាគៈ

ចាគៈ ប្រែថា ការលះ ឬលះឱ្យ សំដៅដល់ការឱ្យដែលពិតប្រាកដ ។ ចាគៈ លះទាំងខាងក្រៅ លះទាំងខាងក្នុង គឺខាងក្រៅលះវត្ថុ ខាងក្នុងលះកិលេស លះលោភៈ មិនមានកំណាញ់ហួងហែង មិនប្រាថ្នាផលតបស្នង ។

ការឱ្យរបស់ព្រះអរិយសាវ័ក លោកឱ្យដោយចិត្តដ៏ខ្ពង់ខ្ពស់ ផុតស្រឡះពីការសង្ឃឹមផលតបស្នងណាៗទាំង-អស់ មិនថាជាលាភ ជាយស ជាសុខ ជាសួគ៌អ្វីឡើយ ។ លក្ខណៈផ្នែកចាគៈរបស់ព្រះអរិយសាវ័ក គឺពេញចិត្តក្នុងការឱ្យ ត្រេកអរក្នុងការលះ ជាការសម្តែងឱ្យឃើញនូវសេចក្តីសុខក្នុងខ្លួន គឺមានការសប្បាយចិត្តក្នុងការធ្វើបែបនោះ ។

ព្រះអរិយសាវ័ក មិនមានបញ្ហាក្នុងរឿងខកចិត្ត ហើយមកដេកកើតទុក្ខក្តៅក្រហាយ សោកសៅខ្សឹកខ្សួលពោលរៀបរាប់ថា ធ្វើហើយមិនបានផលយ៉ាងនេះឬយ៉ាង

នោះឡើយ ។

កាលដែលលោភៈមិនគ្របសង្កត់ចិត្ត មិនមានការហួងហែង បិទបាំង នៅខាងក្នុងចិត្តនៃព្រះអរិយសាវ័កហើយ ចិត្តក៏បានបើកធំទូលំទូលាយ ហើយការយល់ដល់អ្នកដទៃក៏កើតឡើង មើលឃើញដល់សេចក្ដីទុក្ខលំបាករបស់អ្នកដទៃបានដោយងាយ ម្ល៉ោះហើយ ដួងចិត្តក៏បង្អោនទៅឯងក្នុងការឱ្យ សំដៅដល់ការសង្គ្រោះ ឱ្យអ្នកដទៃបាននូវប្រយោជន៍ ដោះស្រាយបញ្ហាឱ្យគេ ធ្វើឱ្យគេបានសុខ និងត្រេកអរពេញចិត្ត មានសេចក្ដីសុខចិត្តព្រោះហេតុតែបានឱ្យ ។

ការលះ ការបែងចែកនោះៗ បើគិតនៅក្នុងផ្នែកនៃផលតបស្នង ការឱ្យនោះឯងជាការបាននូវផលសម្រេចក្នុងខ្លួនឯង ដែលត្រូវឃើញច្បាស់ក្នុងបច្ចុប្បន្នទាន់ភ្នែកព្រោះព្រះអរិយសាវ័កមានកុសលឆន្ទៈ គឺពេញចិត្តក្នុងកុសលធម៌ ត្រូវការធ្វើសេចក្ដីល្អ ឬត្រូវការឱ្យមាននូវសភាវៈដែលល្អ ដោយការឱ្យនោះជាដើម ម្ល៉ោះហើយ



សភាវៈដែលល្អនោះៗ ក៏បានសម្រេចជាផលក្នុងខ្លួនឯងដែលជាទីរីករាយនៃព្រះអរិយសាវ័ក ។

ព្រះអរិយសាវ័ក មានមេត្តា ប្រាថ្នាឱ្យសត្វលោកមានសេចក្ដីសុខ ឯការដែលបានបរិច្ចាគនោះ ក៏ដោយអំ-ណាចនៃមេត្តាករុណាហ្នឹងឯង ដោយការឱ្យនោះ មនុស្សសត្វក្នុងលោកក៏មានសេចក្ដីសុខចម្រើនឡើង ។ ក្រៅពីនេះ ព្រះអរិយសាវ័កនៅមានចិត្តបរិសុទ្ធផូរផង់ មានកិលេសបានកាត់បន្ថយដោយអរិយមគ្គ មានការហ្វឹកហាត់អប់រំខ្លួន មានការឈានទៅមុខក្នុងកុសលធម៌ ក្នុងសេចក្ដីសុខ និងមានបីតិក្នុងសភាវៈដែលជាបុណ្យជាកុសលទាំង-អស់នោះ ព្រមទាំងបានចូលជិតទិសដៅនៃព្រះពុទ្ធសាសនាយ៉ាងកៀកកិតទៀតផង ។

បណ្ឌិតទាំងឡាយ រមែងមិនឱ្យទាន ព្រោះឃើញដល់ឧបធិសុខ (សុខជាអារម្មណ៍នៃកិលេស គឺលោកិយសុខ ឬសុខក្នុងភពបី ) រមែងមិនឱ្យទានដើម្បីភពថ្មី ប៉ុន្តែបណ្ឌិតទាំងនោះ រមែងឱ្យទានដើម្បីកម្ចាត់កិលេស ដើម្បី

មិនកកើតនៃភពថ្មីតទៅទៀត ។

ក្រៅអំពីការឱ្យដោយការជួយសង្គ្រោះហើយ ចាគៈរបស់ព្រះអរិយសាវ័កនៅសម្តែងចេញមួយផ្នែកទៀត គឺទំនុកបម្រុងដល់អ្នកមានសីល មានកល្យាណធម៌ទាំងឡាយ ដោយទុកដូចជាថា ទ្រព្យសម្បត្តិរបស់ខ្លួននោះជាសាធារណៈដល់អ្នកមានសីលមានកល្យាណធម៌ ។

ម្យ៉ាងទៀត ក្នុងឋានៈដែលព្រះអរិយសាវ័កជាសប្បុរស រមែងឱ្យទានជាសប្បុរិសទាន ។ លក្ខណៈសំខាន់ម្យ៉ាងដែលព្រះសម្មាសម្ពុទ្ធសង្កត់ធ្ងន់ក្នុងសប្បុរិសទាន គឺការឱ្យទានដោយគោរព បានដល់ការឱ្យដោយការតាំងចិត្តពិតៗ ឱ្យសេចក្តីសំខាន់ដល់អ្នកទទួល ដល់ទេយ្យធម៌ និងឱ្យសេចក្តីសំខាន់ដល់ការឱ្យទាននោះឯង ។



## ១៦. បញ្ញា

បញ្ញា ប្រែថា ការដឹងច្បាស់ បានដល់ការយល់ ការដឹងហេតុផល ដឹងដោយទូទៅ វិនិច្ឆ័យបានថា អ្វីពិត អ្វីមិនពិត អ្វីល្អ អ្វីអាក្រក់ អ្វីខុស អ្វីត្រូវ អ្វីគួរ អ្វីមិនគួរ អ្វីជាគុណ អ្វីជាទោស និងអ្វីជាប្រយោជន៍ អ្វីមិនជាប្រយោជន៍ ជាដើម ។

បញ្ញា ដឹងទំនាក់ទំនងរវាងហេតុនិងផល ឬបច្ច័យផ្សេងៗ ដឹងសភាវៈតាមសេចក្តីពិត ដឹងថា ត្រូវបដិបត្តិយ៉ាងណាចំពោះសភាវៈពិតនោះ ទើបអាចដោះស្រាយបញ្ហា ដោះស្រាយនូវទុក្ខទាំងឡាយក្នុងជីវិត ។

បញ្ញា ចេះដឹងអំពីដំណើរជីវិតព្រមទាំងចេះរៀបចំដំណើរជីវិតឱ្យបានល្អត្រឹមត្រូវទៀតផង គឺមិនឱ្យកើតបញ្ហា មិនឱ្យជាទីមកនៃទុក្ខ ព្រោះការដើរក្នុងផ្លូវខុសឡើយ ។

បញ្ញា យល់អំពីលោក និងជីវិតក្នុងលោកតាមសេចក្តីពិត ឃើញបដិច្ចសមុប្បាទធម៌ ដឹងនូវអរិយសច្ចធម៌

មានការគិតពិចារណានូវហេតុផល ដែលមិនត្រូវអកុសលនីវរណៈគ្របសង្កត់ ។

បញ្ញាសម្បទាដែលជាគុណសម្បត្តិរបស់ព្រះអរិយ-សាវ័ក គឺដឹងការកើត និងការអស់ទៅសូន្យទៅនៃសង្ខារ-ធម៌ ដឹងគតិធម្មតារបស់លោកនិងជីវិត ដែលមានការកើតចាស់ឈឺស្លាប់ អ្វីៗដែលកើតឡើងរមែងមានការវិនាសទៅវិញរលត់ទៅវិញជាធម្មតា ហើយរំលត់នូវសេចក្តីប្រកាន់ ដោយបានដឹងច្បាស់ថា សង្ខារទាំងពួងមិនគួរប្រកាន់ថាជារបស់មាំមួន ។

មិនថាអ្នកណា ដែលជាអ្នកមានលោកិយបញ្ញាខ្លាំងក្លាពូកែ ទោះជាក្នុងផ្នែកការងាររកទទួលទាន ឬរកធ្វើមានធ្វើបាន រុងរឿងខាងសេដ្ឋកិច្ច ពូកែខាងស្រាវជ្រាវក្នុងផ្នែកវិទ្យាសាស្ត្រយ៉ាងណាក៏ដោយ ចំណេះដឹងដែលមិនអាចខ្វះខាតបាន ឬមានការចាំបាច់ជាទីបំផុតសម្រាប់គ្រប់គ្នា ក្នុងការដែលត្រូវដោះស្រាយបញ្ហាជីវិតឱ្យប្រាសចាកទោស ក៏គឺបញ្ញាដែលជាគុណសម្បត្តិរបស់ព្រះអរិយ-



សាវ័កនោះឯង ។

សុតៈជាឧបករណ៍ដ៏សំខាន់របស់បញ្ញា ឯចំណែកបញ្ញាឱ្យសេចក្តីសម្រេចដល់សុតៈ ពោលគឺបញ្ញាជាផលសម្រេចរបស់សុតៈនោះឯង ។ មិនត្រឹមតែឱ្យសេចក្តីសម្រេចដល់សុតៈប៉ុណ្ណោះទេ បញ្ញាបានឱ្យភាពត្រឹមត្រូវដល់គុណសម្បត្តិដទៃៗទាំងអស់ ។ បញ្ញាធ្វើឱ្យសទ្ធាជាសទ្ធាដែលត្រឹមត្រូវទៅតាមសេចក្តីពិត មិនភ្លាំងភ្លាត់ទៅជារឿងភ្ញាក់ផ្អើលផ្សេងៗ ដោយចេះតែជឿខុសហេតុផលនោះឡើយ ។ បញ្ញាធ្វើឱ្យសីល ជាសីលដែលជាទីត្រេកអរនៃព្រះអរិយៈ មិនក្លាយទៅជាសីលព្វតបរាមាស ។ បញ្ញាធ្វើឱ្យចាគៈ ជាចាគៈដែលលះបង់ពិតប្រាកដ ។

បើមិនមានបញ្ញាយល់អំពីលោក និងជីវិតតាមសេចក្តីពិត ពោលគឺមិនបានឃើញសភាវធម៌ដែលមានការកើតឡើង និងរលត់ទៅ មិនបានកំណត់ដឹងនូវគតិធម្មតារបស់សង្ខារទាំងឡាយទេ ព្រមទាំងមិនបានរៀនឱ្យដឹងអំពីសេចក្តីសុខដែលប្រណីតក្រៃលែងឡើងនោះ គឺជាធម្មតា

វមែងឱ្យតម្លៃដល់វត្ថុកាមដ៏ខ្ពង់ខ្ពស់បំផុត ម្ល៉ោះហើយវាជាការលំបាកណាស់ ដែលថាមិនឱ្យវង្វេងប្រាថ្នាទៅក្នុងលោកិយសុខ និងជាការលំបាកដោយពិត ដែលថាចាគៈលះបង់ហើយដោយមិនប្រាថ្នាផលតបស្នង ជាកាមគុណផ្សេងៗ ឬក្នុងសភាវៈឯណានីមួយនោះ ។

ដូច្នេះ បញ្ញាទើបជាខ្លឹម និងជាតួឃុំគ្រងនូវគុណសម្បត្តិដទៃៗ ។ បញ្ញាជាគុណសម្បត្តិដ៏សំខាន់បំផុតរបស់ព្រះអរិយសាវ័ក និងជាចំណុចទិសដៅនៃការហ្វឹកហាត់អប់រំខ្លួនរបស់ព្រះអរិយសាវ័កជាបន្តទៅ រហូតដល់អស់អវិជ្ជាមិនមានសល់ ។



## ១៧-សាងមនុស្ស

បណ្ដាការសាងទាំងឡាយ មិនមានការសាងណាឱ្យលំបាកជាងការសាងមនុស្សឡើយ ព្រោះថាការសាងវត្ថុសម្ភារៈផ្ទះសម្បែងជាដើម ពេលដែលចុះដៃសាងទៅហើយ ក៏ឃើញផលសម្រេចជាលំដាប់ៗ មិនយូរប៉ុន្មានក៏បានរួចស្រេចបាច់តាមគម្រោងការ ទោះជាមានភ្លាំងភ្លាត់ខ្លះក៏មានតិចដែរ ។

ការសាងមនុស្ស លំបាកតាំងតែពីពេលចាប់ផ្ដើម លំបាកទាំងវិធីក្នុងការសាង លំបាកទាំងត្រូវប្រើពេល-វេលាច្រើន និងដែលសំខាន់បំផុតគឺលទ្ធផលដែលបានមកនោះ ស្ថិតនៅក្នុងសភាពមិនប្រាកដថា តើបានល្អតាមដែលត្រូវការឬអត់ ។ អ្នកដែលតាំងចិត្តសាងមនុស្ស មានការចុះទុនចុះកម្លាំងយ៉ាងច្រើន រួចហើយត្រឡប់ជាខកចិត្តអស់សង្ឃឹមទៅវិញ គឺមានមិនតិចនាក់ឡើយ ។

កាលបើសាងមនុស្សបានសម្រេច សូម្បីតែម្នាក់

រមែងមានតម្លៃដ៏ក្រៃលែង គ្រប់គ្រាន់ដល់ការចុះទុនចុះកម្លាំងស្រេចតែម្តង។ ជាការពិតណាស់ ក្នុងភូមិស្រុកណាមានមនុស្សល្អម្នាក់ មនុស្សល្អម្នាក់នោះ អាចធ្វើឱ្យភូមិស្រុកនោះចម្រើនបាន គ្រួសារណាមានកូនល្អម្នាក់ ឪពុកម្តាយអាចពឹងពាក់អាស្រ័យបាន វត្តណាមានបព្វជិតល្អសូម្បីតែមួយអង្គ វត្តនោះរមែងចម្រើន អាចជាទីពឹងដល់មនុស្សទាំងឡាយច្រើន ។ ក្នុងសេចក្តីនេះ ប្រសិនបើមានមនុស្សល្អច្រើននាក់និងច្រើនអង្គ គឺជាការប្រសើរដ៏ក្រៃ-លែង ភូមិស្រុកនោះ គ្រួសារនោះ វត្តនោះ រមែងមានតែការចម្រើនទៅមុខ គ្មានថយក្រោយឡើយ ។

ការថែរក្សាគ្រប់គ្រង ព្រមជាមួយនឹងការចិញ្ចឹមមនុស្ស ដើម្បីសាងឱ្យបានទៅជាមនុស្សល្អមាននូវគុណ-ភាពនោះ គឺពិតជាមិនងាយដូចសាងវត្ថុឡើយ អ្នកសាងត្រូវចេះអត់ធន់ ចេះលះបង់ ទាំងត្រូវចេះត្រៀមចិត្តក្នុងការទទួលផលមិនល្អ ដើម្បីកុំឱ្យខូចចិត្ត ជាពិសេសគឺមាតាបិតាដែលប្រាថ្នាតែកូនល្អនោះឯង ។



ទោះជាយ៉ាងណាក៏ដោយ ការសាងមនុស្សពិតជាការងារសំខាន់បំផុត ។ ក្នុងរវាងការត្រាស់ដឹងនៃព្រះ-សម្មាសម្ពុទ្ធ ព្រះអង្គបំពេញពុទ្ធកិច្ចក្នុងការសាងមនុស្ស ។ ធម្មទានរបស់ព្រះអង្គឈ្នះអស់ទានទាំងពួង ព្រោះជាទានក្នុងការសាងចិត្ត សាងវិញ្ញាណរបស់មនុស្សនិងទេវតាឱ្យបានប្រសើរខ្ពង់ខ្ពស់ ធ្វើឱ្យគ្រប់គ្នាមានការយល់ត្រូវ ជាក់-ច្បាស់ចំពោះការពិត ឈ្នះនូវទុក្ខទាំងពួងបាន ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា « លាភសក្ការៈតែងតែសម្លាប់នូវបុគ្គលល្ងង់ខ្លៅ » ។ ដូច្នេះក្នុងរយៈពេលដែលកំពុងស្ថិតនៅក្នុងការសាងមនុស្ស ត្រូវប្រយ័ត្នរឿងលាភសក្ការៈមាសប្រាក់និងសម្ភារៈផ្សេងៗ ។ កាលណាបើមាតាបិតាជាដើម ចេះតែផ្តល់ប្រគល់ឱ្យតាមចិត្តកូនចង់ ពុំនោះសោតទេ គឺបង្រៀនកូនឱ្យចេះចាយធំឱ្យចេះហ៊ឺហាដោយអលង្ការ ដោយសំពត់ខោអាវ និងដោយសម្ភារៈផ្សេងៗ ដែលលើសហួសពីការចាំបាច់នោះឱកាសដែលនឹងធ្វើឱ្យខូចកូនគឺមានច្រើន ។ មិនមែនថា

បើអីចឹងកូនអ្នកក្រ សុទ្ធតែបានល្អទៅនោះឡើយ ចំណុចចាំបាច់សំខាន់បំផុតក្នុងការសាងមនុស្ស គឺសាងគុណធម៌ ជួយអប់រំ ជួយបណ្ដុះបណ្ដាលនូវអំណត់អត់ធន់ សេចក្ដីព្យាយាម សេចក្ដីសន្ដោស មេត្តាករុណាជាដើម ឱ្យមានក្នុងមនុស្សនោះៗ មានកូនចៅជាដើមហ្នឹងឯង ។

គំនិតជាសភាវៈសំខាន់ណាស់ មានឥទ្ធិពលក្នុងការផ្លាស់ប្ដូរដំណើរនៃជីវិតរបស់ខ្លួន ផ្លាស់ប្ដូរសង្គមឱ្យទៅតាមគំនិតបាន ។ ដូចជាគំនិតរបស់មនុស្សសព្វថ្ងៃ សម្លឹងឆ្ពោះទៅរកការចម្រើនផ្នែកវត្ថុ ឱ្យជាទិសដៅនៃជីវិត មានការស្វែងរកវត្ថុឱ្យជាចំណុចសំខាន់ យកវត្ថុមកជាគ្រឿងវាស់សេចក្ដីសម្រេចនៃជីវិត ម្ល៉ោះហើយ សង្គមលោកទាំងមូលក៏ផ្លាស់ប្ដូរ ដោយផ្អៀងទៅរកខាងវត្ថុ ខ្វាយខ្វល់ទៅនឹងវត្ថុសម្ភារៈ ទំនងដូចជាដើមចេកដែលចេញត្រយូងមានផ្លែ ។

ប្រសិនបើការគិតរបស់មនុស្ស ប្រព្រឹត្តទៅរកសេចក្ដីចម្រើនខាងផ្នែកចិត្តវិញ្ញាណវិញ មនុស្សរមែងមាន



គុណធម៌ជាទិសដៅ ស្វែងរកការចម្រើនផ្លូវចិត្តជាការសំខាន់ លើកតម្កើងនិងរាប់អានចំពោះអ្នកដែលមានចិត្តប្រសើរខ្ពស់ សង្គមលោកនឹងចម្រើនទៅដោយអរិយធម៌ ឯការខ្វាយខ្វល់ ក្រហល់ក្រហាយក្នុងចិត្តរបស់មនុស្ស ក៏នឹងថយចុះដែរ ។

ដូច្នេះ អ្នកដែលសាងមនុស្សទាំងឡាយ គប្បីសាងនូវសម្មាទិដ្ឋិគំនិតយល់ត្រូវ និងគុណធម៌ផ្សេងទៀត ឱ្យចម្រើនក្នុងមនុស្ស ទើបឈ្មោះថាជាអ្នកសាងលោកពិតប្រាកដ ។

## ១៨-បញ្ជាក់អត្ថន័យក្នុងពាក្យផ្សេងៗ

ពាក្យថា « ខ្លួនទីពឹងខ្លួន » មិនមែនបានសេចក្តីថា មិនជួយគ្នានោះទេ ។ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់សម្តែងអំពីការជួយអ្នកដទៃ ដោយវិធីច្រើនបែប ច្រើនយ៉ាងណាស់ ជាពិសេសគឺព្រះអង្គផ្ទាល់ ដែលមានពុទ្ធកិច្ចជួយសត្វលោក ដោយមិនមានអ្នកណាប្រៀបប្រដូចបាន។ ឯពាក្យថា « ខ្លួនទីពឹងខ្លួន » នេះ គឺមានអត្ថន័យថាត្រូវព្យាយាមកម្ចាត់បង់នូវកិលេសក្នុងសន្តានដោយខ្លួនឯង ព្រោះថា អ្នកដទៃមិនអាចមកធ្វើនូវកិច្ចការនេះ ជំនួសយើងបានឡើយ ។ កិច្ចការនេះអាចនិយាយបានថា ការទូន្មាន ឬការធ្វើឱ្យខ្លួនឯងបរិសុទ្ធ ។ បុគ្គលដែលទូន្មានខ្លួន ធ្វើឱ្យខ្លួនឯងបានស្អាតបរិសុទ្ធពិតៗ គឺជាការបាននូវទីពឹងក្នុងការរួចចាកទុក្ខទាំងពួង ជាទីពឹងដែលគេបានដោយកម្រ ។

ពាក្យថា « ធ្វើល្អបានល្អ » គេច្រើនតែកាន់យក



សេចក្តីថា « ធ្វើល្អបានផលល្អ » ( លាភ យស សរសើរ និងកាមសុខ គេចាត់ថាជាផលល្អក្នុងទីនេះ ) លុះដល់គេមិនបានឃើញផលល្អតបស្នង បែរជាទទួលរឿងមិនល្អ ដោយប្រការផ្សេងៗវិញ គេក៏អស់ជំនឿឬក៏គេគិតថាធ្វើល្អក្របានផលណាស់... ។ ពាក្យថា « ធ្វើល្អបានល្អ » ពិតមែនថាសំដៅដល់ការបានផលល្អដែរហើយ ប៉ុន្តែអ្វីដែលល្អជាងផលល្អដែលជាលាភ យស សរសើរ និងកាមសុខទៅទៀតនោះ គឺសេចក្តីល្អហ្នឹងឯង ។ សេចក្តីល្អ ល្អជាងភពភូមិឋានណាៗទាំងអស់ ព្រោះជាសេចក្តីល្អរបស់ចិត្ត ជាគុណសម្បត្តិប្រព្រឹត្តទៅជាបារមី ជាគុណជាតិកម្ចាត់បង់បាបក្នុងសន្តាន មានតម្លៃកាត់ថ្លៃមិនបាន កាលណាបើសេចក្តីល្អនោះប្រកបដោយបញ្ញាផង ។ ឯពាក្យថា « ធ្វើបុណ្យបានបុណ្យ » ក៏មានអត្ថន័យដូចគ្នាដែរ ព្រោះបុណ្យគឺជាសេចក្តីល្អហ្នឹងឯង ។

ពាក្យថា « ធ្វើបាបបានបាប » មានមនុស្សមួយចំនួនយល់ថា « ធ្វើបាបបានលុយ » ។ ពិតមែនហើយ

ធ្វើបាបបានលុយ តែហ្នឹងគឺជាការលក់ខ្លួន លក់បុណ្យ លក់ឧត្តមគតិ លក់សិរីសួស្តី ប្តូរយកបាបអពមង្គល និងសេចក្តីក្តៅក្រហាយមកដង្ហែជីវិត ។ អ្វីៗដែលបានមកពីការធ្វើបាប ដូចជាមាសប្រាក់និងសេចក្តីសប្បាយផ្សេងៗជាដើម ត្រូវបានអស់ទៅ ឋិតនៅតែអារម្មណ៍ដែលនាំឱ្យសៅហ្មងចិត្ត ជាពិសេសត្រូវបានរស់នៅជាមួយនឹងខ្លួនឯងជាមនុស្សអាក្រក់ ។

ពាក្យថា « ទុក្ខសច្ច » មិនមែនព្រះពុទ្ធអង្គទ្រង់សម្តែងឱ្យមនុស្សយើងកើតទុក្ខទេ ពាក្យនេះបញ្ជាក់ពីចំណុចចាប់ផ្តើមក្នុងការរំលត់ទុក្ខ ព្រោះទុក្ខសច្ចត្រូវកំណត់ដឹង ។ មនុស្សយើងតែងស្វែងរកការសប្បាយដើម្បីបំភ្លេចទុក្ខ តែនេះគឺយើងភ្លេចទុក្ខដោយខ្លួនឯងតែប៉ុណ្ណោះ ឯចំណែកទុក្ខវិញនោះ មិនបានបំភ្លេចយើងទេ ពោលគឺទុក្ខមិនបានបាត់បង់ទៅណាឡើយ ។ ដើរក្នុងព្រៃបន្លា ដោយបិទភ្នែកព្រោះខ្លាចបន្លាមុត វាជារឿងឡប់សតិយ៉ាងណា សត្វលោកខ្លាចទុក្ខក្នុងវដ្តសង្សារ តែមិនមើល



ឱ្យឃើញទុក្ខ នេះជាការល្ងង់ខ្លៅ អង្គធម៌បានដល់អវិជ្ជា ។ ការកំណត់ដឹងនូវទុក្ខ រមែងឃើញទុក្ខព្រមទាំងហេតុ ឯផលសម្រេចគឺជាសុខ ប្រៀបដូចឃើញបន្លាហើយ មិនជាន់បន្លា ដូច្នោះឯង ។ ជាធម្មតា បន្លាមិនដែលមកមុតយើងទេ មានតែយើងទេដែលដើរជាន់បន្លានោះ ។

ពាក្យថា « និព្វាន » ជាពាក្យដែលគួរនាំយកមកនិយាយគ្នាជាទូទៅពេញពិភពលោក ព្រោះនិព្វានជាទិសដៅនៃមនុស្សគ្រប់គ្នា ។ ព្រះនិព្វានគឺជាទីបញ្ចប់នៃបញ្ហា ជាការអស់ទៅនៃទុក្ខ ដែលមនុស្សគ្រប់គ្នាអាចសម្រេចបាន ព្រោះការរំលត់នូវតណ្ហា ។ មនុស្សយើងដែលមានការប្រាថ្នា មានការចម្រើននូវតណ្ហា ត្រូវការយ៉ាងនេះត្រូវការយ៉ាងនោះ ក៏ព្រោះតែចង់ដោះស្រាយនូវបញ្ហាហ្នឹងឯង ដោយយល់ថា បញ្ហានៅត្រង់ការមិនមានឬខ្វះនូវរបស់នោះៗ ប៉ុន្តែតាមពិត បញ្ហាដែលថាមិនមានឬខ្វះនោះ ព្រោះតែមានតណ្ហាទេតើ ប្រសិនបើមិនមានតណ្ហាទេ សេចក្តីដឹងខ្លួនថាខ្វះខាតក្នុងចិត្ត ឬទុក្ខកង្វល់

ព្រោះការខ្វះខាតរមែងមិនមានដោយពិតប្រាកដ។ មនុស្សយើងដែលមិនដឹង តែងតែយកតណ្ហាមកដោះស្រាយបញ្ហា តែនេះវាជាការចម្រើនកពូននូវបញ្ហាទៅវិញទេ ដោយសារការចម្រើននូវតណ្ហាច្រើនឡើងៗ ក្នុងចិត្តមនុស្សខ្លួនឯងរាល់ថ្ងៃ ។

មនុស្សក្នុងពិភពលោក កំពុងតែធ្លាក់ចូលទៅក្នុងរណ្តៅនៃតណ្ហា ព្រោះតែមិនរង្កៀសចំពោះតណ្ហាក្នុងខ្លួនម្នាក់ៗ ថែមទាំងជ្រោមជ្រែង ប្រព្រឹត្តទៅដើម្បីប្រកួតប្រជែងគ្នាសព្វបែបសព្វយ៉ាងទៀតផង ។

ដូច្នេះ ពាក្យថា « និព្វាន » ជាពាក្យនិយាយអំពីការអស់ទុក្ខ អស់កង្វល់ និយាយអំពីសន្តិភាពក្នុងមនុស្សម្នាក់ៗ និងសន្តិភាពក្នុងពិភពលោក ។ ដើម្បីដោះស្រាយបញ្ហានៅក្នុងពិភពលោក មនុស្សគួរតែយកចិត្តទុកដាក់និយាយគ្នាអំពីនិព្វាន ដែលជាអរិយសច្ចៈដ៏សំខាន់ និងដែលមានពិតប្រាកដជា **ទុក្ខនិរោធ** ។



## ១៩-អនត្តានិងកម្ម

មានសំនួរសួរថា បើមិនមានខ្លួនទេ តើអ្នកណាធ្វើបុណ្យ ? តើអ្នកណាទទួលផលបុណ្យ ? និងតើអ្នកណាទៅព្រះនិព្វាន ?

### ចម្លើយ

ពុទ្ធបរិស័ទយើងបានស្តាប់ឮពាក្យថា « អនត្តា ប្រែថា មិនមែនខ្លួន » ប៉ុន្តែដោយមិនបានឃើញនូវខន្ធ ៥ គឺរូបក្ខន្ធ ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ និងវិញ្ញាណក្ខន្ធ១ តាមពិត ដែលមិនមែនជាសត្វបុគ្គលតួខ្លួនមែននោះ ក៏កើតទៅជាមានការឆ្ងល់ក្នុងបញ្ហានេះឡើង ។

ប្រសិនបើបានឃើញនូវខន្ធ ៥ ដែលជាជីវិតនេះតាមសេចក្តីពិតហើយ ការឆ្ងល់អំពីអ្នកនេះ អ្នកនោះទៀតមិនមានឡើយ ។

ដោយបរមត្ថសច្ចៈ បុណ្យក្តី បាបក្តី ជាធម្មជាតិអាស្រ័យបច្ច័យកើតឡើង មិនមានអ្នកណាចាំបាច់មកធ្វើ

បុណ្យឬបាបនេះឱ្យកើតឡើងនោះទេ ប្រៀបដូចការកើតឡើងនៃផ្លេកបន្ទោរ ឬឥន្ទធនូ ដូច្នោះឯង ។ បុណ្យនិងបាប សុទ្ធតែជាតួកម្ម កាលបើមានឱកាសដ៏សមគួរហើយ ក៏ជាបច្ច័យញ៉ាំងផលវិបាកឱ្យកើតឡើង ។ ដំណើរជីវិតគឺជាក្រសែនៃសង្ខារធម៌សុទ្ធ ដែលកើតបន្តគ្នាប្រៀបដូចជាអណ្តាតភ្លើងដែលចេះតែឆេះត។គ្នា ដរាបណាដែលនៅតែមានអុសដាក់សម្រាប់ឱ្យឆេះនោះឯង ។

ដោយសម្មតិសច្ចៈ ក៏មានការសន្មតនូវក្រសែនៃសង្ខារធម៌សុទ្ធនោះៗ មួយខ្សែៗ ក្នុងសង្សារវដ្តនេះ ថាជាបុគ្គលនេះឬបុគ្គលនោះអ៊ីចឹងទៅ ។ ទោះជាសន្មតថាអ្នកនេះធ្វើកម្ម ឬអ្នកនោះទទួលផលកម្ម ក៏មិនមានសភាវធម៌អ្វីបន្ថែមពីលើបរមត្ថសច្ចៈទៀតដែរ វានៅត្រឹមតែជាក្រសែនៃសង្ខារធម៌សុទ្ធដដែល គឺកិលេសនាំឱ្យកើតកម្ម ឯកម្មនាំឱ្យកើតផលវិបាក រួចហើយព្រោះការមិនដឹងគឺអវិជ្ជាក៏បង្កនូវកិលេស... សភាពបែបនេះបន្តគ្នាអស់កាលដ៏យូរអង្វែងមកហើយ ដែលមិនអាចដឹងទីបំផុតខាងដើម ។



និព្វាន គឺអស់កិលេស អស់កម្ម អស់ផលវិបាករបស់កម្ម អស់ទុក្ខ អស់បញ្ញា អស់ក្រសែនៃសង្ខារអស់ការតាក់តែងដោយហេតុដោយបច្ច័យ ។ ព្រោះការអស់ទៅយ៉ាងនេះឯងទើបមានការសន្មតថា បុគ្គលបានដល់នូវព្រះនិព្វាន ។ ដែលថាបុគ្គល គឺសន្មតទៅលើក្រសែនៃសង្ខារធម៌ដដែលហ្នឹងឯង តែនេះមកអំពីខ្សែនៃសង្ខារ-ធម៌នោះត្រូវដាច់ កិលេសត្រូវអស់ ទុក្ខត្រូវរលត់ ។

ក្រសែរបស់សង្ខារធម៌ ជាតួបរមត្ថប្រព្រឹត្តទៅតាមច្បាប់ធម្មតា តាមហេតុតាមបច្ច័យនៃសង្ខារធម៌នោះឯង ចំណុចសំខាន់គឺមានការដឹងទាន់ ហើយចែកសម្មតិឱ្យដាច់ចេញពីបរមត្ថ ។ ពេលណាដែលយើងនិយាយដល់បរមត្ថក៏និយាយទៅតាមបរមត្ថ ពេលណាត្រូវប្រើសម្មតិ ក៏និយាយទៅតាមសម្មតិ គឺកុំឱ្យច្របូកច្របល់ន័យសេចក្តីគ្នា និងត្រូវយល់អំពីបរមត្ថ មានស្មារតីរលឹកដឹងនូវសភាវធម៌ជាគោលជំហរឬជាភូមិឋាន ទោះជាពោលអំពីរឿងរ៉ាវសត្វបុគ្គល ក៏មិនប្រឡាក់ដោយទិដ្ឋិគឺការយល់ខុសដែរ ។

ទាំងបរមត្ថ ទាំងសម្មតិ សុទ្ធតែចាំបាច់ទាំងអស់ ។ បរមត្ថជាសភាវៈរបស់ធម្មជាតិ ចំណែកសម្មតិជារឿងមានប្រយោជន៍ សម្រាប់ការរស់នៅរបស់មនុស្សទាំងឡាយ ប៉ុន្តែ បញ្ហាកើតឡើង ព្រោះមនុស្សយើងយកបរមត្ថមកច្របូកច្របល់ជាមួយនឹងសម្មតិ គឺចូលទៅប្រកាន់យកតួបរមត្ថឱ្យប្រព្រឹត្តទៅតាមសម្មតិ ទើបកើតភាពវឹកវរឡើង។

បរមត្ថធម៌មិនវឹកវរឡើយ ព្រោះវាប្រព្រឹត្តទៅយ៉ាងនោះឯង តាមប្រក្រតីធម្មតា មិនទាក់ទងនឹងអ្នកណាប្រកាន់ឬមិនប្រកាន់ឡើយ មានតែចំណែកខាងមនុស្សប៉ុណ្ណោះ ដែលវឹកវរក្រវាយក្រវល់ និងម្យ៉ាងទៀត ដោយមកអំពីបរមត្ថធម៌មិនបានវឹកវរផងហ្នឹងឯង ទើបមនុស្សរឹងរឹតតែវឹកវរឡើងៗ ព្រោះប្រឆាំងទាស់នឹងសេចក្តីប្រាថ្នាដែលមនុស្សលោកនេះ ចេះតែចង់ឱ្យយ៉ាងនេះ ចង់ឱ្យយ៉ាងនោះ ពោលគឺចង់កែប្រែធម្មជាតិ ម៉្លោះហើយបញ្ហាចេះតែកើតឡើងដល់ខ្លួនឯង ។



## ២០-អនត្តាទំនាស់ជាមួយកម្មឬទេ

អនត្តាធម៌ជាមួយនឹងកម្មមិនទំនាស់គ្នាឡើយ ផ្ទុយមកវិញអនត្តាមានការជ្រោមជ្រែងនូវកម្ម ព្រមទាំងបញ្ជាក់លក្ខណៈរបស់កម្មទៀតផង ។ ព្រោះធម៌ទាំងឡាយជាអនត្តា ទើបមានកម្មកើតឡើង កម្មកើតអំពីបច្ច័យផ្សេងៗ មានហេតុប្បច្ច័យ អារម្មណប្បច្ច័យ និងអធិបតិប្បច្ច័យជាដើម ក្នុងបណ្តាបច្ច័យទាំងអស់ មិនមានបច្ច័យណាជាអត្តាតួខ្លួនឡើយ គឺសុទ្ធតែជាអនត្តាទាំងអស់ ។ ចេតនាជាតួកម្ម កើតឡើងព្រោះអាស្រ័យបច្ច័យច្រើន ដូច្នេះ កម្មក៏ជាតួអនត្តាធម៌ផងដែរ ។

កាលបើក្រសែធម៌ប្រព្រឹត្តទៅ អង្គប្រកបគ្រប់យ៉ាងត្រូវកើតរលត់ ហើយមានទំនាក់ទំនងគ្នាជាហេតុ ជាផលបន្តគ្នាមិនដាច់ ។ ក្រសែដែលមានសម្ពន្ធភាពទាក់ទងគ្នាដោយហេតុដោយបច្ច័យ ដូច្នេះទើបប្រព្រឹត្តទៅបានដោយមិនមែនមានអ្វីមកជារបស់ឋិតថេរ ជាសត្វជាអត្តាទៀង-

ទាត់ក្នុងសង្សារវដ្ត មិនស្លាប់ មិនរលត់នោះឡើយ ។

បើមានអត្តា គឺមិនមានកម្ម និងមិនមានផលវិបាករបស់កម្មទេ ព្រោះអត្តា មិនប្រព្រឹត្តទៅតាមហេតុតាមបច្ច័យ តែក្នុងលោកនេះ ខន្ធលោកក្តី អាយតនលោកក្តី ធាតុលោកក្តី មានអ្វីដែលមានខ្លួនឯង មិនប្រព្រឹត្តទៅតាមហេតុតាមបច្ច័យនោះ ។ ការគិតយល់ប្រកបដោយសេចក្តីប្រកាន់ថា អត្តាមាន ជាតួសោយសុខ សោយទុក្ខ ជាអ្នកធ្វើកម្មនិងជាអ្នកទទួលផលកម្ម រហូតដល់អត្តាចូលដល់ព្រះនិព្វាន នេះគ្រាន់តែជាតួនាមធម៌មួយបែប មានផស្សៈជាបទដ្ឋាន និងមានអវិជ្ជាជាឧបនិស្សយប្បច្ច័យផង ជាហេតុប្បច្ច័យផង កើតឡើងប៉ុណ្ណោះ ជាសភាវៈមិនទៀងជាទុក្ខនិងជាអនត្តាផងដែរ ។ អ្វីដែលជាអត្តាពិតប្រាកដរមែងមិនមាន ដូចជាការមិនមាននៃស្នែងទន្សាយអ៊ីចឹងឯង ។

ដែលយើងគ្រប់គ្នាធ្វើកម្ម និងទទួលផលកម្មរាល់ថ្ងៃនេះ រមែងធ្វើកម្ម និងទទួលផលកម្ម ដោយមិនត្រូវមាន



មនុស្សអ្នកធ្វើ និងមិនត្រូវមានមនុស្សអ្នកទទួលឡើយ ។ ក្នុងសភាវធម៌ទាំងឡាយ ដែលប្រជុំរួមគ្នា និងប្រព្រឹត្តទៅជាក្រសែធម៌នោះ ត្រូវពិចារណាក្នុងផ្នែកដែលថា មានអ្វីខ្លះត្រូវចូលទៅជាបច្ច័យ អ្វីទាក់ទងជាមួយអ្វី ហើយមានផលអ្វីកើតឡើងក្នុងក្រសែនៃធម៌ទាំងនោះ និងហេតុដូចម្តេចបានជាក្រសែនៃធម៌មានការប្រែប្រួល ព្រមទាំងផ្លាស់ប្តូរភពភូមិកំណើតផ្សេងៗ ។

កាលមានហេតុ ដែលហៅថាកម្ម គឺការធ្វើកើតឡើងជាបច្ច័យ ក៏រមែងមានផលវិបាកកើតឡើងក្នុងក្រសែធម៌នោះឯង ។ ក្រសែធម៌នេះ វាដោយឡែកផ្សេងអំពីសម្មតិដែលយើងយកទៅបំពាក់ឱ្យនោះ។ យើងបានសន្មតហៅក្រសែធម៌ដែលប្រព្រឹត្តទៅនោះឯង ថាជាបុគ្គលនេះបុគ្គលនោះ រួចហើយយើងសន្មតគ្នាថា បុគ្គលនេះបុគ្គលនោះជាម្ចាស់នៃកម្ម ជាអ្នកធ្វើកម្មនិងទទួលផលកម្ម ប៉ុន្តែក្រសែធម៌ដែលជាតួសភាវៈ ជាបរមត្ថធម៌ រមែងប្រព្រឹត្តទៅតាមប្រក្រតីរបស់ខ្លួន ជាហេតុ ជាផលទៅព្រម

ស្រេចក្នុងខ្លួនឯង ដោយបរិបូណ៌គ្រប់គ្រាន់ហើយ មិនចាំបាច់អាស្រ័យបុគ្គលនេះ បុគ្គលនោះ ទើបមានហេតុមានផលកើតឡើងឡើយ ។

កាលបើត្រូវនិយាយក្នុងផ្នែក ក្រសែធម៌ ថាប្រព្រឹត្តទៅយ៉ាងណា ដោយហេតុអ្វី និងជាផលយ៉ាងណា ក៏និយាយទៅ ឬក៏ត្រូវនិយាយក្នុងផ្នែកបុគ្គលនេះ បុគ្គលនោះ ជាអ្នកធ្វើកម្មនោះហើយ ត្រូវទទួលផលកម្មយ៉ាងនេះ ក៏និយាយទៅ ។ បើនិយាយក្នុងផ្នែកសម្មតិ ក៏ឱ្យដឹងថា កំពុងនិយាយក្នុងផ្នែកសម្មតិ បើនិយាយអំពីបរមត្ថក៏ឱ្យដឹងថា កំពុងនិយាយក្នុងផ្នែកបរមត្ថ កាលបើដឹងតាមសេចក្ដីពិត ដឹងទិសដៅនៃការនិយាយបែបនោះៗ មិនប្រកាន់ដោយទិដ្ឋិ មិនច្របូកច្របល់ ដូច្នេះរមែងសម្រេចជាប្រយោជន៍ ទាំងអ្នកនិយាយទាំងអ្នកស្ដាប់ ។

ដោយបរមត្ថ អ្នកធ្វើកម្មមិនមាន អ្នកសោយផលកម្មក៏មិនមាន គឺមានតែធម៌សុទ្ធៗ ដែលប្រព្រឹត្តទៅជាសង្សារវដ្ដ ការឃើញយ៉ាងនេះ ទើបជាសម្មាទស្សនៈ ។



## ២១-គុណសម្បត្តិនៃពុទ្ធបរិស័ទល្អ

ពុទ្ធបរិស័ទល្អ គឺជាអ្នកសិក្សាស្រាវជ្រាវរាវរកសេចក្ដីពិត ត្រួតត្រាពិនិត្យនូវសេចក្ដីនៃព្រះពុទ្ធភាសិត ជាអ្នកយល់ដឹងនូវហេតុផលបានច្បាស់លាស់ រមែងមាននូវគុណសម្បត្តិដូចតទៅ :

១- ធ្ងន់ក្នុងហេតុផល ចេះមើលឃើញកម្ម និងផលវិបាករបស់កម្មទៅតាមទំនងនៃហេតុនៃបច្ច័យ មិនចេះតែជឿងាយៗ ហើយភ្ញាក់ផ្អើលទៅតាមពាក្យដែលគេឃោសនានោះឡើយ ។

២- យល់ត្រូវថា ផលសម្រេចដែលខ្លួនត្រូវការទិសដៅដែលខ្លួនប្រាថ្នានឹងទៅឱ្យដល់ រមែងសម្រេចបានដោយការចុះដៃធ្វើខ្លួនឯង ត្រូវពឹងលើខ្លួនឯង ពឹងលើការព្យាយាមព្រមដោយប្រាជ្ញាស្មារតី មិនរង់ចាំជោគជតារាសី ឬសង្ឃឹមផលដោយការអង្វរករ បួងសួងសែនព្រេនចំពោះអ្វីៗជាបច្ច័យខាងក្រៅឡើយ ។

៣. មានការទទួលខុសត្រូវចំពោះខ្លួនឯង ដោយការវៀរចាកនូវអំពើអាក្រក់ រក្សាខ្លួនដោយការមិនធ្វើបាប មិនមែនធ្វើអាក្រក់ហើយ ស្វែងរកវត្ថុខាងក្រៅឱ្យជួយលាងជម្រះ ឬរកអ្នកដទៃមកទទួលទោសជំនួសនោះទេ ។ ម្យ៉ាងទៀតមានការទទួលខុសត្រូវចំពោះអ្នកដទៃ ដោយការធ្វើនូវអំពើល្អដល់គេ ព្រោះថាសត្វលោកគ្រប់គ្នាធ្វើអ្វីៗគ្រប់យ៉ាងមកពីចង់បានសុខ ចង់បានប្រសើរ ដូច្នេះទើបត្រូវមានមេត្តាចំពោះសត្វលោកទាំងអស់ មិនត្រឹមតែប៉ុណ្ណោះ ក្នុងបណ្តាសត្វលោកទាំងនោះ មានអ្នកមានគុណដោយប្រការផ្សេងៗ រាប់មិនអស់ផងដែរ ទើបត្រូវមាននូវកតញ្ញូតាធម៌ ដែលជាផ្នែកទទួលខុសត្រូវចំពោះអ្នកដទៃយ៉ាងពិសេស ។

៤. យល់ត្រូវថា មនុស្សមានសិទ្ធិដោយធម្មជាតិដើម្បីនឹងធ្វើការផ្សេងៗក្នុងការសាងខ្លួនឯងឱ្យបានល្អឡើងរហូតដល់ថ្នាក់ប្រសើរជាងទេវតាឥន្ទព្រហ្មទៅទៀត ។

៥. យល់ត្រូវថា គុណធម៌ក្តី សមត្ថភាពក្តី ការ



បដិបត្តិក្តី គឺជាគ្រឿងវាស់នូវភាពប្រសើរ ឬភាពអន់ថយរបស់មនុស្ស មិនមែនបែងចែកទៅតាមការប្រកាន់វណ្ណៈនោះឡើយ ។

៦. មិនចេះតែសម្លឹងមើលទៅទោសអ្នកដទៃនោះទេ គឺមានការសិក្សាចំពោះជីវិត ឃើញច្បាស់នូវកម្មចាស់ដែលឱ្យផលក្នុងបច្ចុប្បន្ន កំណត់យកជាការរៀនសូត្រ ពោលគឺចេះពិចារណា យល់ខ្លួនឯងតាមហេតុផល ។

៧. មានការសម្លឹងមើលភូមិឋាន គឺចិត្តសន្តានរបស់ខ្លួនដែលមាននៅក្នុងបច្ចុប្បន្ន ផ្នែកណាដែលមិនល្អ ក៏ហ្វឹកហាត់កែប្រែបន្តិចម្តងៗ រៀបចំដាក់ផែនការកម្ចាត់បាបអកុសលឱ្យអស់ពីសន្តាន បើផ្នែកណាដែលល្អ ក៏ចេះតែសន្សំចម្រើន កពូននូវគុណធម៌ យកគុណធម៌ជាខ្លឹម-សារនៃជីវិត ។

៨. មានការដឹងច្បាស់ថា វាមិនមានអនាគតជាតិណា ក្រៅអំពីការបន្តទៅនៃចិត្តមួយខណៈៗនេះឡើយ ដូច្នេះហើយ អំពើល្អទាំងប៉ុន្មានដែលចិត្តបានសន្សំ គឺជា

ការសាងនូវគុណភាពរបស់ចិត្ត ឬគុណភាពនៃជីវិត ធ្វើឱ្យជីវិតដែលបន្តរហូតទៅមុខដល់ជាតិក្រោយ ជាជីវិតដែលល្អក្រៃលែងឡើងៗ ។ តាមពិតមិនមានការរីករាយណាក្នុងដំណើរជីវិតឱ្យដូចការរួមដំណើរជាមួយនឹងខ្លួនឯង ដែលជាមនុស្សល្អនោះទេ ។

៩. មានការថែរក្សានូវគុណធម៌ផ្សេងៗ ដូចជាគេរក្សានូវទ្រព្យដ៏មានតម្លៃ ពុំនោះសោត គឺដូចជាការរក្សាកូនចៅ អវយវៈនិងអាយុជីវិតរបស់ខ្លួនជាដើម ។ តាមពិតកិលេសដែលនៅមិនទាន់បានលះ វាអាចឱ្យយើងទៅជាមនុស្សអាក្រក់បាន ប៉ុន្តែដោយសារយើងរក្សាធម៌ ទើបធម៌រក្សាមិនឱ្យយើងទៅជាមនុស្សអាក្រក់ហ្នឹងឯង ។

១០. ឧស្សាហ៍ព្យាយាម ទទួលយកនូវព្រះពុទ្ធវចនៈមកដាក់ខ្លួន ព្រោះបានដឹងថា មិនមានសម្បត្តិអ្វីដែលមានតម្លៃឱ្យដូចជា ការត្រាស់ដឹងនៃព្រះសម្មាសម្ពុទ្ធឡើយ ។



## ២២-ទ្រទ្រង់ព្រះពុទ្ធសាសនា

នៅក្នុងអដ្ឋកថា **បាបិច្ឆតានិទ្ទេស ខុទ្ទកវត្ថុវិភង្គ** គម្ពីរព្រះអភិធម្ម បានសម្តែងថា : បុគ្គលដែលមានបញ្ញាអន់ថយ មានការអង្គុយនៅកណ្តាលបរិស័ទជាឧបដ្ឋាកទាំងឡាយ ហើយបានពោលថា « យើងរមែងលះបង់នូវបរិយត្តិ »ដូច្នេះជាដើម ។(ចំពោះពាក្យទាំងស្រុង ដូចជាពោលថា ) កាលដែលយើងត្រួតមើលពួក ៣ នៃធម៌ដែលញ៉ាំងសត្វឱ្យយឺតយូរ (តណ្ហា មានះ ទិដ្ឋិ ) មគ្គនោះឯងមកហើយព្រមដោយឫទ្ធិ។ឈ្មោះថាបរិយត្តិ មិនជារបស់ដែលធ្វើបានដោយលំបាកសម្រាប់ពួកយើងទេ តែការចូលចិត្តធ្ងន់ចិត្តទៅក្នុងបរិយត្តិ រមែងមិនរួចផុតចាកទុក្ខឡើយ ។

ការពោលដូចនេះ គឺមានសេចក្តីប្រាថ្នាសម្តែងខ្លួនឱ្យស្តែងថាខ្លួនជាមនុស្សមានបញ្ញាច្រើន ។ ការដែលភិក្ខុនោះពោលដូចនេះ ឈ្មោះថា ទម្លាយព្រះពុទ្ធសាសនា ។ម្យ៉ាងទៀត ឈ្មោះថា មហាចោរដូចជាបុគ្គលនេះ រមែង

មិនមានទៀតឡើយ ព្រោះថា អ្នកទ្រទ្រង់នូវព្រះបរិយត្តិ-ធម៌ រមែងមិនរួចផុតចាកទុក្ខនោះ គឺរកមិនមានទេ ។

សេចក្ដីនៅក្នុងគម្ពីរ ដែលបានដកស្រង់យកមកនេះ យើងគួរយល់ដូចតទៅ :

១.ទ្រទ្រង់នូវបរិយត្តិធម៌ គឺទ្រទ្រង់ព្រះសម្មាសម្ពុទ្ធ ព្រោះព្រះធម៌ដែលព្រះអង្គសម្ដែងហើយ វិន័យដែលព្រះ-អង្គបញ្ញត្តហើយ ជាព្រះសាស្ដាបន្ទាប់ពីព្រះអង្គទ្រង់បរិនិព្វានទៅ ។

២.ទ្រទ្រង់នូវព្រះបរិយត្តិធម៌ គឺទ្រទ្រង់នូវព្រះ-ធម្មរតនៈ ដែលជារតនៈដ៏ឧត្ដមក្នុងលោក ធ្វើឱ្យគង់វង្សនូវព្រះពុទ្ធសាសនា ។

៣.ទ្រទ្រង់នូវព្រះបរិយត្តិធម៌ គឺទ្រទ្រង់នូវព្រះ-សង្ឃរតនៈ ព្រោះបើមិនមាននូវព្រះបរិយត្តិធម៌ទេ ព្រះ-សង្ឃក៏មិនមានដែរ ។

៤.ទ្រទ្រង់នូវព្រះបរិយត្តិធម៌ គឺទ្រទ្រង់នូវការងាររបស់សង្ឃគ្រប់សង្កាយនាទាំងអស់ មានបឋមសង្គាយនា



ជាដើម ជាការងារដ៏ធំធេងក្នុងព្រះពុទ្ធសាសនា ។

៥.ទ្រទ្រង់នូវព្រះបរិយត្តិធម៌ គឺទ្រទ្រង់នូវគុណ-សម្បត្តិរបស់ពុទ្ធបរិស័ទ ដែលព្រះសម្មាសម្ពុទ្ធទុកដាក់នូវព្រះសាសនាឱ្យ ហើយទើបដាក់នូវព្រះជន្មាយុសង្ខារ ។

៦.ទ្រទ្រង់នូវព្រះបរិយត្តិធម៌ គឺទ្រទ្រង់នូវព្រះធម្ម-ចេតិយដ៏ជាទីគោរពក្រៃលែង ។

៧.ទ្រទ្រង់នូវព្រះបរិយត្តិធម៌ គឺទ្រទ្រង់នូវព្រះ-សទ្ធម្មទាំង ៣ គឺបរិយត្តិសទ្ធម្ម បដិបត្តិសទ្ធម្ម និងបដិវេធសទ្ធម្ម ព្រោះបើមិនមានបរិយត្តិទេ បដិបត្តិមិនមានឡើយ ឯអរិយមគ្គអង្គ ៨ សម្រាប់អរិយសាវ័កក៏មិនមានដែរ ។

៨.ទ្រទ្រង់នូវព្រះបរិយត្តិធម៌ គឺទ្រទ្រង់នូវសីល សមាធិ បញ្ញា ព្រោះជាការទ្រទ្រង់នូវព្រះវិន័យបិដក សុត្តន្តបិដក និងអភិធម្មបិដក ។

សូមពុទ្ធបរិស័ទជ្រាបថា បើមិនមានព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកទេ គឺមិនមានព្រះពុទ្ធសាសនាស្ថិតនៅក្នុងលោកឡើយ ។

## ២៣-បណ្ដុះពូជមេត្តា

នៅពេលភ្លៀងធ្លាក់ជាបន្តបន្ទាប់ ផែនដីទទួលទឹកជ្រួតជ្រាបសព្វ បណ្ដាគ្រាប់ពូជទាំងឡាយក៏បានដុះ រុក្ខ-ជាតិដែលស្វិតស្រពោន និងដែលជ្រុះស្លឹកអស់ ក៏ប្រែជាស្រស់ និងលាស់ស្លឹកខៀវខ្ចី មានលំពង់មានត្រួយ គួរឱ្យគយគន់ហើយសប្បាយចិត្ត ។ ពូជដុះព្រោះទឹក រុក្ខជាតិល្អស្លឹក ព្រោះមានភ្លៀង ។

មានពូជមួយបែបទៀត ដែលត្រូវអាស្រ័យទឹកដូចគ្នាដែរ ប៉ុន្តែជា « ទឹកចិត្ត » មិនមែនជាទឹកភ្លៀងទេ ព្រោះថាពូជនោះគឺពូជមេត្តា ។

មេត្តា ក៏ដូចជាពូជដទៃៗទៀតដែរ ព្រោះត្រូវដាំត្រូវបណ្ដុះក្នុងផែនដី គឺចិត្តសន្តានហ្នឹងឯង ដូចពាក្យថា :

បណ្ដុះពូជឈើនៅលើដី បណ្ដុះមេត្រីនៅក្នុងចិត្ត
ស្រោចទឹកមេត្តាកុំឱ្យស្វិត ថែកុសលពិតកុំឱ្យរោយ ។

ការបណ្ដុះបណ្ដាលនូវមេត្រីភាព ក្នុងចិត្តសន្តាន



បានដល់ បំណងល្អ គិតល្អ ប្រាថ្នាល្អ ដើម្បីអ្នកដទៃរស់នៅជាសុខ គឺជាការប្រាសចាកនូវការបៀតបៀន និងបំណងអាក្រក់ផ្សេងៗទៅរកអ្នកដទៃនោះៗ ។

បុគ្គលដែលមានចិត្តពេញទៅដោយមេត្តា រមែងសាងតែមិត្តនៅជុំវិញខ្លួន ឬនៅគ្រប់ទិស គ្រប់ស្ថានម្ល៉ោះហើយ បុគ្គលនោះទើបមានតែអ្នកដែលស្រឡាញ់រាប់អានដោយទូទៅ ហើយមិនមានចាត់ទុកអ្នកណាជាសត្រូវឡើយ រស់នៅដោយចិត្តត្រជាក់ ប្រាសចាកពៀរ ប្រាសចាកចិត្តព្យាបាទ ។ ទាំងអស់នេះ រមែងបានសម្រេចមកអំពីពូជមេត្តា ដែលខ្លួនបានបណ្ដុះទុកហើយដោយល្អ និងបានស្រោចទឹកជាប្រចាំហ្នឹងឯង ។

> មិត្តសម្លាញ់រមែងនាំសុខមកឱ្យ
> នៅពេលមានការអ្វីមួយ

## ២៤-ទន់ភ្លន់

បាយដែលបរិភោគទទួលទាន បើរឹងស្រួយពេកទៅ ក៏គេលំបាកទំពា លំបាកលេប ឯសំពត់អាវស្លៀកពាក់វិញ បើសាច់គ្រោតគ្រាតខ្លាំង ក៏មិនមានអ្នកណានិយមស្លៀកពាក់ដែរ ។ បាយដែលគេនិយមបរិភោគ គឺបាយទន់មានជ័រ ល្មមល្មៃ មិនជ្រាយពេក មិនស្រួយពេក និងមិនឆៅ ឯសំពត់អាវ គឺគេត្រូវការសំពត់សាច់ម៉ដ្ឋ សាច់ទន់ល្អល្អិតស្លៀកពាក់ទៅសប្បាយកាយ ។ សេចក្ដីនោះយ៉ាងណា ចំពោះមនុស្សយើងដែលមានកិរិយារឹងៗគ្រោតគ្រាត មិនចេះទន់ភ្លន់ មានពាក្យសម្ដីមិនសុភាពរាបសា រមែងមិនមានបុគ្គលណានិយមចូលចិត្តរាប់រកឡើយ ព្រោះរឿងគ្រោតគ្រាត ច្រងេងច្រងាង មិនទន់ភ្លន់ មិនរាបសា រមែងមិនជាការពេញចិត្តរបស់មនុស្សដោយទូទៅ ។

កិរិយាទន់ភ្លន់ វាចាសុភាពជាស្នេហ៍ដ៏ប្រសើរធ្វើឱ្យមនុស្សនិយមចូលចិត្តស្និទ្ធស្នាល ដូចបាយល្អមានរសជាតិ



គួរដល់ការទទួលទាន និងដូចសំពត់សាច់ម៉ដ្ឋ ទន់ល្មៃ ដែលជាទីពេញនិយមនៃមនុស្សទាំងឡាយដូច្នោះឯង ។

ដោយហេតុនេះ មនុស្សដែលមានកិរិយាមារយាទល្អ និងមានពាក្យសម្ដីទន់ភ្លន់ រាបសា ដូចផ្កាក្រអូប ឬផ្អែមល្ហែមដូចទឹកឃ្មុំ ទើបមានប្រៀបលើមនុស្សដែលរឹងគ្រោតគ្រាត ខាងផ្នែកចរិយាមារយាទ និងពាក្យសម្ដី ។

មនុស្សព្រហើនកោងកាចរមែងមានពៀរ

## ២៥-សម្បត្តិពិត

កាលនៅពីតូច យើងយល់ថា ខ្លួនយើងជាសម្បត្តិរបស់ឪពុកម្ដាយ ព្រោះលោកទាំងពីរនៅជិតដិតនិងថែទាំយើងដ៏ក្រៃលែង ។ តមកយើងក៏បានធំឡើង មានមិត្តមានភក្តិ យើងក៏យល់ថា យើងជាសម្បត្តិរបស់មិត្តភក្តិ ឬមិត្តភក្តិជាសម្បត្តិរបស់យើង ព្រោះមិត្តភក្តិបានឱ្យភាពលេងសប្បាយរីករាយ ភ្លើតភ្លើនដល់យើង ( មានកូនខ្លះចោលម៉ែ ចោលឪទៅតាមមិត្តភក្តិទៀតផង )។ លុះដល់វ័យដែលចេះស្រឡាញ់ផ្លូវភេទ និងមានមនុស្សណាដែលខ្លួនស្រឡាញ់ ក៏មានការយល់ជាថ្មីថា មនុស្សដែលជាទីស្រឡាញ់របស់យើង ជាសម្បត្តិដ៏សំខាន់ថ្លៃថ្លា ព្រោះជីវិតរបស់យើងនឹងមានសេចក្តីសុខ ក៏ដោយសារបាននៅរួមជាមួយបុគ្គលនោះៗ បើមិនបានបុគ្គលដែលជាទីស្រឡាញ់នោះទេ យើងរមែងមិនបាននូវសេចក្តីសុខឡើយ ។

លុះដល់គ្រាកាលបានគ្នាជាគូគ្រង ស្វាមីក៏យល់ថា



ភរិយាជាសម្បត្តិរបស់ខ្លួន រីឯភរិយាវិញ ក៏យល់ថា ស្វាមីជាសម្បត្តិរបស់ខ្លួនដូចគ្នា ។ ក្រោយមកក៏មានបុត្រធីតា ការដូរផ្លាស់ចិត្តក៏ចេះតែដូររហូតដែរ ឥឡូវក៏មានសេចក្តីដឹងខ្លួនជាថ្មីថា បុត្រធីតាគឺកូនប្រុសស្រី ទើបជាសម្បត្តិដ៏វិសេសវិសាលជាងអ្នកណាៗទាំងអស់ ។

នៅពេលដែលកូនៗធំឡើង ហើយបានបែកចាកពីទ្រូងម៉ែឪទៅមានគូគ្រងរៀងៗខ្លួន ភាពឯកោ ឬភាពស្ងាត់ជ្រងំក្នុងចិត្ត ក៏បានប្រាកដឡើងដល់ម៉ែ ដល់ឪយ៉ាងគួរឱ្យស្រងេះស្រងោច ព្រោះក្នុងរយៈពេលនេះអាយុរបស់ម៉ែឪក៏ត្រូវច្រើន ចូលដល់វ័យចាស់ ហើយត្រូវបានដូរផ្លាស់នូវការយល់ នូវសេចក្តីដឹងខ្លួនព្រមទាំងដូរផ្លាស់នូវសេចក្តីសង្ឃឹមក្នុងសម្បត្តិរបស់ខ្លួន មានតែការសង្ស័យថា « តើអ្វីជាសម្បត្តិរបស់ខ្លួនពិតប្រាកដ » ។

ដល់វ័យចាស់ជរា គួរឱ្យអាណិតម៉ែឪ ជាពិសេសម៉ែឪដែលត្រូវកូនបោះបង់ចោល ដូច្នេះទើបបានដឹងនូវសេចក្តីពិតថា « ខ្លួននេះឯងដែលជាសម្បត្តិរបស់ខ្លួន »

មិនមែនអ្នកដទៃទាំងឡាយ ដែលខ្លួនធ្លាប់សំដៅទៅរក ដោយសេចក្ដីសង្ឃឹមថា ជាសម្បត្តិរបស់ខ្លួននោះឡើយ ។ អ្នកដទៃគ្រប់គ្នាគេបានដូរផ្លាស់ទៅអស់តាមកាល តាមវ័យ និងទៅតាមកម្មរៀងខ្លួន តែខ្លួនរបស់យើងនៅជាប់ជាមួយ នឹងយើងជានិច្ច និងជាសម្បត្តិតាំងពីដើមរហូតមក ។

ខ្លួនយើងទើបជាសម្បត្តិរបស់យើង ព្រោះហេតុដូច្នេះ យើងត្រូវព្យាយាមយកសម្បត្តិសាងសម្បត្តិក្នុងវ័យនេះឯង គឺលែងគិត លែងប្រកាន់ទៅរកអ្នកដទៃ ដើម្បីចាប់យកមកជាសម្បត្តិរបស់ខ្លួនតទៅទៀត ហើយត្រូវព្យាយាមសាងបុណ្យកុសល ដែលជាគ្រឿងជាប់តាមខ្លួនទៅក្នុងទីគ្រប់ស្ថាន ព្រោះមានតែបុណ្យប៉ុណ្ណោះជាសម្បត្តិដែលល្អពិតរបស់ខ្លួន អ្វីៗដទៃទៀត មិនអាចជាប់តាមខ្លួនទៅផងបានឡើយ ។

**គួរធ្វើបុណ្យ ព្រោះបុណ្យនាំសុខមកឱ្យ**



## ២៦.សម្បត្តិស្ដេចចក្រពត្តិ

ស្ដេចចក្រពត្តិ ជាស្ដេចធំគ្រប់គ្រងលើពិភពនៃមនុស្សទាំងអស់ ប្រកបដោយសុចរិតធម៌ ហើយដឹកនាំពពួកជនឱ្យកាន់សីល ៥ បានទៀតផង ។ ព្រះអង្គមានរតនៈ ៧ ប្រការ :

១.ចក្ករតនៈ នាំចតុរង្គសេនាហោះទៅគ្រប់ទីកន្លែង

២.ហត្ថិរតនៈ ដំរីដែលអាចហោះបាន

៣.អស្សរតនៈ សេះដែលអាចហោះបាន

៤.មណីរតនៈ កែវមណីភ្លឺខ្លាំងពេលយប់

៥.ឥត្ថីរតនៈ មហេសីដ៏ល្អល្អះក្លិនក្រអូប

៦.គហបតិរតនៈ នាយឃ្លាំងដ៏ពូកែរកទ្រព្យ

៧.បរិនាយករតនៈ ព្រះរាជបុត្រច្បងគ្រប់គ្រងការងារ ជំនួសព្រះរាជបិតា ។

កាលបើស្ដេចចក្រពត្តិប្រព្រឹត្តធម៌ រតនៈ ៧ ប្រការក៏រមែងសម្រេចដោយបរិបូណ៌ ព្រះអង្គអាចផ្សាយនូវ

ព្រះតេជះឱ្យទូលំទូលាយទៅបាន រហូតគ្រប់ទិសទាំងពួង ហើយទ្រង់ក៏បានដល់ព្រមដោយរាជសម្បត្តិ តាមព្រះរាជ-ហឫទ័យ ។

គ្រប់គ្នា បើនឹងប្រៀបថាខ្លួនឯងជាស្តេចចក្រពត្តិ ក៏រមែងប្រព្រឹត្តទៅបានទាំងអស់គ្នា ព្រោះមានរតនៈដ៏វិសេសប្រចាំខ្លួនគ្រប់ទាំង ៧ មុខ ដែលមានអត្ថន័យដូចតទៅ :

១-ឥរិយាបថទាំង ៤ របស់មនុស្សយើង អាចប្រព្រឹត្តទៅបានក្នុងកិច្ចការងារ នេះចាត់ទុកជាចក្ករតនៈ។

២-ជើងស្តាំចាត់ទុកជាហត្ថិរតនៈ ។

៣-ជើងឆ្វេងចាត់ទុកជាអស្សរតនៈ ។ ជើងទាំងពីរជាអវយវៈនាំរាងកាយទៅក្នុងទីផ្សេងៗតាមប្រាថ្នា ។

៤-កែវភ្នែកទាំងគូ ចាត់ទុកជាមណីរតនៈ ព្រោះអាចមើលអ្វីៗទាំងពួងឃើញ តាមដែលនិយាយថាភ្នែកភ្លឺ។

៥-សកលកាយ ចាត់ទុកជាឥត្ថីរតនៈ ព្រោះជាទីស្រឡាញ់ ជាទីឱបក្រសោប ថែរក្សាស្លៀកពាក់ប្រដាប់



ដោយអាភរណៈផ្សេងៗ ។

៦-ដៃទាំងពីរ ចាត់ទុកជាគហបតិរតនៈ ព្រោះត្រូវធ្វើការងារដើម្បីបានទ្រព្យសម្បត្តិ ។

៧-មាត់និងអណ្តាត ចាត់ទុកជាបរិនាយករតនៈ ព្រោះពោលស្តីឱ្យសម្រេចការងារ ។

រាងកាយនិងអវយវៈមួយមុខៗ ប្រៀបបាននឹងរតនៈដ៏វិសេសដោយប្រការដូច្នេះឯង ។

គ្រប់គ្នាគួររីករាយចិត្ត ព្រោះថាខ្លួនយើងមានរតនៈដ៏វិសេស ដូចជាសម្បត្តិរបស់ស្តេចចក្រពត្តិជាស្រេចហើយ ទើបគួរព្យាយាមប្រើរតនៈដែលមាន ដើម្បីរក្សា និងពង្រីកនូវនគរកាយរបស់ខ្លួនឯង ដែលមានអាណាខេត្តកំណត់ត្រឹមទទឹង ១ ហត្ថ បណ្តោយ ១ ព្យាម និងកម្រាស់ ១ ចំអាម ឱ្យរុងរឿង និងសុខសប្បាយ ។

ក្នុងសេចក្តីនេះ គឺយើងមិនត្រូវប្រើរបស់ល្អដែលមានក្នុងខ្លួនទៅក្នុងផ្លូវខុស ឬអំពើថោកទាបផ្សេងៗឡើយ ត្រូវផ្សាយតេជានុភាព បង្ក្រាបសត្រូវនៅក្នុងខ្លួនដោយការ

ប្រព្រឹត្តធម៌ ។

ស្តេចចក្រពត្តិប្រព្រឹត្តធម៌ ទើបដល់ព្រមដោយរតនៈ ៧ ប្រការ យ៉ាងណា មនុស្សយើងលុះត្រាតែប្រព្រឹត្តធម៌ ទើបសកលកាយនិងអវយវៈផ្សេងៗ សម្រេចបានជារតនៈដ៏វិសេសនាំមកនូវជ័យជម្នះដ៏ក្រៃលែងទៅបាន ។

| | |
|---|---|
| អវយវៈមានតម្លៃ | វិស័យបីដូចជារតនៈ |
| គួរប្រើឱ្យល្អនិងទុកដាក់ | ឱ្យសមអន់ត្បូថ្នាក់ឧត្តម ។ |
| មិនត្រូវប្រព្រឹត្តការទាបថោក | សម្លាប់ឆបោកចាប់បង្ខំ |
| វចីទុច្ចរិតពិតពុំសម | គួរតែខិតខំរក្សាធម៌ ។ |

ការប្រព្រឹត្តធម៌នាំមកនូវសេចក្តីសុខ



## ២៧-មរតករបស់ម៉ែឪ

មានអ្នកដែលតែងតែពោល ទំនងជាអន់ចិត្តថា «ខ្លួនជាមនុស្សអភ័ព្វ ព្រោះម៉ែឪ ជីដូនជីតាមិនបានឱ្យនូវមរតកដូចជាអ្នកដទៃ ម៉្លោះហើយត្រូវប្រឹងប្រែងដោយកម្លាំងរបស់ខ្លួនឯង » ។

តាមពិត អ្នកដែលពោលដូច្នេះ គឺជាអ្នកមានការយល់ខុសទៅលើការពិត ព្រោះគ្រប់គ្នាសុទ្ធតែបានទទួលនូវមរតកពីបុព្វជនរបស់ខ្លួនដូចៗគ្នា គឺបានអវយវៈខ្លួនប្រាណដៃជើងក្បាលមុខមាត់ រហូតដល់សតិបញ្ញាដែលមាតាបិតាបានបង្ហឹកបង្ហាត់ ។ តិចគ្នាណាស់ដែលកើតមកហើយ ត្រូវពិកល្យពិការខុសធម្មតានោះ ។

អវយវៈរូបរាងកាយព្រមដោយសតិបញ្ញាដែលគ្រប់គ្នាបានមាននេះនោះ ជាសម្បត្តិដ៏ប្រសើរជាទីបំផុត គឺវិសេសជាងទ្រព្យមរតកណាៗទាំងអស់ ព្រោះគ្រប់គ្នាបាន

ប្រើសម្បត្តិដែលជាប់តាមខ្លួននេះ ធ្វើការចិញ្ចឹមជីវិតខ្លួនឯងបានជារៀងរហូត ទាំងជាគ្រឿងសាងសេចក្ដីសុខដែលពិតប្រាកដឱ្យដល់ខ្លួនឯងទៀតផង ។

មាសប្រាក់ផ្ទះសំបែងទីកន្លែងស្រែចម្ការ ដែលសន្មតថាជាសម្បត្តិនោះ រមែងមានវិបត្តិផ្លាស់ប្ដូរប្រែប្រួលជាខាងក្រោយ ទាំងមិនអាចនាំយកទៅទិញដូរឱ្យបាននូវសេចក្ដីស្ងប់ចិត្តផងឡើយ ។ ចំណែករាងកាយសតិបញ្ញាជាទ្រព្យសម្បត្តិជាប់តាមខ្លួន បើអ្នកមានបញ្ញានាំយកទៅប្រើឱ្យជាប្រយោជន៍ រមែងទទួលបាននូវសេចក្ដីស្ងប់ចិត្តដែលចាត់ថាជាសេចក្ដីសុខដែលពិតប្រាកដរហូតតទៅ ។

ព្រោះដូច្នោះ យើងចូររីករាយចិត្តក្នុងសម្បត្តិដែលខ្លួនមានដោយការនឹករលឹកយ៉ាងធ្ងន់ចិត្តថា « រាងកាយអវយវៈ សតិបញ្ញា និងជីវិត ទាំងអស់នេះសុទ្ធតែជាមរតករបស់មាតាបិតានៃយើង ដែលលោកបានប្រគល់ឱ្យមក » ហើយចូរព្យាយាម ប្រើប្រាស់គ្រប់យ៉ាងនូវរបស់ដែលមានឱ្យកើតប្រយោជន៍ពិតប្រាកដដល់ខ្លួនឯង កុំរវល់តែអង្គុយ



គិត ដេកគិត ហើយអន់ចិត្តថាខ្លួនអភ័ព្វ ដែលវាជាការនាំឱ្យខូចពេលវេលា ប្រាសចាកនូវប្រយោជន៍ ។

## ពាក្យមេទាំងអស់ប្រដូចនឹងម៉ែ

ភ្នំព្រះសុមេរ៉ុគឺជាមេភ្នំ ធំក្រៃលែងធំទ្រៃត្រិង្សឋាន
តែគង់នៅតូចជាងម៉ែកល្យាណ ព្រោះម៉ែទ្រឋានព្រះព្រហ្មមុខបួន។
ម៉ែពិតជាធំនៅក្នុងលោកា មេទ័ពខ្លាំងក្លាសំពះម៉ែខ្លួន
ទោះស្ដេចចក្រពត្តិគ្រងទ្វីបទាំងបួន អំណាចមាំមួនក៏នៅខ្លាចម៉ែ។
ពាក្យមេក្នុងលោកមានច្រើនពេកក្រៃ មេជើងមេដៃមេស្រុកមេស្រែ
ពាក្យមេទាំងនោះប្រដូចនឹងម៉ែ ពាក្យមេហូរហែគឺម៉ែទាំងអស់។
ព្រោះម៉ែជាធំម៉ែអ្នកបង្កើត ម៉ែឱ្យកំណើតម៉ែឱ្យបៅដោះ
ម៉ែបង្ហាត់កូនម៉ែមានចិត្តស្មោះ ម៉ែគឺជាកោះនៃជីវិតកូន ។

## ២៨-មេមាន់និងកូនមាន់

ពេលស្រាង១ មេមាន់ក្រោកឡើងឈរ បន្ទាប់ពីដេកក្រុងកូនតូច១ ទុកក្នុងស្លាបអស់ពេញមួយយប់មក ។ មេមាន់បបួលកូនចេញរកស៊ី ដោយជើងកកាយ និងភ្នែកសម្លឹងរកចំណី បានអ្វី១ ហៅកូនមកជុំ បើចំណីរាងធំ មេចឹកបំបែកឱ្យជាបំណែកតូច១ ។

ពេលមេមាន់ដឹងថា មានសត្រូវហើរឆ្វៃលពីលើ មានខ្លែងជាដើម គឺក្រៃលែងក្នុងការហួងហែងកូន ស្រែកហៅកូនយ៉ាងប្រញាប់ ឱ្យកូនរត់មកជិត១ ប្រាប់ឱ្យកូនចេះក្រាប ចេះគេចពួនពីសត្រូវ និងបើកស្លាបឱ្យកូនរត់ចូល ។

មេមាន់បណ្តើរកូន ចិញ្ចឹមកូន រក្សាកូន តាំងពីព្រលឹមស្រាងរហូតដល់ព្រលប់ រាល់១ថ្ងៃ មេមាន់ត្រូវនឿយហត់យ៉ាងគួរឱ្យអាណិត ។ ដល់ពេលព្រលប់ត្រូវឈប់សម្រាក មេតែងតែហៅកូន១ឱ្យចូលមកនៅក្រោមស្លាប ដោយក្រាបឱ្យកូនដេកលក់យ៉ាងសប្បាយវាស់ព្រឹក។



ឱ! សេចក្តីស្រឡាញ់របស់ម៉ែ កុំថាតែមនុស្សឡើយ សូម្បីមាន់ក៏ព្រមលំបាកដោយការចិញ្ចឹមកូនរបស់ខ្លួនរហូតទាល់តែកូនទាំងអស់ធំ ដុះស្លាបក្រាស់ចាស់ជើង រកស៊ីខ្លួនឯងបាន នោះឯង ទើបបានផុតចាកពីទ្រូងរបស់មេទៅតាមកន្លែងរៀងខ្លួន ។

កូនមាន់ ដែលធំរហូតដល់ជាមេមាន់ធំមែនទែនហើយ តើមានមាន់ណាខ្លះដែលចិញ្ចឹមនូវមេដើម្បីតបស្នងសងគុណ ?

មិនមានឡើយ ព្រោះវាជាសត្វ ដូច្នេះទើបមិនចេះដឹងគុណរបស់មេដែលចិញ្ចឹមខ្លួនមក ។ អនិច្ចា ! មេមាន់គួរឱ្យអាណិតណាស់ ចិញ្ចឹមកូនមកហើយ រហូតដល់កូនធំ១ តែមិនអាចពឹងកូនណាមួយបានឡើយ ។

ឪពុកម្តាយរបស់យើងគ្រប់គ្នា ក៏ដូចគ្នានឹងមេមាន់ ដោយត្រូវលំបាកក្នុងការចិញ្ចឹមកូនប្រុសស្រីតាំងតែពីគភ៌ចាប់ផ្តើម ដោយសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដ មានការយកចិត្តទុកដាក់យ៉ាងក្រៃលែង ។ មាតាបិតានឿយ

ហត់ទាំងកាយទាំងចិត្ត ពិតប្រាកដខ្លាំងក្លា ប៉ុន្តែមានកូនខ្លះក៏ដូចជាកូនមាន់ មិនមានខុសអ្វីឡើយ ។

ចូរយកតម្រាប់តាមមេមាន់ ដែលមិនព្រមចោលកូន តែកុំយកតម្រាប់តាមកូនមាន់ឡើយ សឹងដែលធំឡើងហើយ លះបង់ចោលមេរបស់ខ្លួន ។

ឪពុកម្តាយរបស់យើងនោះ មានត្រឹមតែពីរនាក់ប៉ុណ្ណោះ ហើយនឹងនៅឱ្យយើងជាកូនចិញ្ចឹមតបគុណនោះមិនជាយូរប៉ុន្មានឡើយ ។

| |
|---|
| នឹកគុណ តបគុណ ជាបុណ្យប្រណីត |



## ២៩-ស្រណោះមេអក

មេបក្សី នៅពេលដែលពងហើយ ត្រូវក្រាបត្រូវរក្សាពងក្នុងសំបុក ឯបក្សីឈ្មោលដែលត្រូវជាគូ ក៏ដឹងតួនាទីរបស់ខ្លួន ត្រូវទៅស្វែងរកចំណីដើម្បីខ្លួនឯងផងដើម្បីគូគ្រងរបស់ខ្លួនផង និងជួយក្រាបពងក្នុងវេលាផ្លាស់ប្តូរគ្នាផង ។ យ៉ាងនេះ រហូតដល់កូនញាស់ចេញចាកស៊ុតទាំងមេទាំងឈ្មោលត្រូវមានភារៈបន្ថែមយ៉ាងធ្ងន់ ដោយការហើរឡើង ហើរចុះ ដើម្បីរកចំណីមកចិញ្ចឹមកូនតូចៗទាំងព្រឹកទាំងល្ងាច ។

អ្នកណាដែលថា មានតែមនុស្សប៉ុណ្ណោះដែលស្រឡាញ់កូននោះ គឺពុំមែនឡើយ ។ តាមពិត យើងសង្កេតឃើញប្រភេទសត្វតិរច្ឆានច្រើនណាស់ ដែលស្រឡាញ់កូនដ៏គួរឱ្យសិក្សាពិចារណា គ្រាន់តែផ្សេងគ្នាត្រង់ដែលមនុស្សស្រឡាញ់កូនរហូតដល់ស្លាប់បាត់បង់ជីវិត មិនព្រមលះបង់ចោលកូនឡើយ ឯចំណែកសត្វ កាលបើកូនធំ ដុះស្លាប

ហើរបាន មានកម្លាំងល្មមរកស៊ីខ្លួនឯងកើតហើយ ក៏បែកចាកពីមេបារបស់ខ្លួន ទៅតាមទំនើងចិត្ត ។

ចាស់បុរាណធ្លាប់បានពោលរឿងសត្វអក ទុកមកថា កាលមានមនុស្សចាប់យកកូនពីសំបុកទៅ ដល់មេវាត្រឡប់មកពីរកចំណីមិនឃើញកូន ក៏ខូចចិត្ត ហើយហើរឡើងទៅលើខ្ពស់ រួចក្តោបស្លាបទម្លាក់ខ្លួនចុះ បោកខ្លួននឹងផែនដីយ៉ាងខ្លាំងរហូតដល់ស្លាប់ របៀបដូចជាការព្រាត់គូដូច្នោះដែរ ។ ព្រោះហេតុនោះទើបចាស់ៗ ហាមកូនចៅមិនឱ្យទៅចាប់យកកូនសត្វអក ឬបំបែកគូវាឡើយ ដោយខ្លាចថាមេ ឬគូរបស់វាបោកខ្លួនឱ្យស្លាប់ព្រោះតែអាល័យ នាំឱ្យជាប់បាបកម្មពៀរវេរាដែលគួរឱ្យខ្លាច ។

ចាករឿងសត្វអកនេះ មានគតិឱ្យមនុស្សគ្រប់គ្នាពិចារណាថា សូម្បីវាជាសត្វ តែវាស្រឡាញ់កូន ស្រឡាញ់គូគ្រងស្មើជីវិតរបស់ខ្លួន បើមានការព្រាត់ប្រាស យំរកមិនឃើញច្រើនថ្ងៃ ក៏នឹកថាកូន ឬគូរបស់វាស្លាប់ទៅហើយ ខ្លួនឯងក៏សុខចិត្តស្លាប់តាមដែរ ទាំងដែលសេចក្តីស្លាប់នេះ



ជាភ័យរបស់សាមញ្ញសត្វដ៏ក្រៃលែងនោះ ។

កូនមនុស្សខ្លះព្យាយាមគេចចេញពីម៉ែពីឪ ដែលម៉ែឪខំព្យាយាមទូន្មានប្រៀនប្រដៅណែនាំឱ្យបានជាមនុស្សល្អ គឺមិនជឿមិនស្តាប់ និងមិនព្រមប្រព្រឹត្តតាមឡើយ ។ ជាកូន ដែលវង្វេងទៅសេពគប់ជាមួយមនុស្សអាក្រក់ជាមិត្តបួម ហើយប្រព្រឹត្តខ្លួនជាមនុស្សចៃសង្គម រហូតក្លាយជាមនុស្សអន្ធពាល ដូច្នេះទើបនៅនឹងផ្ទះជាមួយម៉ែឪមិនបាន ត្រូវគេចាប់យកទៅឱ្យនៅក្នុងគុក ជាប់ឃុំឃាំងតាមទោសកំហុសរបស់ខ្លួន ។ របៀបនេះ វាស្រដៀងគ្នានឹងកូនសត្វអកដែលត្រូវគេចាប់យកពីសំបុកទៅ ម៉ែឪត្រូវដេកមិនលក់បាយមិនបាន កើតការក្តៅក្រហាយចិត្ត និងខូចចិត្តត្រង់ដែលកូនជាមនុស្សលំបាកប្រដៅ ចចេសក្បាលរឹង សេព-គប់បាបមិត្ត និងប្រព្រឹត្តអាក្រក់ថោកទាប រហូតដល់ត្រូវទទួលទុក្ខទោសជាទម្ងន់ ។

ចូរកូនៗ សម្លឹងមើលមេបក្សាបក្សី ដែលស្រឡាញ់កូនរបស់ខ្លួន ហើយចូរដឹងដល់ព្រះគុណរបស់មាតាបិតា

ថា លោកទាំងពីរស្រឡាញ់យើង ប្រាថ្នាល្អចំពោះយើងដ៏យ៉ាងក្រៃលែង ។ ចូរកូនប្រុសស្រីកុំធ្វើខ្លួនឱ្យមាតាបិតាសោកសៅដំបៅចិត្ត ព្រោះហេតុតែយើងជាកូនប្រព្រឹត្តអាក្រក់ឡើយ ។

ត្រីនៅលើគោកបម្រះរកទឹក ចចកតែងនឹករកព្រៃស្មសាន
សត្វក្នុងទ្វីបលោកនឹករកសុខសាន្ត មិនអាចប្រៀបបានចិត្តម៉ែដែលនឹក។
នៅពេលភ្លៀងធ្លាក់រុក្ខជាតិខៀវខ្ចី បក្សាបក្សីខ្មៀវខ្មាវពេលព្រឹក
ថ្ងៃក្ដៅសត្វរកជ្រកក្រោមសន្លឹក ប្រៀបដូចកូននឹករកម៉ែពេលឈឺ។



## ៣០-ប្រើសជាមួយគុម្ពព្រៃ

មានសត្វប្រើសមួយ ត្រូវនាយព្រានដេញតាមប្រហារ ក៏ខំប្រឹងរត់ហើយគេចពួន បានចូលអែបទៅនឹងគុម្ពព្រៃមួយ ។ ដោយផុតពីក្រសែភ្នែករបស់ព្រាន ធ្វើឱ្យព្រានរត់ដេញហួសអំពីទីនោះទៅ ។

ប្រើសមានការសប្បាយចិត្ត ព្រោះគិតថា បានរួចផុតពីភ័យហើយ ទើបបេះស៊ីស្លឹកឈើនៃគុម្ពព្រៃនោះឯងស៊ីរហូតទាល់តែគុម្ពព្រៃស្រឡះ អាចមើលឃើញខ្លួនឯងបានច្បាស់ពីផ្លូវដើរមក ។ ដល់ពេលល្ងាច នាយព្រានដើរមកវិញតាមផ្លូវដដែលទាំងខកចិត្ត ត្បិតដេញប្រើសមិនទាន់ លុះមកដល់ទីនោះ ដាក់ភ្នែកទៅឃើញប្រើស ក៏លាន់មាត់ថា « យើះ អាដែងនេះ នៅទីនេះទេតើ » ។

ប្រើសឃើញព្រានម្ដងទៀត ខំប្រឹងគេច តែវាកៀកជិតណាស់ទៅហើយ នាយព្រានទាញព្រួញបាញ់ប្រើបត្រូវប្រើសដួលស្លាប់ តែមុននឹងស្លាប់ក៏បាននឹកដល់ទោស

ដែលខ្លួនទម្លាយនូវគុម្ពព្រៃ ទើបប្រើសប្រដៅខ្លួនឯងថា «នេះឯង ទោសនៃការទម្លាយរបស់ដែលមានគុណ» ។

គតិចាករឿងនេះ ដាស់តឿនចិត្តឱ្យមនុស្សយើងគិតដល់ឧបការៈនៃអ្នកដ៏មានគុណរបស់ខ្លួន ហើយមិនទម្លាយ ឬប្រទូសរ៉ាយចំពោះគុណឡើយ ។

បើពោលឱ្យទូលាយទៅ អ្នកមានគុណដល់ខ្លួននោះ មានទាំងអ្នកធំ មានទាំងអ្នកតូច ។ នឹងគិតថា អ្នកតូចជាបុគ្គលប្រាសចាកនូវសេចក្តីសំខាន់មិនបានឡើយ ព្រោះដែលអាចបានជាអ្នកធំ ក៏មកអំពីមានអ្នកតូចដែរ ឬថា ជាចៅហ្វាយនាយរបស់គេទៅបាន ក៏ត្រូវតែមានទាសកម្មករហ្នឹងឯង ។

តាមផ្លូវលោក តែងអប់រំឱ្យអ្នកតូច នឹកដល់គុណរបស់អ្នកធំជាប្រមាណ តែតាមផ្លូវធម៌ មានការរំលឹកឱ្យអ្នកធំព្យាយាមគិតដល់គុណរបស់អ្នកតូច ព្រោះថាជាអ្នកលើកតម្កើង ជួយទំនុកបម្រុង និងបម្រើឱ្យដល់ខ្លួនជាអ្នកធំយ៉ាងជិត និងជិតដល់ជាទីបំផុត ដូច្នោះ កាលបើពោល



ដល់បុគ្គលអ្នកមានគុណ រមែងមានទាំងអ្នកធំ និងអ្នកតូច មិនមែនមានចំពោះតែអ្នកធំប៉ុណ្ណោះឡើយ ។

ការទម្លាយអ្នកតូច ដោយការច្រណែនក្តី ដោយព្យាបាទក្តី ឬដោយអំណាចនៃអគតិក្តី ស្មើគ្នានឹងការទម្លាយខ្លួនឯង ឬទុកដូចជាការកាត់ដៃ កាត់ជើងខ្លួនឯងចោល ។ ដូច្នេះចូរកុំឱ្យដូចជាសត្វប្រើស ដែលសប្បាយចិត្តពេក ហើយបរិភោគស្លឹកឈើ សឹងដែលជាទីកំបាំងរបស់ខ្លួន ទើបត្រូវស្លាប់ ព្រោះធ្វើឱ្យនាយព្រានមើលឃើញរូបកាយបានយ៉ាងច្បាស់នោះឡើយ ។

### បុរាណភាសិត

អ្នកធំកុំមើលងាយអ្នកតូច ស្មៅវល្លិវេញកួចចងដំរី
ស្តេចពឹងរាស្ត្រសង្ឃពឹងវិន័យ មច្ឆាជលស័យពិតពឹងទឹក ។

## ៣៦-ព្រះតេជ-ព្រះគុណ

ក្នុងលោកនេះ មានធម្មជាតិដែលនាំឱ្យមានពន្លឺភ្លឺស្វាងសឹងឃើញបានដោយងាយ ២ ប្រការគឺ ១ដួងអាទិត្យ និង ១ ទៀតគឺដួងចន្ទ ។

ដួងអាទិត្យនោះ មានលក្ខណៈក្តៅខ្លាំង មានអំណាចតេជះជាទីគួរខ្លាច គួរញញើត ចំណែកដួងចន្ទវិញ មានលក្ខណៈត្រជាក់ ស្រទន់ ជាទីគួរឱ្យរីករាយ ព្រោះភ្លឺស្វាងព្រមដោយសភាពស្ងប់ស្ងាត់ ។ ម្យ៉ាងទៀត ដួង-អាទិត្យជាដួងភ្លើងដ៏ធំក្រៃលែង អណ្តែតកណ្តាលវេហា មិនមានបរិវារដោយផ្កាយដទៃៗឡើយ ឯដួងចន្ទមានផ្កាយដទៃជាបរិវារ ហែហមឡោមព័ទ្ធសន្ធឹកសន្ធាប់ ។

ដួងអាទិត្យនោះ ប្រៀបដូចជាព្រះតេជ គឺអំណាច។ អ្នកមានអំណាច សូម្បីមានមនុស្សភ័យខ្លាចជាមួយ តែក៏មិនមានអ្នកណាស្រឡាញ់ឡើយ ។ ដួងចន្ទឧបមាដូចព្រះគុណ សឹងនាំមកនូវភាពត្រជាក់ត្រជំដល់ចិត្តនៃអ្នក



ដែលឋិតនៅក្រោមព្រះគុណនោះ ។ អ្នកមាននូវព្រះគុណ មានធម៌មេត្តា រមែងមានអ្នកស្រឡាញ់ស្ម័គ្រស្មោះ មានស្វាមីភក្តិគួរឱ្យកក់ក្តៅ ។

ព្រះតេជ និងព្រះគុណនេះ សូម្បីចាំបាច់ដែលអ្នកធំត្រូវប្រើជាគូគ្នាក៏ពិត ប៉ុន្តែគួរឱ្យធ្ងន់រឿងព្រះគុណក្រៃលែងជាងព្រះតេជ ព្រោះបើប្រើតែព្រះតេជ ឬធ្ងន់ដោយព្រះតេជពេកទៅ រមែងបានផលបែបដួងអាទិត្យ គឺភ្លឺស្វាងជាប្រយោជន៍ពិត តែភ្លឺក្តៅចែងចាំងរហូតដល់មិនមានបរិវារ ។ អ្នកធំដែលធ្ងន់ដោយព្រះគុណ រមែងមានប្រៀបជាង ទោះជាភ្លឺស្វាងមិនសូវខ្លាំង តែក៏មិនក្តៅ ជះតែពន្លឺលាយឡំដោយភាពត្រជាក់ ឱ្យដល់អ្នកតូចទាបដោយទូទៅ ព្រោះហេតុដូច្នោះ បរិវារទើបឡោមព័ទ្ធហែហមប្រកបដោយស្វាមីភក្តិ ដូចជាដួងតារានិករត្រាច់ចរ ឡោមព័ទ្ធដួងចន្ទក្នុងរាត្រីនៃសុក្កបក្ខដូច្នោះឯង ។

អ្នកធំដែលឆ្លាត រមែងធ្វើខ្លួនឱ្យដូចជាដួងចន្ទ គឺប្រើព្រះគុណជាគោលក្នុងការគ្រប់គ្រង មិនធ្វើខ្លួនជាដួង-

អាទិត្យ គឺមិនប្រើព្រះតេជឱ្យជាប្រចាំ សូម្បីក្នុងកាលដែលមិនចាំបាច់ត្រូវប្រើនោះឡើយ ។

យើងគ្រប់គ្នាជាអ្នកតូចតាចនៅក្រោមឱវាទ និយមចូលចិត្តនូវភាពត្រជាក់ត្រជំ ហើយសូមប្រាថ្នាចំពោះអ្នកធំណាដែលពេញប្រៀបទៅដោយព្រះគុណ ព្រមដោយប្រាជ្ញាញាណក្នុងការដឹកនាំ ។

អ្នកណាធ្វើបាបក្នុងកាលមុន ក្រោយមកមានបុណ្យបិទបាបធម៌
អ្នកនោះញុំាងលោកឱ្យភ្លឺល្អ ដូចដួងចន្ទចរចាកពពក ។



## ៣២-ឈប់

អង្គុលិមាលចោរ យារដាវ ដេញតាមព្រះពុទ្ធអង្គមានបំណងនឹងប្រហារព្រះអង្គ ដើម្បីឱ្យបានចំនួនមនុស្សស្លាប់ដោយដៃរបស់ខ្លួន គ្រប់មួយពាន់នាក់ ។ មានសេចក្ដីអស្ចារ្យក្នុងចិត្តជាខ្លាំង ដែលខ្លួនតាមព្រះពុទ្ធអង្គមិនទាន់កាលដែលហត់ពេកមិនអាចរត់តទៅទៀតបាន ទើបហៅឱ្យព្រះអង្គទ្រង់ឈប់ថា «សមណៈឈប់ សមណៈឈប់ » ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់តបថា « ម្នាលអង្គុលិមាលតថាគតឈប់ហើយ អ្នកឯងទេដែលមិនទាន់ឈប់នោះ» ។

អង្គុលិមាលសួរព្រះអង្គថា «បពិត្រព្រះសមណៈព្រះអង្គកំពុងស្ដេចយាង តែពោលថា តថាគតឈប់ ទាំងពោលចំពោះខ្ញុំដែលឈប់ ថាជាបុគ្គលមិនទាន់ឈប់ដូច្នេះវិញ ។ បពិត្រព្រះសមណៈ ខ្ញុំសូមសួរសេចក្ដីនោះនឹងព្រះអង្គ ព្រោះហេតុអ្វី បានជាព្រះអង្គឈ្មោះថាឈប់ ឯខ្ញុំព្រះអង្គឈ្មោះថាមិនទាន់ឈប់ » ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា « ម្នាលអង្គុលិមាល តថាគតឈ្មោះថាឈប់ ព្រោះដាក់ចុះនូវអាជ្ញា ចំពោះសត្វទាំងពួងគ្រប់ពេលវេលាហើយ ចំណែកឯអ្នកវិញ ជាបុគ្គលមិនសង្រួមក្នុងពពួកសត្វ ព្រោះហេតុនោះ តថាគតទើបឈ្មោះថាឈប់ ឯអ្នកឈ្មោះថាមិនទាន់ឈប់ទេ » ។

អង្គុលិមាលចោរបាននូវសតិ ឃើញទោសរបស់ខ្លួនឯង គ្រវែងចោលដាវព្រមទាំងអាវុធផ្សេងៗទៀត ហើយចូលទៅថ្វាយបង្គំព្រះបាទានៃព្រះបរមសាស្តា សូមផ្នួសនឹងព្រះអង្គ លះបង់ចោលនូវបាបកម្ម អំពើអាក្រក់ដែលធ្លាប់ធ្វើទាំងពួងនោះ លុះក្រោយមកក៏បានសម្រេចជាព្រះអរហន្តមួយអង្គដែរ ។

ចំណែកយើងវិញ ឈប់ហើយឬនៅ ? ឈប់ធ្វើអាក្រក់ ឈប់ឈ្លោះគ្នា ... ដើម្បីសេចក្តីបរិសុទ្ធជារបស់ចំពោះយើងខ្លួនឯង ។

អ្នកណាប្រមាទក្នុងកាលមុន ក្រោយមកមានគុណមិនប្រមាទ
អ្នកនោះញ៉ាំងលោកឱ្យស្វាងស្អាត ដូចចន្ទផុតឃ្លាតចាកពពក ។



## ៣៣-រូបស្អាត ក្លិនក្រអូប

ផ្កាឈើដែលចេញពីចុងមែកក្តី ចេញពីដើមក្តី សូម្បីថាដើមនៅទាបតឿជាប់នឹងផែនដីក៏ដោយ ឱ្យតែថារូបស្អាត ហើយមានក្លិនក្រអូប មនុស្សទាំងឡាយគេមិនរង្កៀសអ្វីឡើយ គេរមែងបេះ ឬកាត់ចេញពីដើម នាំយកមកក្រងដើម្បីប្រដាប់សីសៈ ឬក៏ដាក់ថូដើម្បីថ្វាយព្រះពុំនោះសោតទេ គេដាក់ភាជនៈណាមួយដោយល្អ ហើយតាំងទុកក្នុងបន្ទប់ទទួលភ្ញៀវជាដើម ដោយមិនចាំបាច់រំពឹងគិតទៅដល់ដើមផ្កានោះៗ ថាមានសភាពយ៉ាងណា និងកើតនៅទីណាឡើយ ។

សេចក្តីខាងលើនេះ យ៉ាងណាមិញ មនុស្សយើងក៏យ៉ាងនោះដែរ ទោះជាកើតក្នុងត្រកូលក្រីក្រ ឬមានកំណើតក្នុងឋានៈដែលគេសន្មតថាអន់ថយ ឬក៏មានរូបរាងមិនសូវល្អស្អាតយ៉ាងណា តែបើថាជាអ្នកមាននូវវិជ្ជា មានចំណេះចេះដឹងប្រពៃពិតហើយ គឺរមែងក្លាយជាមនុស្ស

មានតម្លៃ ជាទីនិយមរាប់អាននៃអ្នកដទៃទាំងពួង ដោយមិនមានអ្នកណារង្កៀសចំពោះទៅលើរូបរាង ឋានៈ ឬវង្សត្រកូលឡើយ ព្រោះសេចក្ដីល្អដែលបុគ្គលនោះមាន បានដល់ចំណេះវិជ្ជា ដែលជាគ្រឿងបិទបាំងនូវអ្វីដែលគួរឱ្យរង្កៀសដទៃៗបាត់អស់ទៅហើយ ដូចជាផ្កាឈើរូបស្អាត ថែមទាំងមានក្លិនក្រអូបទៀតនោះ ធ្វើឱ្យមនុស្សទាំងពួងប្រាថ្នា ដោយមិនត្រូវចាំបាច់អ្វីទៅគិតដល់សភាពនៃដើមរបស់វាឡើយ ។

ដោយហេតុនេះ មនុស្សយើងទើបត្រូវសាងតម្លៃឱ្យដល់ខ្លួនឯង ដោយការប្រឹងប្រែងស្វែងរកនូវចំណេះវិជ្ជាមកប្រដាប់ខ្លួន ។

ផ្កាឈើ ពិតហើយថាស្អាត និងក្រអូប រមែងមានតម្លៃជាទីនិយមនៃមនុស្សទាំងឡាយ តែនេះដោយចំពោះក្នុងខណៈនៅស្រស់តែប៉ុណ្ណោះ បើស្វិតក្រៀមទៅហើយនោះ គឺអស់ស្អាត បាត់ក្រអូប និងមិនមានតម្លៃក្នុងការប្រដាប់តាក់តែងឡើយ នឹងយកទៅថ្វាយព្រះក៏មិនកើត



តាំងទុកដើម្បីលម្អ ឬដើម្បីក្លិនក្រអូបអ្វីៗ ក៏មិនបានទាំងអស់ ម៉្លោះហើយវាជាសំរាមដែលគេត្រូវចោល ។

ក្នុងចំណុចខាងលើនេះ យ៉ាងណាមិញ មនុស្សដែលមាននូវចំណេះវិជ្ជាក៏ដូចគ្នាដែរ បើភ្លើភ្លេចសតិតម្កើងឫក ប្រកាន់ខ្លួន និងថោកទាប វាក៏ក្លាយទៅជាមនុស្សអស់តម្លៃ ព្រោះថា ការចេះដឹងនឹងជាប្រយោជន៍ពិតទៅបាន គឺត្រូវអាស្រ័យមានមារយាទល្អជាទីរ៉ាប់រងនិងជាគូគ្នារហូតទៅ ។ បើមានតែចំណេះវិជ្ជា ឆ្លាតក្នុងការងារប៉ុណ្ណោះ ឯមារយាទវិញនោះ អន់ថយថោកទាបប្រព្រឹត្តឡេះឡោះ មិនសង្រួមក្នុងកាម ប្រព្រឹត្តអនាចារ ។ល។ គឺមិនខុសអ្វីអំពីផ្កាដែលស្វិតក្រៀមនោះដែរ សូម្បីមានគេលើកតម្កើងក្នុងកាលមុនក៏ដោយ ដល់ពេលក្រោយមានការស្វិតក្រៀម ពោលគឺមានមារយាទអាក្រក់ គេនឹងបោះបង់ចោល ថែមទាំងស្អប់ខ្ពើមទៀតផង តាមវិស័យនៃមនុស្សទូទៅ ដូចជាគេចោលផ្កាដែលអស់ស្អាត បាត់ក្រអូប ស្វិតស្អុយ ទៅក្នុងធុងសំរាមដូច្នេះឯង ។

## ៣៤_រាជសីហ៍មិនបរិភោគសាច់ស្អុយ

ជាតិជាស្ដេចម្រឹគមានចិត្តអង់អាច    សព្វសត្វកោតខ្លាចអំណាចរាជសីហ៍
មិនបរិភោគស្មៅដូចសត្វដទៃ    សំណល់អ្វីៗក៏មិនបរិភោគ ។
បរិភោគតែសត្វដែលខ្លួនសម្លាប់    ដល់ពេលទៅចាប់តែងតែមានជោគ
បើអត់ស៊ូស្លាប់មិនឱនក្បាលឈ្លោក    មិនបរិភោគស្មោកគ្រោកសាច់ស្អុយ។
ធីរជនអ្នកប្រាជ្ញប្រៀបដូចរាជសីហ៍    រស់ក្នុងវិន័យស្គាល់អ្វីជានុយ
ចិញ្ចឹមជីវិតមិនស្មានប្រថុយ    សុខចិត្តអត់លុយមិនលួចមិនប្លន់។
ប្រឹងប្រែងធ្វើការដោយកម្លាំងខ្លួន    ការល្អធ្វើផ្ទួនមិនពួនបន់ស្រន់
មិនពួនស៊ីពែមិនលក់បំភាន់    មិនជិះមិនជាន់មិនចាញ់អាត្មា ។
គោរពខ្លួនឯងធ្វើការហ្មត់ចត់    រក្សាបែបបទឧត្តមចរិយា
ចិត្តជារាជសីហ៍សម្រេចកិច្ចការ    អត់ឃ្លានយ៉ាងណាអាហារបរិសុទ្ធ។

អ្នកដែលដល់ព្រមដោយការចេះដឹង    មានទាំងទីពឹងគឺការប្រព្រឹត្ត
អ្នកនោះប្រសើរក្នុងលោកដោយពិត    អ្នកផងចូលចិត្តនៃបនិត្យមិនណាយ។
ដូចផ្កាមានក្លិនក្រអូបហើយស្អាត    ស្រស់តាមធម្មជាតិញាតិប្រដាប់កាយ
ដោតក្រងដាក់ថូក្រាបសំពះថ្វាយ    មនុស្សផងទាំងឡាយមិនឆ្ងាយពីក្លិន។



## ៣៥_បង្គួយបានមាស

ព្រះរាជឧទ្យានមានបង្គួយមួយ    មានបុណ្យលើកស្ទួយឱ្យចេះគារវៈ
ងក់ក្បាលបង្គំស្ដេចទ្រង់ទតជាក់    ហើយត្រាស់ឱ្យដាក់ទានជាប្រចាំ។
ថ្ងៃមួយពុំមានសាច់ជាចំណី    ត្រូវដូរលាភថ្មីដូរទាំងបុញ្ញកម្ម
បង្គួយឡើងចាងធ្វើខុសចំណាំ    ពាក់មាសរងកម្មព្រោះហេតុតែល្ងង់។
បង្គួយបានមាសលះបង់គារវៈ    ស្ដេចបានជ្រាបជាក់ទាស់ហឫទ័យទ្រង់
លើកការឱ្យទានរឿងនេះយូរលង់    តែនៅគង់វង្សជាគ្រូប្រដៅ ។
ស៊ីឆ្អាញ់ដេកស្រួលមានលាភមានយស លោកធមិទាំងអស់សម្លាប់មនុស្សខ្លៅ
ឱ្យឃ្លាតពីគុណឆ្ងាយពីទិសដៅ    រងទុក្ខសោកសៅក្នុងវដ្តសង្សារ។
រក្សាគុណធមិទទួលលាភយស    មិនវាយឫកខ្ពស់ជីវិតថ្លៃថ្លា
បង្គួយបានមាសយើងគួរសិក្សា    កុំលង់អាត្មានៅក្នុងលោកីយ៍ ។

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការទារធម្មទាន

១. ឧបាសក សំរ៉ង វណ្ណ    ២. ឧបាសក យន្ត សួន
៣. ឧបាសក គួង លាងផេង    ៤. ឧបាសក មួង យេន
៥. លោកគ្រូ រស់ សូផាត    ៦. ឧបាសក អ៊ិត ប្រាំង
៧. នាង ជា សុណារី    ៨. នាង ឃុន សូនីម៉ា
៩. ឧបាសិកា ហួនចាន់បូដា    ១០.ឧបាសក វ៉ាន់ ខុនណា
១១. ឧបាសក គុយ សុធន    ១២.ឧបាសក ជឹង វ៉េងអ៊ាវ
១៣. ឧបាសក ជឹម ជំនិត    ១៤.ឧបាសក ហាយ ចំរើន
១៥. ឧបាសិកា ប៊ុត ម៉ាលី    ១៦.ឧបាសិកា ហាយ ច័ន្ទធរី
១៧. លោកគ្រូ ជូ ប៊ុនយូ    ១៨.លោកគ្រូ លាក់ តុង
១៩. ឧបាសក ង៉ូវ គា

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈



## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១. ឧ.ស. យូស៊ាង-ងួនលី និង ឧ.សិ. លីម-ឃីម ..... ស.រ.អ.
២. ឧ.ស. ឆាយ-អ៊ីវស៊ាង និងឧ.សិ.ហុង-គីមសែ .... ស.រ.អ.
៣. ឧ.ស. ឆាយអ៊ីវ-ស្រេងលីម និងឧ.សិ.ហួត-ឃីម... ស.រ.អ.
៤. ឧ.ស. ហៃ-ប៊ុនណារិន និងឧ.សិ.អោង-ស៊ីថាន់ ... ស.រ.អ.
៥. ឧ.ស. ហៀប-បេ និងឧ.សិ. ឡៅ-កែវម្លិះ ........ ស.រ.អ.
៦. ក្រុមឧ.ស. ឈុំ-កុសល និងឧ.ស. អ៊ុន-ឆាយគ្រី.... ស.រ.អ.
៧. ក្រុមឧ.ស. លឹម -ស៊ាង ( ហៅ ទូច ) ........ ស.រ.អ.
៨. ឧ.ស. យន្ត-សួន ឧ.សិ. តាំង ឈុងប៊ួយ និងបុត្រ .... ភ.ព.
៩. ឧ.ស.ប៊ុន-ហេង ឧ.សិ.ជុំ-សុខុម ព្រមទាំងបុត្រ... អូស្រ្តាលី
១០. ឧ.សិ.ឱម-លក្ខណា ព្រមទាំងបុត្រធីតា ......... អូស្រ្តាលី
១១. លោក យូណូស អាស៊ីស អ្នកស្រី ហុក ណារី +បុត្រ .បារាំង
១២. ឧ.ស.ង៉ូវ ជួនណារេត ឧ.សិ.ង៉ូវ សោភ័ណ+បុត្រ.....បារាំង
១៣. ឧ.ស. ម៉ៅ វង់ និង ឧ.សិ. ឆាន់ កាន់ជួង ....... ស.រ.អ.
១៤. ឧ.ស.សយ ស៊ីផាន់ណា និងឧ.សិ.ម៉ៅ សុផល +បុត្រ ភ.ព.
១៥. ឧ.សិ. ច័ន្ទ-បុប្ផាណា ព្រមទាំងបុត្រធីតា ........... ភ.ព.

១៦_ ឧ.សិ. អ៊ា នៅ ព្រមទាំងបងប្អូនកូនចៅ ........ កាណាដា

១៧_ ឧ.ស. ឡុក ប៊ុនអ៊ីវ និងឧ.សិ.តាន់ ស៊ីវឡាង+បុត្រ . បារាំង

១៨_ ឧ.សិ.ប៊ិតថងខាំ និង ឧ.សិ.សាន គីន + ឧ.សិ.សាន ផល្លីន.

១៩_ ឧ.ស. យូ ម៉េង ................................ ក.ព.ស.

២០_ ឧ.ស.ម៉ៅ_សុគន្ធ ឧ.សិ.អ៊ឹង_យ៉េកហួយ និងបុត្រ .. ភ.ព.

២១_ ឧ.សិ. អ៊ឹង_យ៉េកសាង ព្រមទាំងបុត្រ ........... បារាំង

២២_ ឯ.ឧ. អ៊ិត_ប្រាំង និង ជ.ទ.ញ៉ែម_សេដ្ឋា +បុត្រ .... ភ.ព.

២៣_ ឯ.ឧ. ធី តាឃី និង ជ.ទ. ហេង មុនីរ័ត្ន +បុត្រ ...... ភ.ព.

២៤_ ឯ.ឧ.ចែម វីឌ្យ៉ា និង ជ.ទ.សុខា ស៊ូលីវណ្ណ +បុត្រ ....ភ.ព.

២៥_ ឯ.ឧ.ឧកញ៉ា ប៊ុត គឹមស៊ាន និងជ.ទ.ឈួន ទូច+បុត្រ ប.ប.

២៦_ ឯ.ឧ.ប៉ុល_នាង និង ជ.ទ.គ្រៀល_ស៊ីយ៉ា +បុត្រ ..... ភ.ព.

២៧_ ឧ.ស. ស៊ិន សុខា និងឧ.សិ. សុខា ផល្លី និងបុត្រ ... ភ.ព.

២៨_ ឧ.សិ. ស៊ីវ យក់លុយ ............................ ស.រ.អ.

២៩_ ឧ.ស. អ៊ុត_ឆៃវ៉ាន ឧ.សិ. ធាន ស៊ុនលី និងបុត្រ .. ស.រ.អ.

៣០_ ឧ.ស. ប្លោក_ងួនថៃ ឧ.សិ.ធាន ត្រលុច និងបុត្រ . ស.រ.អ.

៣១_ ឧបាសិកា អ៊ឹង ស៊ីវន ............................ ស.រ.អ.

៣២_ ឧ.សិ.ហេង_ស៊ីវខេង +ម្ដាយឈ្មោះ អៀង_ហ៊្គិច ..កណ្ដាល

៣៣_ ឧ.ស.យឹម_ស៊ីមុន្នី ឧ.សិ.យូ_ប៉ូលីន និងបុត្រ ........ ភ.ព.

៣៤_ ឧ.ស. ឡាយ_សុខុម ឧ.សិ. សួន_ចន្ថា និងបុត្រ .......ភ.ព.

_១២៩_

៣៥_ ឧ.ស.ធឹម_ញាណ ឧ.សិ. កាំង_ប៉ូលីន និងបុត្រ ...ក.ព.ស.

៣៦_ ឧបាសិកា អ៊ំ_អ៊ន់

៣៧_ ឧ.សិ. ប៉ូអាន_ស៊ីវុត្ថា ................................ ភ.ព.

៣៨_ ឧ.សិ. ប៉ូ ផាវ៉ាណ ...................................ភ.ព.

៣៩_ ឧ.សិ. ម៉ៅ សុន្ធា .....................................ភ.ព.

៤០_ ឧ.សិ. សាក់_ស៊ាងអេង ព្រមទាំងបុត្រ

៤១_ ឧ.សិ. ជា_ផាត ព្រមទាំងបុត្រ

៤២_ ឧ.ស. ស៊ីវ សៅរ៍ និង ឧ.សិ. ស្រៀង រួចលាង

៤៣_ ឧ.ស.ស្វ ហុកឡុង ឧ.សិ.កាន់ ឈីវហា ........... ស.រ.អ.

៤៤_ ឧបាសិកា គា_ស៊ីន ................................ ប.ប.

៤៥_ ឧ.ស.អ៊ុក_សាម៉ាណារ៉ា ឧ.សិ.ហ៊ាប_តេង និងបុត្រ ...ភ.ព.

៤៦_ ឧ.ស. ម៉ៅ_ស្រ៊ិន ឧ.សិ. ទូច_ស៊ីនហ៊ន និងបុត្រ...... ភ.ព.

៤៧_ ឧ.ស.ពុធ_ប៉ោលាង ឧ.សិ. ហ៊ុន_ស៊ីវអៀង ...... កាណាដា

៤៨_ Chhem Sokreth et Puth Kunthea ....... កាណាដា

៤៩_ ឧ.ស. ឡោ សេងជ្រុន ឧ.សិ.ផាំង លី និងបុត្រ...... បារាំង

៥០_ ឧ.ស. ម៉ែន_សឿន ឧ.សិ. អៀង ណារី និងបុត្រ .... ភ.ព.

៥១_ ឧ.សិ. សយ វណ្ណា និង ស្វាមី ព្រមទាំងបុត្រ ........ ភ.ព.

៥២_ ឧ.សិ.ហេង ប៉ូរីស្រីនាថ និងកូនឯមភក្តី+ភរិយា+បុត្រ ភ.ព.

៥៣_ ឧ.សិ. ចំណាន ព្រមទាំងក្រុមគ្រួសារ ........ កាណាដា

_១៣០_

៥៤. ឧ.សិ. លី វន ព្រមទាំងក្រុមគ្រួសារ ............ កាណាដា

៥៥. ឧ.ស. ហួន ប៉ាន់ ឧ.សិ. ថៃ នាថ និងបុត្រ

៥៦. លោក ស៊ា រស់ អ្នកស្រី ញ៉េប ដារ៉េត និងបុត្រ

៥៧. លោក រឿង សេដ្ឋា អ្នកស្រី នាង ជូនអេង និងបុត្រ

៥៨. លោក សែន-សុវណ្ណរិទ្ធ និងភរិយា ................. ភ.ព.

៥៩. ឧ.ស. ប៉ូច បូរី ព្រមទាំងបុត្រ

៦០. ឧ.ស. អៀង ឆាយ និងឧ.សិ. អៀ-កេសរ +បុត្រ... ស.រ.អ.

៦១. លោកតា តាន់-ឈីវហា និងលោកយាយ ស៊ូ-ចិន្ត្រា

៦២. ឧ.សិ. តែ-សាយជូ ព្រមទាំងកូនចៅ

៦៣. ឧ.សិ. តាន់-ជាលី និងពុទ្ធបរិស័ទខេត្តសៀមរាប ..... ស.រ.

៦៤. ឧ.សិ. ឯម សុខន ព្រមទាំងបុត្រ និងចៅ ............ ភ.ព.

៦៥. ឧ.សិ. ម៉ុល-យ៉ែម ................................ ស.រ.អ.

៦៦. ឧ.សិ. កង-ភឹម

៦៧. ឧ.សិ. ម៉ក់-នាង

៦៨. ពុទ្ធបរិស័ទ ចាន់ នារីសុខ និងក្រុមគ្រួសារ ......... ស.រ.អ.

៦៩. ពុទ្ធបរិស័ទ ភឿក.កុំ

៧០. ឧ.សិ. ជុំ ឆាយ

៧១. ឧ.សិ. ស៊ីវ យក់លី ................................. ភ.ព.

៧២. ឧ.ស. ជាន យ៉ែត ឧ.សិ. សុក ចេង ព្រមទាំងបុត្រ ...ភ.ព.

-១៣១-

៧៣. ឧ.ស. សោម រតនៈ ឧ.សិ. ស៊ិប វណ្ណា ព្រមទាំងបុត្រ ព.វ.

៧៤. ឧ.ស. ហេង សម្បូរដ្ឋ ឧ.សិ. ស៊ិនគន្ធា ............. ភ.ព.

៧៥. ញោមប្រុសនិងញោមស្រីរបស់សាមណេរ ជា សុភ័ក្ត្រ.ភ.ព.

៧៦. ឧ.ស.សារឿន ឧ.សិ.លាប+ឧ.ស.ហ៊ីស៊ុ ឧ.សិ.អាន ស.រ.អ.

៧៧. លោក សួន បូភា អ្នកស្រី ហួន ចាន់ផូ ព្រមទាំងបុត្រ

៧៨. លោកស្រី ហ៊ុយ សុខម៉ា និងស្វាមី ព្រមទាំងបុត្រ

៧៩. ឧបាសក តាំង ស៊ុនម៉ាប

៨០. ឧបាសិកា ចៅ សារួន

៨១. ឧបាសិកា ឱប រះ ............................. ...ស.រ.អ.

៨២. ឧ.ស.គង់ សុគន្ធ ហៅជូគឹមសែ +បុត្រីគន្ធច័ន្ទដារា....ភ.ព.

៨៣. ឧ.សិ. វណ្ណ មុនី ព្រមទាំងបុត្រ និងចៅ ............. ភ.ព.

៨៤. ឧ.សិ. លឹម ប៊ូ ព្រមទាំងបុត្រធីតា

៨៥. ឧ.សិ. ឈុន លន

៨៦. ឧ.ស. ស៊ុយ ជូ និងឧ.សិ. តាំង ទៀង

៨៧. ឧ.សិ. ព្រុំ សុភាព .................................. ភ.ព.

៨៨. ឧ.ស.ហេង គីមរិន ឧ.សិ. ហោ ចន្ទូ ព្រមទាំងបុត្រ...បារាំង

៨៩. ឧ.សិ. សុខ ភួង និង ឧ.សិ. សុខ ផៃ

៩០. ឧ.សិ. អួន ញ៉ូ ឧ.សិ. រស់ លីនណា និងបុត្រ ..... ស.រ.អ.

៩១. លោក ចក់ ឈុន និង អ្នកស្រី វណ្ណារី សុខ

-១៣២-

៩២. ឧ.សិ. អ៊ុក លន់ និងក្រុមវេន ព្រមទាំងបុត្រ ......... ភ.ព.

៩៣. ឧ.សិ. ជា គឹមហឿន ព្រមទាំងបុត្រ

៩៤. ឧបាសិកា អ៊ីវ ថា ព្រមទាំងក្មួយ និងចៅ

៩៥. ឧបាសិកា ឈុន តាំងសៀក ព្រមទាំងបុត្រ និងចៅ

៩៦. ឧ.សិ. ជា ម៉ាក់លាង

៩៧. ឧ.ស.ហ្វាន់ វ៉ាន់ហួ និងឧ.សិ.ហ្វាន់ យូលាង........ បារាំង

៩៨. ឧ.ស.លីម ធីនសួ ឧ.សិ. អ៊ឹង ឆាយហួ +បុត្រ. ... អូស្ត្រាលី

៩៩. ឧ.ស.ឡុង អ៊ាងលី ឧ.សិ. សេង ចិន្តា +បុត្រ ..... អូស្ត្រាលី

១០០. ឧ.សិ. ទិត នាង ................................ អូស្ត្រាលី

១០១. ឧ.ស. ប៉ុច រឿត ឧ.សិ.ញូង ស៊ាងម៉េង +បុត្រ .. អូស្ត្រាលី

១០២. ឧ.ស.ឌួង ឆែម ឧ.សិ.អ៊ុយ អ៊ាត និងបុត្រ ....

១០៣. ឧ.ស. ឌឿ សេង ឧ.សិ.លឹម យី និងបុត្រ .....

១០៤. ឧ.ស. សុខ សារឿន ឧ.សិ.ទូច ម៉ុម និងបុត្រ ..

១០៥. ឧ.សិ. ទូច លឹមអាំង និងឧ.សិ.ទូច សុផានី .....

១០៦. ឧ.សិ. គង់ ម៉ៃ ច្បារអំពៅ ......................... ភ.ព.

១០៧. ឧ.ស. កែវ ឆាត ឧ.សិ.កាន គិរីសុខា +កូនចៅ ..

១០៨. លោកយាយ ពិន សាត .......................... ស.រ.អ.

១០៩. លោក ចាន់ ម៉ល់ និងអ្នកស្រី ជា សុផា .......... ស.រ.អ.

១១០. ភិក្ខុ ឈម បូ (វិជ្ជាសម្បទា )...................... ស.រ.អ.



១១១. ឧ.ស.ឈឹម ហុកអ៊ាន ............................ បារាំង

១១២. ឧ.សិ.មុំ ទូច និងកូនឧ.សិ.សាមុល គឹមធន់ ........ ភ.ព.

១១៣. លោក ងួន បាន និងអ្នកស្រី លិន ដាណារី ...... ស.រ.អ.

១១៤. ឧ.សិ.រស់ សេរី និងឧ.សិ.សឿ ចន្ថា

១១៥. ឧ.សិ.លី ស៊ីវជូ ព្រមទាំងបុត្រ ..................... ភ.ព.

១១៦. ឧ.សិ. ឈ គឹមស៊ីន និង ក្រុមគ្រួសារ .......... អូស្ត្រាលី

១១៧. លោក ជា ស៊ុវត្ថានា និង អ្នកស្រី ឃុន សូនីម៉ា .. ស.រ.អ.

១១៨. ឧ.សិ.លីប៉ូលីនស៊ីមប៉ូ ព្រមទាំងបុត្រធីតា ........ ស.រ.អ.

១១៩. ឧ.ស.ហាក់ ច័ន្ទសុផល ឧ.សិ.វ៉ាង ស៊ីណា+បុត្រ ស.រ.អ.

១២០. ឧ.សិ.ស្រង់ អៃ ................................ ស.រ.អ.

១២១. ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី ........... ស.រ.អ.

១២២. ឧ.សិ.រស់ សុផល និងកូន ស៊ុន ............... ស.រ.អ.

១២៣. ឧ.សិ.ង៉ោ ស៊ូអេង ព្រមទាំងក្រុមគ្រួសារ ..... ស.រ.អ.

១២៤. ឧ.សិ.ស្រី រ័ត្ន ................................ ស.រ.អ.

១២៥. ឧ.សិ.សក់ សាន់នី និង ឧ.សិ.សក់ សាលី ..... ស.រ.អ.

១២៦. លោក សម ហ៊ន និង អ្នកស្រី ខាំ យ៉ាន ....... ស.រ.អ.

១២៧. ឧ.សិ.ថេង ម៉េងជូ ព្រមទាំងបុទ្រធីតា ........ ស.រ.អ.

១២៨. ឧ.សិ.សុផាណី ................................ ស.រ.អ.

១២៩. ឧ.សិ.សៀង ភាច .............................. ស.រ.អ.

១៣០. ឧ.សិ.ស៊ុន យ៉ូង +លោក គយ សេង និងគ្រួសារ ..........

១៣១. អ្នកស្រី គយ ហ្គេច ......................................

១៣២. អ្នកស្រី ផាន់ ណាលី និងក្រុមគ្រួសារ ....................

១៣៣. ឧ.សិ.ធុច ហ៊ូល ព្រមទាំងកូនចៅ .........................

១៣៤. ឧ.សិ.ម៉ម នាង ..........................................

១៣៥. ឧ.ស.គឹម ចាន់ជា .......................................

១៣៦. ពុទ្ធបរិស័ទ វត្តសុរិយរង្សី ...................... ស.រ.អ.

១៣៧. ឧ.សិ.ស៊ុយ ជាវលី ព្រមទាំងកូនចៅ ........... កាណាដា

១៣៨. ឧ.ស.ឡាវ លាងថេង និង ឧ.សិ.ពឹង ឈីវអ៊ាន.កាណាដា

១៣៩. ឧ.សិ.គឹម មុយ ព្រមទាំងក្រុមគ្រួសារ ............ បារាំង

១៤០. ឧ.សិ.ទាវ គឹមហ៊ួន ព្រមទាំងកូនចៅ ............. បារាំង

១៤១. ឧ.សិ.ដៀប រុន ព្រមទាំងបុត្រធីតា .............. បារាំង

១៤២. ឧ.សិ.ឡោត កិណរី ព្រមទាំងក្រុមគ្រួសារ ....... បារាំង

១៤៣. ឧ.សិ.តា យូអេង ព្រមទាំងបុត្រ និងចៅ .......... ភ.ព.

១៤៤. លោក ម៉េង ហ៊ា អ្នកស្រី ម៉ាន ស៊ីសុថា និងបុត្រ ..ភ.ព.

១៤៥. ឧ.ស.ចៅ ហ្វា ឧ.សិ.ឡា គឹមសាន និងបុត្រ ... ភ.ព.

១៤៦. ឧ.ស.ជិន ដេត និង ភរិយា ព្រមទាំងបុត្រ ..... ភ.ព.

១៤៧. ឧ.សិ.វៀន គង់+ស្វាមី និង ឧ.សិ.អ៊ុច សានី+ស្វាមី ភ.ព.

១៤៨. ក្រុមឧ.ស.អ៊ុច សុខុន វេនប្រចាំខែវត្តសុវណ្ណបទុម. ភ.ព.



១៤៩. ក្រុមឧ.ស. មួង -យេន វត្តសំពៅមាស ......... ភ.ព.

១៥០. ក្រុមឧ.ស. ផាន់- សារី វត្តទួលទំពូង ............... ភ.ព.

១៥១. ក្រុមវេនចង្ហាន់ ១កើតសំពៅមាស ៦កើតចំបក់មានជ័យ
១១កើតសុវណ្ណបទុម ១រោចធុតង្គ ៦រោចនិគ្រោធវ័ន
១០រោចវេឡុវ័ន .................................... ភ.ព.

១៥២. មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន ខេត្តពោធិ៍សាត់ ..

១៥៣. ក្រុមពុទ្ធបរិស័ទនៅទីក្រុងស៊ីតនី ប្រទេសអូស្ត្រាលី .......

១៥៤. ក្រុមពុទ្ធបរិស័ទស្រុកមង្គលបូរី+សិរីសោភ័ណ ... ប.ម.ជ.

១៥៥. ក្រុមពុទ្ធបរិស័ទចិត្តបុណ្យក្នុងសហគមន៍ធម្មទាន

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

## នាមពុទ្ធបរិស័ទដែលមានសទ្ធា
## បរិច្ចាគប្រាក់បោះពុម្ពសៀវភៅនេះ

| | | |
|---|---|---|
| ១- | ប្រាក់បូជាព្រះធម៌នៅវត្តអែរ៉ាប់ បុណ្យឧបាសក អ៊ុន ឆៃគ្រី.... | ៥២៥ $ |
| ២- | ប៉េង ស៊ីវ+ភរិយា PENG SIV CAHEANG PANG CHORN.. | ៥០០ $ |
| ៣- | ឧ.សិ.សុផានី ......................................................... | ៥០០ $ |
| ៤- | ប្រាក់បូជាព្រះធម៌នៅវត្តអែរ៉ាប់ បុណ្យឧបាសិកា សុំ ......... | ៥០០ $ |
| ៥- | ឧ.សិ.ឡៅ ប៊ូតា ................................................... | ៥០០ $ |
| ៦- | ឧ.ស.ឡាយ សុខុម និង ឧ.សិ.សួនចន្ថា ព្រមទាំងបុត្រ . | ៣២០ $ |

៧- សាមណេរ សោម ហួន ............................................. ៣០០ $

៨- ឧ.សិ.លីប៉ូលីនស៊ីប៉ូ និងក្មួយប្រុស សេងលីប៊ុនណាត+ក្មួយ+ចៅ ៣០០ $

៩- ឧ.សិ.ទុំ ផៃ ព្រមទាំងកូនចៅ ......................................... ៣០០ $

១០- ឧ.ស.លី ភិនហែម និង ឧ.សិ.ថេង ឡាំគី .......................... ៣០០ $

១១- ឧ.សិ.ស៊ូ ស្រ៊ុន ព្រមទាំងបុត្រ ..................................... ៣០០ $

១២- ក្រុមអ្នកទិញកាសែត នៅម៉ែលបិន ប្រទេសអូស្ត្រាលី ........ ២៦០ $

១៣- ផេង ហៀក+ផេង នាង+រ៉ុន ចរណៃ+ចាន់ សុខកាន់+រស្មី+... ២៥០ $

១៤- លោកយាយ ឧត្តមា ពេជ្រអូន ..................................... ២០០ $

១៥- ឧ.សិ.ផាវ សារឿប ..................................................... ២០០ $

១៦- ឧ.សិ.ភន សៀងហៃ ព្រមទាំងបុត្រ ................................ ២០០ $

១៧- ឧ.សិ.ជៀវ អេងលី ហៅនាង ....................................... ២០០ $

១៨- ពុទ្ធបរិស័ទ ម៉ាលិនដា អ៊ឹង និង គ្រួសារ .......................... ២០០ $

១៩- ឧ.សិ.មុនីរ័ត្ន ព្រមទាំងកូនស្រី ...................................... ២០០ $

២០- ឧ.ស.ពៅ វ៉ែន និង ឧ.សិ.ឡាច យៀម ........................... ២០០ $

២១- លោក ហេង ឆៃទិត និង លោកស្រី រស់ ម៉ារី ព្រមទាំងបុត្រ ... ២០០ $

២២- ឧ.សិ. ស៊ុយ ជាវលី ................................................ ២០០ $

២៣- លោកអាចារ្យ មាស សារ៉េត ...................................... ១៨០ $

២៤- ឧ.ស.សោម រតនៈ និង ឧ.សិ.ស៊ុប វណ្ណា ព្រមទាំងបុត្រ ....... ១៧០ $

២៥- ឧ.ស.ម៉ាក់ អ៊ុយ ឧ.សិ.យឹម ហ៊ុន+បុត្រ និងលោក មិន អាន .. ១៦០ $

២៦- លោកតា កុងឡោង៉ុយឡៃ ឧ.សិ.ស៊ន ឡេង ព្រមទាំងបុត្រ ១៥០ $

២៧- ឧ.ស.ប៊ូ ហោនាង ឧ.សិ.អ៊ឹង វីទ្ធារី និងកូនឧ.សិ.អ៊ឹង មារីនណា ១៥០ $

២៨- លោក ទៀវ ផាង និងអ្នកស្រី លឹម ឡេង ព្រមទាំងបុត្រ ..... ១៥០ $



២៩- ឧ.ស.ប៉ុង អាង និង ឧ.សិ.អឿង លាងជុន ......................... ១៥០ $

៣០- ឧ.សិ.ឡេង អម ...................................................... ១៥០ $

៣១- ឧ.ស.ផាត សាវឿយ ឧ.សិ.វ៉ាត អម+បុត្រ+ ឧ.ស.មិន អាន ១៣០ $

៣២- ឧ.សិ.អឹម តិប និងឧ.សិ.ពេជ្រ បុទុម ព្រមទាំងបុត្រធីតា ....... ១២០ $

៣៣- ឯកឧត្តម អ៊ិត ប្រាំង លោកជំទាវ ញ៉ែម សេដ្ឋា ព្រមទាំងបុត្រ ១០០ $

៣៤- ពុទ្ធបរិស័ទ ជូ គីមស្រាយ ............................................ ១០០ $

៣៥- លោកគ្រូ អឿ សៅ និងអ្នកម្តាយ នូ ប៉ុក ......................... ១០០ $

៣៦- ឧ.ស.អៀម វ៉ន ឧ.សិ.សុខ សោរិន+បុត្រ និង លោក មិន អាន ១០០ $

៣៧- ឧ.សិ.ធីក ស្រ៊ន និងកូន អ៊ឹង វិទ្ធី+ភរិយា អ៊ឹង វិទ្ធថារិ+ស្វាមី ១០០ $

៣៨- ឧ.សិ.ទិន ឈីវ និងកូនស្រីឧ.សិ.ទូច ផាន់នី +គ្រួសារ និងបុត្រ ១០០ $

៣៩- ឧ.ស.ជិម អេងស្រ៊ន និងឧ.សិ.វ៉ា សុខគីន ព្រមទាំងបុត្រ ....... ១០០ $

៤០- ឧ.សិ.ព្រះ ឈៀង ព្រមទាំងបុត្រ .................................. ១០០ $

៤១- ឧ.សិ.លី គីមសៀ ..................................................... ១០០ $

៤២- ឧ.ស.អ៊ួង ម៉េង និង ឧ.សិ.ស៊ីវ ហ៊ាង ............................... ១០០ $

៤៣- ឧ.ស.វីរ៉ាត David Viradet Krend ........................... ១០០ $

៤៤- ឧ.សិ.ហៀក ព្រមទាំងកូនចៅ ..................................... ១០០ $

៤៥- ឧ.សិ.ណៃស្រីម ធីក ហៅ នួន ផន ព្រមទាំងបុត្រធីតា .......... ១០០ $

៤៦- ឧ.ស.ម៉ក់ គីមឡុង និងឧ.សិ.សេក សាវឿន ព្រមទាំងបុត្រ .. ១០០ $

៤៧- ឧ.ស.ឈាង ឆេង និងឧ.សិ.ង៉ាន ម៉ុម ព្រមទាំងបុត្រធីតា ....... ១០០ $

៤៨- ឧ.សិ.លឹម ហ៊ួចឆាយ ................................................. ១០០ $

៤៩- អ្នកស្រី ទូច ង៉ា ....................................................... ១០០ $

៥០- ឧ.សិ.ចៅ សារួន ..................................................... ១០០ $

| | | |
|---|---|---|
| ៥១- | ឧ.សិ.ទី សារីន -ហ៊ីរិម៉ា ................................................ | ១០០ $ |
| ៥២- | ឧ.សិ.អ៊ុន សាងឿន ................................................... | ១០០ $ |
| ៥៣- | ឧ.ស.ឡុង សុវត្ថិ ...................................................... | ១០០ $ |
| ៥៤- | ឧ.ស.ពុធ ប៉ោលាង និងឧ.សិ.ហ៊ុន ស៊ីវអៀង ព្រមទាំងបុត្រ .... | ១០០ $ |
| ៥៥- | M. CHHEM SOKRETH et Mme PUTH KUNTHEA ....... | ១០០ $ |
| ៥៦- | M.SU SOKUNORA MmeINN VISAL÷NARITA et RAKSA . | ១០០ $ |
| ៥៧- | ឧ.សិ.ច័ន្ទ បុប្ផាណា ព្រមទាំងបុត្រធីតា .............................. | ១០០ $ |
| ៥៨- | ឧ.សិ.ភូ ហ្គួចឡាន ...................................................... | ១០០ $ |
| ៥៩- | ឧបាសិកា THARY UNG ............................................ | ១០០ $ |
| ៦០- | ឧ.ស.ទិត សូនី និង ភរិយា មាឃ សាវ៉ាន់ ព្រមទាំងបុត្រ ........ | ១០០ $ |
| ៦១- | ឧ.សិ. សក់ សាន់លី និង ឧ.សិ.សក់ សាលី ........................ | ១០០ $ |
| ៦២- | . CHEA NEANG ..................................................... | ១០០ $ |
| ៦៣- | ឧ.សិ.អ៊ា នៅ ........................................................... | ១០០ $ |
| ៦៤- | ឧ.ស.ឡាវ លាងថេង និង ឧ.សិ.ពឹង ឈីវអ៊ាន .................... | ១០០ $ |
| ៦៥- | ឧ.សិ.ម៉ី សុគន្ធារី ....................................................... | ១០០ $ |
| ៦៦- | ឧ.សិ.ឡាច រុំ ............................................................ | ១០០ $ |
| ៦៧- | ឧ.សិ.ស្រេង់ អៃ ......................................................... | ១០០ $ |
| ៦៨- | ឧ.ស.ឡាង រតនៈមុនី និង ឧ.សិ.ចន្ទ លីដា ព្រមទាំងបុត្រ ..... | ១០០ $ |
| ៦៩- | ឧ.ស.រស់ ប៊ុនឈឿន និង ភរិយា បញ្ញា ............................ | ១០០ $ |
| ៧០- | ឧ.សិ.ចាន់សុកាន់+ចាន់ស៊ីចាយ+ចាន់ហេង+ចាន់តាក់+ចាន់តេង | ១០០ $ |
| ៧១- | ឧ.សិ.យ៉ោក សំ ......................................................... | ១០០ $ |
| ៧២- | លោក ហ៊ឹម ណាំង និងលោកស្រី ស៊ីណា ណាំង .................... | ១០០ $ |



| | | |
|---|---|---|
| ៧៣- | ឧ.សិ.លឹម ស៊ីវឆេង .................................................. | ១០០ $ |
| ៧៤- | ឧ.សិ ភោគ សឿន .................................................... | ១០០ $ |
| ៧៥- | ឧ.សិ.តាំង ប៉ៅណៃ ព្រមទាំងបុត្រ និង ចៅ ....................... | ១០០ $ |
| ៧៦- | ដួនជី នាង ទូច ................................ ៤០.០០០៛ + | ១០០ $ |
| ៧៧- | ឧ.ស.លឹម ហួយ និង ឧ.សិ.ចេក ឡាំង ព្រមទាំងបុត្រធីតា | ១០០ $ |
| ៧៨- | ឯកឧត្តម គីម សាន្ត និងលោកជំទាវ សារ៉ារ៉ាត់ គីមសាន្ត . | ១០០ $ |
| ៧៩- | ឧ.ស.ឈីវ ឃួយ និង ឧ.សិ.ស៊ីវ លាង ........................ | ១០០ $ |
| ៨០- | ឧ.ស.ហុក ណារី និង ស្វាមី ព្រមទាំងបុត្រធីតា ............ | ១០០ $ |
| ៨១- | លោក លី សុងស្រេង ............................................. | ១០០ $ |
| ៨២- | ពុទ្ធបរិស័ទ លឹម សៀកអាន .................................... | ១០០ $ |
| ៨៣- | ឧ.សិ.តាំង គីមលាង ................................................... | ៨០ $ |
| ៨៤- | ឧ.ស.ងីម ញាណ និង ឧ.សិ.កាំង ប៉ូលីន ព្រមទាំងបុត្រ ......... | ៨០ $ |
| ៨៥- | លោកអាចារ្យ ម៉ែន វិត និងឧ.សិ.ស្នាន់ ឈឿន ព្រមទាំងបុត្រ | ៧០ $ |
| ៨៦- | ឧ.សិ. សារ៉ាត យឹម ព្រមទាំងបុត្រ ................................ | ៧០ $ |
| ៨៧- | ឧ.សិ.បែន សាវើយ និង ឧ.សិ.ថាប់ ជុំផន ហៅយឹង ............ | ៧០ $ |
| ៨៨- | ឧ.សិ.គិន ស្រ៊ន + សុរ៉ាត់ ហង់ +គ្រួសារ+នាងសុចិត្រា+គ្រួសារ | ៦០ $ |
| ៨៩- | វេជ្ជបណ្ឌិត លន់ គីមវុធ និង ចាន់ ថន ............................... | ៦០ $ |
| ៩០- | ឧ.សិ.ជីង គីមស៊ាង ព្រមទាំងកូនចៅ ............................... | ៦០ $ |
| ៩១- | ឧ.ស.អ៊ុច ហាន និង គ្រួសារ ....................................... | ៦០ $ |
| ៩២- | ឧ.ស.ឡោ សេងជ្រុន និងឧ.សិ.ផាំង លី ព្រមទាំងបុត្រ ........ | ៥០ $ |
| ៩៣- | ឧ.ស.ខឹប ឡាយហៀង និងឧ.សិ.ខៀវ ស៊ីនួន ...................... | ៥០ $ |
| ៩៤- | ឧ.ស.យិន យ៉ាន់ និង ឧ.សិ.គង់ យ៉េន ............................... | ៥០ $ |

៩៥- ឧ.សិ.អេង សុខយ៉ាង ............................................... ៥០ $

៩៦- ឧ.សិ.ធង អឹម ហៅ ណាច្ចគី ........................................ ៥០ $

៩៧- លោកយាយ ខ្សៅវ មឿន ........................................... ៥០ $

៩៨- ល្បៅវ គីមវួច ព្រមទាំងកូនចៅ .................................... ៥០ $

៩៩- ឧ.សិ.សេង ពុធ ព្រមទាំងបុត្រធីតា និងចៅៗ.................. ៥០ $

១០០- ឧ.ស.ខ្សៅវ ស៊ីណារ៉ុន ឧ.សិ.ស៊ឹម បុប្ផា+ឧ.ស.ខ្សៅវ ស៊ីណារ៉េត ៥០ $

១០១- ឧ.សិ.ហេង រី ព្រមទាំងបុត្រ ....................................... ៥០ $

១០២- ឧ.សិ.ទឹម ហ៊ាន ព្រមទាំងកូនចៅ .................................. ៥០ $

១០៣- ឧ.សិ.លី ណារី ......................................................... ៥០ $

១០៤- លោក ដាវីដ ហេង និង អ្នកស្រី ឡា ណារី ...................... ៥០ $

១០៥- អ្នកស្រី សេង ម៉ាស៊ី ប៉ោជូ ........................................... ៥០ $

១០៦- ឧ.សិ.កែវ មុំ +គ្រួសារ និង ឧ.សិ. កែវ ប៊ុនរ័ត្ន +គ្រួសារ ...... ៥០ $

១០៧- ពុទ្ធបរិស័ទ សឹម លៀងហួត ហាក់ជន ............................ ៥០ $

១០៨- ឧ.សិ.ណៃ ស៊ីណា ...................................................... ៥០ $

១០៩- ឧ.សិ.ខាំមី កែវហ៊ុនតា ............................................... ៥០ $

១១០- ឧ.សិ.គឹម លាង ....................................................... ៥០ $

១១១- ពុទ្ធបរិស័ទ ឃូ ប៊ួយហេង ............................................ ៥០ $

១១២- ឧ.សិ.ចាន់ សុខុម ព្រមទាំងកូនចៅ ............................... ៥០ $

១១៣- លោក យឹម បុណ្ណា អ្នកស្រី ទុន សុគន្ធ ព្រមទាំងបុត្រធីតា .. ៥០ $

១១៤- លោក ស្រី ត្រិន និងអ្នកស្រី ម៉ៅ នឿន ......................... ៥០ $

១១៥- ឧ.សិ.អ៊ួន លន ......................................................... ៥០ $

១១៦- អ្នកស្រី ពេជ្រ មុនីចាន់ និងគ្រួសារ ............................... ៥០ $



១១៧- Mrs.Leaphy-sak ............................................... ៥០ $

១១៨- លោក គង់ ភឿន គង់លី ទឹម សីហា ............................ ៥០ $

១១៩- ឧ.ស.អ៊ៀង សាក់កុស៊ុន និង ឧ.សិ.គង់សៅវរ៉េត ............ ៥០ $

១២០- អ្នកស្រី អោក ផាន ..................................................... ៥០ $

១២១- លោក ពេជ្រ សាវៀន និងអ្នកស្រី ជា សុខបាន .............. ៥០ $

១២២- លោក ទេព សំអាន ហៅ យួម និងភរិយា ឌី និងកូនចៅ ៥០ $

១២៣- ឧ.ស.ពៅ សូនិត និងឧ.សិ.អេង លី ព្រមទាំងបុត្រ .......... ៥០ $

១២៤- ឧ.ស.ស៊ុន ស៊ីម និងឧ.សិ.សូ ស៊ុន ហៅ មុំ ..................... ៥០ $

